OLD VERSION

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

អង្គជំនុំជម្រះសាលាដំបូង
Trial Chamber
Chambre de Premiere instance

ឯកសារដើម
ORIGINAL/ORIGINAL
ថ្ងៃ ខែ ឆ្នាំ (Date): 25-May-2015, 13:24
CMS/CFO: Sann Rada

# កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃកិច្ចដំណើរការនីតិវិធី
# ជំនុំជម្រះក្តីនៅដំណាក់កាលពីរ
# សាធារណៈ

សំណុំរឿងលេខ ០០២/១៩-០៩-២០០៧/អវតក/អជសដ

**ថ្ងៃទី១៨ ខែឧសភា ឆ្នាំ២០១៥**

**ម៉ោង ០៩:១៣នាទី**

**សវនាការលើកទី២៨១**

**ចៅក្រមសាលាដំបូង៖**

ចៅក្រម និល ណុន ជាប្រធាន

ចៅក្រម ក្លូឌា ហ្វេនស៍
*(Judge Claudia FENZ)*

ចៅក្រម យ៉ា សុខន

ចៅក្រម ហ្សង់ម៉ាក ឡាវែន៍
*(Judge Jean-Marc LAVERGNE)*

ចៅក្រម យូរ ឧត្តរា

ចៅក្រម ធូ មណី (បម្រុង)

ចៅក្រម ម៉ាទីន ខារ៉ុបគីន (បម្រុង)
*(Judge Martin KAROPKIN)*

**ក្រឡាបញ្ជីសាលាដំបូង៖**

លោកស្រី សែ កុលវុឌ្ឍ

លោក ឯម ហ៊ាយ

លោក រ៉ូជឺ ហ្វីលីព *(Mr.Roger PHILLIP)*

**ការិយាល័យសហព្រះរាជអាជ្ញា៖**

លោក ឌេល លីសាក់ (*Mr. Dale LYSAK*)

កញ្ញា សុង ឆរ័ន្ត

**ជនជាប់ចោទ៖**

លោក នួន ជា

លោក ខៀវ សំផន

**មេធាវីការពារជនជាប់ចោទ នួន ជា៖**

លោក សុន អរុណ

លោក លីវ សុវណ្ណា

លោក វ៉ិចទ័រ កូប៉េ*(Mr.Victor KOPPE)*

**មេធាវីការពារជនជាប់ចោទ ខៀវ សំផន៖**

លោក គង់ សំអុន

កញ្ញា អង់តា ហ្គីសសេ *(Ms. Anta GUISSÉ)*

**មេធាវីប្រចាំការលោក ខៀវ សំផន៖**

លោកស្រី ទូច វរល័ក្ស

លោក ខលវីន សោនដឺស៍ *(Mr Calvin SAUNDERS)*

**មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី៖**

លោកស្រី ម៉ារី ហ្គីរ៉ូដ៍ *(Ms.Marie GUIRAUD)*

លោក វ៉េន ពៅ

**ផ្នែកគ្រប់គ្រងតុលាការ៖**

លោក អ៊ុច អរុណ

លោកស្រី ស្វ សុទ្ធាវី

## បញ្ជីឈ្មោះអ្នកនិយាយ៖

ភាសាដែលបានប្រើ លើកលែងតែមានការបញ្ជាក់ផ្សេងទៀតនៅក្នុងប្រតិចារឹក

| **អ្នកនិយាយ** | **ភាសា** |
|---|---|
| ចៅក្រម និល ណុន (ប្រធានអង្គជំនុំ) | ខ្មែរ |
| ចៅក្រម ក្លូឌា ហ្វេនស៍ | អង់គ្លេស |
| លោក ឌេល លីសាក់ | អង់គ្លេស |
| លោក សុន អរុណ | ខ្មែរ |
| លោក គង់ សំអុន | ខ្មែរ |
| លោក វិចទ័រ កូប៉េ | អង់គ្លេស |
| កញ្ញា អង់តា ហ្គីសសេ | បារាំង |
| លោកស្រី វង សារុន (2-TCW-986) | ខ្មែរ |

# ឧបសម្ព័ន្ធ

**ការសួរសំណួរទៅសាក្សី៖ លោកស្រី ខេង សារុន** (2-TCW-986)

សួរដោយប្រធានអង្គជំនុំ ផ្តើមពី ....................ទំព័រ ២
សួរដោយលោក ឌេល លីសាក់ ផ្តើមពី ....................ទំព័រ ៥
សួរដោយចៅក្រម ក្លូឌា ហ្វេនស៍ ផ្តើមពី....................ទំព័រ ៣៧
សួរដោយកញ្ញា អង់តា ហ្គីសសេ ផ្តើមពី....................ទំព័រ ៤៤
សួរដោយលោក វ៉ិចទ័រ កូប៉េ ផ្តើមពី....................ទំព័រ ៤៩

# កិច្ចដំណើរការនីតិវិធី

*(ចៅក្រមចូលក្នុងបន្ទប់សវនាការ)*

[០៩:១៣:៣០]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ។ នៅថ្ងៃនេះអង្គជំនុំជម្រះធ្វើសវនាការស្តាប់សក្ខីកម្មសាក្សីដែលមានរហស្សនាម 2-TCW-986។

ក្រឡាបញ្ជីសវនាការ លោកស្រី សែ កុល វុឌ្ឍី ឡើងរាយការណ៍អំពីស្ថានភាពវត្តមាន អវត្តមានភាគី និងបុគ្គលដែលអង្គជំនុំជម្រះកោះអញ្ជើញឲ្យចូលរួមនៅក្នុងកិច្ចដំណើរការសវនាការថ្ងៃនេះ។

**ក្រឡាបញ្ជី៖**

សូមគោរពលោកប្រធាន សម្រាប់សវនាការនៅថ្ងៃនេះ ក្រឡាបញ្ជីកត់សម្គាល់ឃើញថា គ្រប់ភាគីទាំងអស់នៃរឿងក្តីនេះ មានវត្តមាន លើកលែងតែលោក វ៉ិចទ័រ កូប៉េ មេធាវីអន្តរជាតិការពារក្តីឲ្យលោក នួន ជា អវត្តមាននៅថ្ងៃនេះ ដោយមូលហេតុផ្ទាល់ខ្លួន ហើយលោក ខលវីន សោនដឺស៍ មេធាវីប្រចាំការសម្រាប់លោក ខៀវ សំផន អវត្តមានដោយមូលហេតុផ្ទាល់ខ្លួនផងដែរ។ ដោយឡែកលោក នួន ជា មានវត្តមាននៅបន្ទប់ឃុំខ្លួនខាងក្រោមសាលសវនាការនេះ ដោយមូលហេតុសុខភាព។ ហើយសាក្សីដែលត្រូវមកផ្តល់សក្ខីកម្មនៅថ្ងៃនេះ គឺសាក្សីដែលមានរហស្សនាម 2-TCW-986។ សាក្សីបានបញ្ជាក់ថា តាមសមត្ថភាពដែលគាត់អាចដឹងគឺគាត់មិនមានទំនាក់ទំនងញាតិលោហិត ឬញាតិពន្ធជាមួយនឹងជនជាប់ចោទទាំងពីររូប គឺលោក នួន ជា និងលោក ខៀវ សំផន ឬភាគីដើមបណ្តឹងរដ្ឋប្បវេណីណាមួយដែលត្រូវបានទទួលស្គាល់នៅក្នុងរឿងក្តីនេះទេ។ សាក្សីបានធ្វើសម្បថរួចហើយនៅចំពោះមុខលោកតាដំបងដែកកាលពីព្រឹកមិញនេះ។ សូមអរគុណលោកប្រធាន។

[០៩:១៥:២៤]

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។

យ៉ាងម៉េចទៅខាងលោកមេធាវីការពារក្តី នួន ជា ដូចមិនបានដាក់នូវលិខិតសុំលះបង់សិទ្ធិទេ។

**លោក សុន អរុណ៖**

ខាងលោក ផល្លា ទើបមកដល់ព្រោះអី ជាប់*ត្រាហ្វិក* – ជាប់ចរាចរណ៍ច្រើន ម៉្លោះហើយធ្វើមិនទាន់។ បន្តិចទៀតនឹងដាក់ជូនទៅតុលាការ បាទ។

**ប្រធានអង្គជំនុំ៖**

បាទ អង្គជំនុំជម្រះបានស្ដាប់សំណើសុំរបស់លោកជនជាប់ចោទ នួន ជា ដែលធ្វើឡើងតាមរយៈមេធាវីការពារក្ដីរបស់ខ្លួន សុំតាមដានកិច្ចដំណើរការសវនាការពីចម្ងាយ រយៈពេលសវនាការពេញមួយថ្ងៃនេះ ដោយលះបង់សិទ្ធិចូលរួមសវនាការដោយផ្ទាល់ក្នុងបន្ទប់សវនាការនេះ។ ហើយក្រុមមេធាវីការពារក្ដី សន្យានឹងប្រគល់មកឱ្យអង្គជំនុំជម្រះនូវលិខិតលះបង់សិទ្ធិចូលរួមសវនាការដោយផ្ទាល់របស់ជនជាប់ចោទ។ យោងតាមបទប្បញ្ញត្តិនៃវិធាន៨១(៥) នៃវិធានផ្ទៃក្នុង អ.វ.ត.ក អង្គជំនុំជម្រះយល់ព្រមនិងអនុញ្ញាតឱ្យជនជាប់ចោទ នួន ជា បន្តតាមដានកិច្ចដំណើរការសវនាការពីចម្ងាយពីបន្ទប់ឃុំខ្លួនមួយស្ថិតក្រោមសាលសវនាការនេះតាមរយៈឧបករណ៍សោតទស្សន៍សម្រាប់រយៈពេលសវនាការពេញមួយថ្ងៃនេះ ដោយលោក នួន ជា លះបង់សិទ្ធិចូលរួមក្នុងកិច្ចដំណើរការសវនាការដោយផ្ទាល់ក្នុងបន្ទប់សវនាការនេះ។

អង្គជំនុំជម្រះតម្រូវឱ្យក្រុមមេធាវីការពារក្ដីជនជាប់ចោទ នួន ជា ប្រគល់ជូនមកអង្គជំនុំជម្រះភ្លាមនូវពាក្យសុំលះបង់សិទ្ធិចូលរួមសវនាការដោយផ្ទាល់ក្នុងបន្ទប់សវនាការដោយមានចុះហត្ថលេខា ឬផ្ដិតស្នាមម្រាមដៃច្បាស់លាស់របស់ជនជាប់ចោទ នួន ជា។

បង្គាប់ឱ្យបុគ្គលិកផ្នែកសោតទស្សន៍ភ្ជាប់ប្រព័ន្ធសោតទស្សន៍សម្រាប់ឱ្យជនជាប់ចោទ នួន ជា ចូលរួម និងតាមដានកិច្ចដំណើរការសវនាការពីចម្ងាយពីបន្ទប់ឃុំខ្លួនមួយស្ថិតក្រោមសាលសវនាការក្នុងអំឡុងពេលនៃកិច្ចដំណើរការសវនាការពេញមួយថ្ងៃនេះ។

មន្ត្រីរដ្ឋបាលតុលាការអញ្ជើញសាក្សីចូលមកកាន់កន្លែងផ្ដល់សក្ខីកម្មនៅក្នុងបន្ទប់សវនាការ!

[០៩:១៩:៣៧]

**ការតាំងសំណួរដោយចៅក្រម**

**សួរដោយប្រធានអង្គជំនុំ៖**

**ស៖** សួស្ដី លោកស្រីសាក្សី! តើលោកស្រីឈ្មោះអី?

**លោកស្រី វង សារុន៖**

**ឆ៖** ខ្ញុំឈ្មោះ វង សារុន។

**ស៖** បាទ អរគុណ លោកស្រី វង សារុន។ តើលោកស្រីកើតនៅថ្ងៃខែឆ្នាំណា លោកស្រីចាំដែរទេ?

**ឆ៖** ចាស ចាំ។ ថ្ងៃទី២៨ ខែ១១ ១៩៥៤។

**ស៖** បាទ អរគុណ ហើយទីកន្លែងកំណើតរបស់លោកស្រីនៅទីកន្លែងណា?

**ឆ៖** ទីកន្លែងកំណើតរបស់ខ្ញុំ នៅភូមិខ្នាយខាងត្បូង ឃុំដងទង់ ស្រុកដងទង់ ខេត្តកំពត។

**ស៖** បាទ អរគុណ។ ចុះទីលំនៅសព្វថ្ងៃនេះ តើលោកស្រីរស់នៅទីកន្លែងណា?

**ឆ៖** ចាស នៅភូមិឃុំ ដូចខ្ញុំបានជម្រាបមុន។

**ស៖** បាទ អរគុណ។ ហើយប្រកបមុខរបរស៊ីអ្វីដែរ សព្វថ្ងៃនេះ?

**ឆ៖** កាលពីមុនដែលមកពីរត់៧៩ នាងខ្ញុំធ្វើជាគ្រូបង្រៀនសាលាបឋម តែឥឡូវនេះចូលនិវត្តន៍។

[០៩:២១:១១]

**ស៖** បាទ អរគុណ ហើយឪពុកបង្កើតរបស់លោកស្រីគាត់ឈ្មោះអី? ហើយម្ដាយបង្កើតរបស់លោកស្រីគាត់ឈ្មោះអី?

**ឆ៖** ឪពុកបង្កើតរបស់ខ្ញុំឈ្មោះ ហួរ ស។ ម្ដាយឈ្មោះ ឡុញ ហេន។

**ស៖** ចុះស្វាមីរបស់លោកស្រីឈ្មោះអី? ហើយលោកស្រីមានកូនប៉ុន្មាននាក់?

**ឆ៖** ស្វាមីខ្ញុំឈ្មោះ ប្រាជ្ញ សុន ហៅ សែត។ មានកូនបួននាក់។

**ស៖** បាទ អរគុណលោកស្រី វង សារុន។ តាមរបាយការណ៍ក្រឡាបញ្ជីរបស់សវនាការអម្បាញ់មិញនេះ ថាតាមសមត្ថភាពដែលលោកស្រីដឹង គឺលោកស្រីមិនមានឪពុកម្ដាយបុព្វញាតិ កូនបច្ឆាញាតិ បងប្អូនប្រុសស្រី បងប្អូនថ្លៃ ប្ដី ត្រូវទទួលជាដើមបណ្ដឹងរដ្ឋប្បវេណីនៅក្នុងរឿង០០២នេះទេ។ តើជាការពិតមែនដែរឬទេ?

**ឆ៖** ចាស ខ្ញុំឲ្យសួរសំណួរម្ដងទៀត។

**ស៖** តាមក្រឡាបញ្ជីរបាយការណ៍អម្បាញ់មិញនេះ ថាតាមសមត្ថភាពដែលលោកស្រីអាចដឹងបាន គឺថាលោកស្រីមិនមានឪពុកម្ដាយ បុព្វញាតិ កូន ឬបច្ឆាញាតិ បងប្អូនប្រុសស្រី បងប្អូនថ្លៃ ប្ដី ត្រូវបានទទួលយកជាភាគីដើមបណ្ដឹងរដ្ឋប្បវេណីនៅក្នុងរឿងក្ដី០០២នេះទេ។ តើជាការពិតដែរឬទេ?

[០៩:២២:៥៤]

**ឆ៖** ខ្ញុំហាក់ដូចជាអត់យល់សំណួរនេះ។

**ស៖** លោកស្រី តើលោកដឹងថា ស្រីដឹងមានបងប្អូនរបស់លោកស្រីបានតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីពាក់ព័ន្ធនឹងរឿងក្តីនេះទេ?

**ឆ៖** អត់មានទេ។

**ស៖** បាទ អរគុណ។ ហើយថាលោកស្រីបានស្បថរួចហើយ មុននឹងចូលមកផ្តល់សក្ខីកម្មនៅក្នុងបន្ទប់សវនាការចំពោះមុខអង្គជំនុំជម្រះនេះ។ ពិតជាអ៊ីចឹងមែនទេ?

**ឆ៖** ចាស ខ្ញុំបានស្បថហើយ ហើយ។

**ស៖** បាទ តទៅនេះ អង្គជំនុំជម្រះសូមប្រាប់អំពីសិទ្ធិ និងករណីយកិច្ចដល់លោកស្រី ក្នុងនាមជាសាក្សីនៅចំពោះមុខអង្គជំនុំជម្រះ អំពីសិទ្ធិលោកស្រី វង សារុន ក្នុងនាមលោកស្រីជាសាក្សីនៅក្នុងកិច្ចដំណើរការនីតិវិធីចំពោះមុខអង្គជំនុំជម្រះនេះ លោកស្រីអាចបដិសេធក្នុងការឆ្លើយទៅនឹងសំណួរ ឬការធ្វើអំណះអំណាងណាមួយ ឬច្រើន ដែលនាំឲ្យដាក់ពិរុទ្ធភាពលើខ្លួនឯង។ សិទ្ធិមិនធ្វើសក្ខីកម្មប្រឆាំងនឹងខ្លួនឯង។ មានន័យថាដោយសារតែចម្លើយ ឬអំណះអំណាងរបស់លោកស្រីនោះ ហើយនាំឲ្យលោកស្រីនឹងទទួលរងការចោទប្រកាន់។

អំពីករណីយកិច្ច ក្នុងនាមលោកស្រីត្រូវផ្តល់សក្ខីកម្មក្នុងកិច្ចដំណើរការសវនាការនៅចំពោះមុខអង្គជំនុំជម្រះនេះ លោកស្រីត្រូវតែឆ្លើយតបទៅនឹងរាល់សំណួរទាំងឡាយ ដែលភាគី ឬចៅក្រមនៃអង្គជំនុំជម្រះសួរចំពោះលោកស្រី លើកលែងតែសំណួរណាដែលនាំឲ្យចម្លើយតប ឬការធ្វើអត្ថាធិប្បាយរបស់លោកស្រីដែលនាំឲ្យដាក់ពិរុទ្ធភាពលើខ្លួនឯង ដូចយើងប្រាប់អំពីសិទ្ធិអម្បាញ់មិញរួចហើយ។ ហើយក្នុងនាមលោកស្រីជាសាក្សីត្រូវតែឆ្លើយឲ្យការណ៍ណាដែលពិត ដែលលោកស្រីបានដឹង បានឮ បានឃើញ បានចងចាំ ឬធ្លាប់មានពិសោធន៍ជួបប្រទះ ឬបានធ្វើការសង្កេតដោយផ្ទាល់នូវព្រឹត្តិហេតុ ឬហេតុការណ៍ទាំងឡាយដែលពាក់ព័ន្ធទៅនឹងសំណួរ ដែលភាគី ឬចៅក្រមនៃអង្គជំនុំជម្រះសួរចំពោះលោកស្រី។ តើលោកស្រីយល់ទេ អំពីសិទ្ធិ និងករណីយកិច្ចក្នុងនាមជាសាក្សីនៅចំពោះមុខអង្គជំនុំជម្រះ?

[០៩:២៥:០២]

**ឆ៖** ចាស ខ្ញុំយល់ហើយ។

**ស៖** បាទ អរគុណ ហើយលោកស្រី វង សារុន តើរយៈពេលកន្លងមក លោកស្រីធ្លាប់បានផ្តល់

សក្ខីកម្ម ឬផ្តល់កិច្ចសម្ភាសន៍ជាមួយនឹងអ្នកស៊ើបអង្កេតនៃការិយាល័យសហចៅក្រមស៊ើបអង្កេតនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាដែរឬទេ?

**ឆ៖** ចាស អត់ដែលជួបទេ។

**ស៖** បាទ អរគុណ ហើយនៅក្នុងរឿងនេះ ប្រសិនបើអនុវត្តតាមវិធាន៩១ស្ទួន នៃវិធានផ្ទៃក្នុង អ.វ.ត.ក នោះអង្គជំនុំជម្រះត្រូវប្រគល់វេទិកាជូនទៅមេធាវីការពារក្តី នួន ជា សួរសាក្សីនេះមុនភាគីដទៃទៀតនៃរឿងក្តី ប៉ុន្តែដោយសារខាងមេធាវីការពារក្តី នួន ជា ស្នើសុំសួរក្រោយវិញ ទោះបីគាត់ជាម្ចាស់សំណើក្នុងការស្នើសុំសួរស្តាប់សក្ខីកម្មសាក្សីរូបនេះក៏ដោយ។ ហេតុដូច្នេះ អង្គជំនុំជម្រះយល់ស្របទទួលតាមសំណើសុំនេះ ហើយសូមប្រគល់វេទិកាជូនទៅភាគីសហព្រះរាជអាជ្ញា ដើម្បីតាំងសំណួរដេញដោលចំពោះសាក្សីរូបនេះ មុនភាគីដទៃទៀតនៃរឿងក្តី។

សូមអញ្ជើញ តំណាងសហព្រះរាជអាជ្ញា!

[០៩:២៦:២៧]

**លោក ឌេល លីសាក់៖**

សូមអរគុណ លោកប្រធាន។ ជម្រាបសួរលោក លោកស្រីចៅក្រម មេធាវីការពារក្តី។

**ការតាំងសំណួរដោយសហព្រះរាជអាជ្ញា**

**សួរដោយលោក ឌេល លីសាក់៖**

**ស៖** លោកស្រីសាក្សី ខ្ញុំឈ្មោះ លីសាក់។ ខ្ញុំមានសំណួរមួយចំនួនសួរទៅលោកស្រីនៅព្រឹកនេះ។ ខ្ញុំសូមចាប់ផ្តើមសួរថា តើលោកស្រីរស់នៅឯណាដែរ នៅពេលដើមរយៈពេលដំបូងនៃរបបខ្មែរក្រហម គឺចាប់ពីថ្ងៃ១៧ មេសា ១៩៧៥។ លោកស្រីរស់នៅឯណាដែរ?

**លោកស្រី វង សារុន៖**

**ឆ៖** គិតត្រឹមថ្ងៃ០៧ មេសា ១៩៧៥ ខ្លួនខ្ញុំបានចូលពន្ធនាគារ។ ជាប់គុក និយាយឲ្យខ្លី។

**ស៖** តើប្រាកដទេដែលថា លោកស្រីជាប់គុកនៅចាប់ពីថ្ងៃ១៧ មេសា ១៩៧៥? លោកស្រីពេលនុ៎ង លោកស្រីជាប់នៅគុកណាដែរ?

**ឆ៖** ខ្ញុំជាប់គុកនៅគុកក្រាំងតាចាន់ ឃុំសំរោង ស្រុកត្រាំកក់ ខេត្តតាកែវ។

**ស៖** បាទ ខ្ញុំនឹងសួរនៅពេលក្រោយបន្តិច អំពីថ្ងៃខែឆ្នាំនុ៎ង ដែលលោកស្រីជាប់គុកហ្នឹង។ សូមលោកស្រីជម្រាបអង្គជំនុំជម្រះមើល៍ នៅពេលដែល -- មុនពេលគេចាប់ខ្លួនបញ្ជូនទៅក្រាំងតាចាន់ហ្នឹង

តើលោកស្រីរស់នៅទីកន្លែងណាដែរ? ហើយជម្រាបអំពីពេលវេលាផង?

**ឆ៖** ចាស មុនគេចាប់បញ្ជូនខ្ញុំមកគុកក្រាំងតាចាន់ គឺខ្ញុំគេផ្លាស់ពីកន្លែងត្រាំកក់ -- កន្លែងៗ កន្លែងត្រាំកក់ហ្នឹង ជាមេធំជាងគេ នៅបន្ទាប់មក បានគេបញ្ជូនខ្ញុំមកភូមិចានទាប ឃុំត្រពាំងធំ ស្រុកត្រាំកក់ ខេត្តតាកែវ។

**សៈ** មុនពេលគេចាប់ខ្លួនលោកស្រី ហើយបញ្ជូនទៅក្រាំងតាចាន់ តើលោកស្រីធ្លាប់បានធ្វើជាពេទ្យនៅមន្ទីរពេទ្យហៅថា មន្ទីរពេទ្យ២២ ដែរទេ?

**ឆ៖** ចាស ខ្ញុំធ្លាប់ជាបុគ្គលិកនៅពេទ្យ ម-២២។ ក្រោយពេលដែលបែក៧៥ គេបញ្ជូនឲ្យខ្ញុំមកនៅស្រុកត្រាំកក់ហ្នឹង ដូចពាក្យខ្ញុំនិយាយខាងដើម ភូមិចានទាប។

[០៩:២៩:៤៥]

**សៈ** តើលោកស្រីធ្វើការនៅមន្ទីរពេទ្យ២២ហ្នឹង អស់រយៈពេលប៉ុន្មានដែរ?

**ឆ៖** ខ្ញុំហាក់ដូចជាស្រពេចស្រពិលក្រោយពីគេផ្លាស់ឲ្យខ្ញុំទៅហ្នឹង មិនដឹងថាមុនរំដោះ ៧មករា ៧៥ ហ្នឹង ហាក់ដូចជាបីបួនខែ។ ហ្នឹងខ្ញុំស្រពេចស្រពិលមិនដឹងច្បាស់។

**សៈ** តើមន្ទីរពេទ្យ២២ ស្ថិតនៅកន្លែងណាដែរ?

**ឆ៖** កាលមុនទៅវាយរំដោះបានមុន ១៧ (១៩)៧៥ ហ្នឹង។ ខ្ញុំហាក់ដូចភ្លេចកន្លែងហើយ ដូចថា ភូមិ -- ភ្លេចកន្លែង។ ហើយបានគេបញ្ជូនមកឲ្យនៅខេត្ត មន្ទីរពេទ្យខេត្តតាកែវ ហ្នឹងចាំ។ ពេលគ្រាន់តែបែកភ្លាមដូរឲ្យមកនៅហ្នឹង ចាស។

**សៈ** តើលោកស្រីអាចនៅចាំបានថា តើមន្ទីរពេទ្យ២២ ស្ថិតនៅក្នុងស្រុកត្រាំកក់ ឬក៏នៅត្រង់ផ្នែកណាមួយនៃទឹកដីខេត្តតាកែវ?

**ឆ៖** បើខ្ញុំមិនច្រឡំ មន្ទីរពេទ្យហ្នឹងនៅជិតមន្ទីរពេទ្យត្រពាំងគល់ ស្រុកត្រាំកក់ ខេត្តតាកែវដែរ។

**សៈ** តើលោកស្រីអាចជម្រាបជូនអង្គជំនុំជម្រះថា មន្ទីរពេទ្យ២២ ជាប្រភេទមន្ទីរពេទ្យយ៉ាងម៉េចដែរ? ជាមន្ទីរពេទ្យស្រុក ឬមន្ទីរតំបន់ ឬមន្ទីរពេទ្យភូមិភាគ ឬក៏ជាមន្ទីរពេទ្យយោធា?

**ឆ៖** មន្ទីរពេទ្យ២២ ជាមន្ទីរពេទ្យភូមិភាគនិរតី តែផ្នែកកងទ័ព។

**សៈ** លោកស្រីចាំថាអ្នកណាជាប្រធានមន្ទីរពេទ្យ២២ នៅពេលដែលលោកស្រីធ្វើការនៅទីនោះ?

**ឆ៖** ប្រធានពេទ្យឈ្មោះ កង តែខ្ញុំអត់ដឹងថាជីតាឈ្មោះអីទេ។

[០៩:៣៣:៣១]

**ស៖** លោកស្រីនៅចាំបានទេថា ហេតុអ្វីបានជាគេចាត់តាំងលោកស្រីឲ្យទៅធ្វើជាពេទ្យនៅមន្ទីរពេទ្យ២២?

**ឆ៖** ខ្ញុំនៅចាំបានដោយខ្ញុំមានប្ដី។ គាត់ធ្វើពេទ្យ អ៊ីចឹង គេឲ្យខ្ញុំទៅនៅជាមួយប្ដី។

**ស៖** ខ្ញុំសុំសួរសំណួរមួយចំនួនតូចទាក់ទងទៅនឹងប្ដីរបស់លោកស្រី។ លោកស្រីរៀបការនៅពេលណាដែរ? នៅឆ្នាំណាដែរ?

**ឆ៖** ខ្ញុំរៀបការនៅឆ្នាំ១៩៧៣។

**ស៖** នៅពេលដែលលោកស្រីរៀបការរួចហើយហ្នឹង តើលោកស្រីរស់នៅទីណាជាមួយនឹងប្ដីរបស់លោកស្រី?

**ឆ៖** ពេលដែលខ្ញុំរៀបការហើយ ដំបូងគឺខ្ញុំរស់នៅភូមិព្រៃខ្មៅ ស្រុកឈូក ខេត្តកំពត។

**ស៖** តើប្ដីលោកស្រីមកពីណាដែរ មកពីភូមិឃុំស្រុកតែមួយដូចលោកស្រីដែរ ឬក៏អត់ទេ?

**ឆ៖** ចាស ប្ដីខ្ញុំដើមកំណើតនៅភូមិធំ គេហៅ តន់ហាន់ហ្នឹង ស្រុកកំពង់ត្រាច ខេត្តកំពត។

**ស៖** តើប្ដីលោកស្រីជាខ្មែរកម្ពុជាក្រោម ឬមិនមែនទេ?

**ឆ៖** ចាស ប្ដីខ្ញុំខ្មែរសុទ្ធ ប៉ុន្តែគាត់នៅតន់ហាន់ ជាយព្រំដែនវៀតណាម។

**ស៖** មុនពេលលោកស្រីរៀបការ តើប្ដីលោកស្រីធ្លាប់បានរស់នៅក្នុងប្រទេសវៀតណាមក្នុងមួយរយៈពេលណាដែរទេ?

**ឆ៖** ចាស មុនខ្ញុំរៀបការប្ដីខ្ញុំមកខ្មែរ ប៉ុន្តែមកពីអី គេថាមកពីហាណូយនោះ។ ខ្មែរមកពីហាណូយចូលធ្វើការហ្នឹង។

**ស៖** ហេតុអ្វីបានជាគេហៅគាត់ថា "ជាខ្មែរមកពីហាណូយ" លោកស្រីដឹងទេ?

[០៩:៣៧:១០]

**ឆ៖** រឿងនេះ ខ្ញុំមិនដឹងជាពិតប្រាកដទេ ប៉ុន្តែគាត់ប្រាប់ខ្ញុំថា គាត់កាលពីសម័យឥស្សរៈគាត់ធ្វើពេទ្យ ដល់ពេលគេចប់សង្គ្រាម គេក៏ប្រមូលទៅវៀតណាមដើម្បីឲ្យធ្វើពេទ្យបន្ត។

**ស៖** នៅពេលដែលលោកស្រីរៀបការជាមួយប្ដីលោកស្រី តើពិធីរៀបការហ្នឹងធ្វើឡើងតាមបែបប្រពៃណីដែរ ឬក៏ជាការរៀបការមួយដែលអង្គការរៀបចំឲ្យ?

**ឆ៖** ចាស រៀបការខ្ញុំតាមរូបភាពអង្គការរៀបចំឲ្យ។

**ស៖** តើលោកស្រីអាចជម្រាបជូនអង្គជំនុំជម្រះបានទេ ថាប្ដីរបស់លោកស្រីមានតួនាទីអ្វីដែរ

នៅក្នុងរបបខ្មែរក្រហម គឺគិតពីខែមេសា ១៩៧៥ ដល់ខែមករា ១៩៧៩?

**ឆ៖** ចាស គាត់មាននាទីផ្នែកវះកាត់ ព្យាបាលជំងឺតែប៉ុណ្ណឹង។

**ស៖** គាត់ធ្វើការជាពេទ្យផ្នែកវះកាត់ហ្នឹងនៅឯណាដែរ?

**ឆ៖** គាត់ធ្វើការផ្នែកវះកាត់នៅម-២២។

**ស៖** ដូច្នេះ លោកស្រី និងប្ដីរបស់លោកស្រី គឺថាធ្វើការនៅមន្ទីរពេទ្យ ម-២២ ដូចគ្នា។ ត្រឹមត្រូវ ឬក៏អត់ទេ?

**ឆ៖** ចាស ត្រឹមត្រូវ។

[០៩:៣៩:៤២]

**ស៖** តើប្ដីរបស់លោកស្រីសព្វថ្ងៃនេះ នៅរស់រានដែរទេ?

**ឆ៖** ចាស គាត់ស្លាប់ហើយ ដោយពួក ប៉ុល ពត ចាប់គាត់យកទៅដាក់គុកក្រាំងតាចាន់ កន្លែងដែលខ្ញុំជាប់ឃុំឃាំង។

**ស៖** តើគាត់ស្លាប់នៅគុកក្រាំងតាចាន់ គាត់រស់រានមានជីវិតក្រោយពីរបបខ្មែរក្រហមហើយទើបបានស្លាប់?

**ឆ៖** គាត់ស្លាប់នៅពេលដែលគេចាប់គាត់យកទៅបានរយៈពេលមួយអាទិត្យ គេយកគាត់ទៅសម្លាប់នៅក្រាំងតាចាន់ហ្នឹងតែម្ដង កន្លែងចាប់ហ្នឹង។

**ស៖** ខ្ញុំនឹងត្រឡប់មកសួរសំណួរមួយចំនួន។ ប្ដីរបស់លោកស្រីបើខ្ញុំយល់មិនច្រឡំទេគឺគាត់មានឈ្មោះបដិវត្តន៍ហៅថា សែត អ៊ីចឹងឬក៏អត់ទេលោកស្រី?

**ឆ៖** ចាស គាត់ឈ្មោះសែត ឈ្មោះក្រៅ។

**ស៖** សូមលោកស្រីជម្រាបឲ្យបាន -- ឈ្មោះគាត់ឲ្យបានពេញលេញទាំងនាមត្រកូល នាមខ្លួនផងបានទេ?

**ឆ៖** ប្ដីខ្ញុំឈ្មោះ ប្រាជ្ញ សុន ឈ្មោះក្រៅគេហៅគាត់ សែត។

[០៩:៤២:០៣]

**ស៖** សូមអរគុណ។ ខ្ញុំសូមសួរសំណួរមួយចំនួនពាក់ព័ន្ធទៅនឹងការចាប់ខ្លួនលោកស្រី និងព្រឹត្តិការណ៍ក្រោយចាប់ខ្លួនលោកស្រី។ តើលោកស្រីនៅចាំទេថា មានអ្វីកើតឡើងនៅពេលដែលគេ នៅពេលដែលខ្មែរក្រហមចាប់ខ្លួនលោកស្រី?

**ឆ៖** ខ្ញុំសូមឲ្យបញ្ជាក់បន្ថិចថា ហេតុការណ៍កើតឡើងហ្នឹង ហេតុការណ៍អ្វីខ្លះដែលចង់ឲ្យខ្ញុំប្រាប់?

**ស៖** លោកស្រីបានបញ្ជាក់ថាលោកស្រីត្រូវបានគេឃុំខ្លួននៅគុកក្រាំងតាចាន់។ អ្វីដែលខ្ញុំចង់ដឹងនោះគឺ តើគេបញ្ជូនខ្លួនទៅក្រាំងតាចាន់ដោយរបៀបណា? គេចាប់ខ្លួនបញ្ជូនទៅឬក៏យ៉ាងម៉េច? ហើយបើចាប់ខ្លួន តើអ្នកណាជាអ្នកចាប់ខ្លួនលោកស្រីបញ្ជូនទៅគុកក្រាំងតាចាន់?

**ឆ៖** ចាស ពេលដែលគេយកប្ដីខ្ញុំទៅបាត់ហើយ គេឲ្យខ្ញុំនៅសហករណ៍ចានទាប ផ្នែកស្ត្រីមេម៉ាយ គេឲ្យខ្ញុំលើកប្រឡាយ លើកទំនប់។ ពេលដែលថ្ងៃត្រង់ខ្ញុំវិលមកវិញ ស្រាប់តែឃើញឈ្លបពីរនាក់គេមកហៅខ្ញុំដោយមានប្រាប់ថាគេឲ្យខ្ញុំហ្នឹងទៅផ្ទះវិញ ហើយខ្ញុំក៏សុំគេថា ខ្ញុំសុំទៅយកអីវ៉ាន់សិន។ គេថា មិនបាច់ទៅយកទេ ចាំគេផ្ញើឲ្យក្រោយ។ ពេលនោះខ្ញុំមិនមែនមានតែម្នាក់ឯងទេ ខ្ញុំមានកូនស្រីខ្ញុំម្នាក់ អាយុជាងមួយខួបទៅធ្វើកងចល័តហ្នឹង អត់មានខោអាវអីច្រើនទេ មានតែខោអាវ មួយកំប្លេ ពីរនាក់ម៉ែកូន សុទ្ធតែដាច់។ គេប្រើយើងមិនដឹងថាយើងហ្នឹង អត់អាវ អត់ខោ ហូបបបរ មួយវែក កូនតូចខ្ញុំយំរាល់ថ្ងៃ ធ្វើឲ្យ ខ្ញុំនឹកឃើញដល់ប្ដីខ្ញុំមិនដឹងថាគេយកគាត់ធ្វើបាបប៉ុន្មាន។ គ្រាន់តែគេប្រាប់ថាឲ្យទៅផ្ទះ ខ្ញុំរន្ធត់ចិត្ត គិតថាខ្ញុំពិតជាគេយកទៅដាក់គុកហើយ ព្រោះគេចាប់ប្ដីខ្ញុំហើយ។ ប្រធាននារីហ្នឹង ខ្ញុំអត់ចាំឈ្មោះទេ គ្រាន់តែគេប្រាប់ថា បងឯងមិនបាច់កុហកខ្ញុំទេ បើថាយកខ្ញុំទៅណាប្រាប់ខ្ញុំឲ្យត្រង់ទៅព្រោះអីខ្ញុំបែកម៉ែឪខ្ញុំមិនដែលបានជួបមុខទេ។ មានតែកូន មានតែប្ដី ឥឡូវគេយកប្ដីទៅបាត់ហើយនៅតែខ្ញុំ ហើយកូនមួយ អាវមិនអាវ ខោមិនខោ មិនដែលអ្នកណាគេចែកឲ្យខ្ញុំទេ។ ហើយបានគេនាំខ្ញុំមកដល់ស្ពានមួយគេហៅថា "ស្ពានត្រពាំងធំ"។ គេថា អឺ! នៅហ្នឹងសិនហើយ អ៊ីឯងចាំមនុស្សម្នាក់ទៀត។ ដល់មួយសន្ទុះក្រោយស្រាប់ឃើញនារីម្នាក់មានកូនង៉ែតបីខែ។ នារីហ្នឹងខ្ញុំស្គាល់ គឺឈ្មោះ ហាន វានៅធ្វើពេទ្យនៅម-២២ ជាមួយខ្ញុំ។ គ្រាន់តែឃើញភ្លាម ហាន រត់ឱបខ្ញុំប្រាប់ថា បងរុន អើយយើងជាប់គុកហើយ។ ខ្ញុំពេលហ្នឹងយំក៏អត់ចេញ និយាយក៏អត់កើត ខ្ញុំដូចថាឡប់ រកផ្លូវទៅណាក៏អត់ឃើញដែរ។

[០៩:៤៦:១៧]

បន្ទាប់មកទៀត គេបណ្ដើរមកឲ្យឆ្ងាយ ប្រហែលជា៤-៥គីឡូដី ដល់មាត់ត្រពាំងមួយ។ ឈ្លបពីរនាក់ហ្នឹងគេឲ្យខ្ញុំឈប់ ហើយគេឆែកឆេរខ្លួនថា ខ្ញុំហ្នឹងមានស្អីលាក់នៅនឹងខ្លួន។ តាមការពិតខ្លួនខ្ញុំមានតែខោអាវមួយចង្កេះ កូនក៏ខោអាវមួយចង្កេះដែរ ព្រោះអីគេឲ្យមករែកដីប្រឡាយ អត់មានអីតាមខ្លួនទេ ព្រោះអីខ្ញុំ ម៉ែឪខ្ញុំអត់មាននៅទីនោះណា ខ្ញុំជាអ្នកធ្វើការ ប៉ុន្តែគេចាត់ទុកខ្ញុំជាអនុប្រជាជន ក្រោមប្រជា-

ជនគេអ្នកនៅហ្នឹងទៀត ហេតុនេះគេមិនបានចែកអាវ ចែកខោឲ្យខ្ញុំស្លៀកពាក់ទេ។

ដល់ពេលសួរនៅមាត់ត្រពាំងហ្នឹង ហើយគេក៏នាំខ្ញុំមកដីទាបប្រហែលៗជាង១០០ម៉ែត្រពីមាត់ត្រពាំងហ្នឹង ឃើញមានលួសបន្លាមួយ របងព័ទ្ធលួសបន្លា តែរបងហ្នឹងអត់មានទ្វារបិទទេ គេក៏បណ្ដើរខ្ញុំចូលដល់ក្នុងហ្នឹង។ ប្រហែលជា៥០ម៉ែត្រទៀតដល់មានរបងបន្លាមួយទៀត តែមានទ្វារបិទ។ គេក៏នាំខ្ញុំចូលមក ខ្ញុំគ្រាន់តែឃើញប៉ុណ្ណឹង ខ្ញុំនឹកឃើញថា ជីវិតខ្ញុំហ្នឹងស្លាប់ហើយ កូនខ្ញុំឱបខ្ញុំយំ ខ្ញុំក៏ឱបកូនយំ។ ចូលបានឆ្លងមាត់ទ្វារហ្នឹងបន្តិច ឃើញមានរោងគេវែងៗ បាំងជញ្ជាំងក្ដារ ឈ្លបក៏គេនាំខ្ញុំចូលដល់អ៊ីចឹងមានៗមេគុកគេ គេមកចាក់សោរ ហើយគេឲ្យខ្ញុំចូលទៅក្នុងហ្នឹង។ ចូលក្នុងហ្នឹងគេឲ្យខ្ញុំអង្គុយសណ្ដូកជើង ហើយគេយកអាកងអីៗរាងមូលអ៊ីចឹង មានប្រហោងសម្រាប់ស៊កដែក នៅគុកក្រាំងតាចាន់ឥឡូវនេះនៅតែមានភស្តុតាងហ្នឹងដដែល។ គេស៊កអាកងហ្នឹងជាប់ជើងហើយ គេដាក់ខ្នោះដៃខ្ញុំទៀត ដល់ហើយគេនិយាយបញ្ឈឺចិត្តខ្ញុំថា ហ្នឹងហើយប្រពន្ធ តាសែត ខ្ញុំអត់បានឆ្លើយគេទេ ខ្ញុំឆ្អែតចិត្តពេក ខ្ញុំនឹកថាជីវិតខ្ញុំ ប្ដីខ្ញុំស្លាប់ ក៏ខ្ញុំស្លាប់ដែរ ស្លាប់ជាមួយកូននៅទីហ្នឹងហើយ។

[០៩:៤៨:៤១]

ធ្វើឲ្យខ្ញុំលែងគិតអីកើតទាំងអស់។ រហូតដល់គេដាក់គុកខ្ញុំក្នុងផ្ទះ គេឲ្យបបរមួយវែក មានអង្ករមួយគ្រាប់ៗទេ សម្លព្រលិតអត់មានបង់អំបិលទេ ឲ្យកូនខ្ញុំមួយវែក ខ្ញុំមួយវែក ខ្ញុំអត់បានហូបបបរបីថ្ងៃគត់។ ខ្ញុំសុខចិត្តឲ្យកូនខ្ញុំហូប ព្រោះអីវាយំ ដល់ពេលវាយំគេចូលមកវ៉ៃ ព្រោះអីវាក្មេង វាអត់ដឹង តែវាឃ្លានវាយំហើយ បើអ៊ីចឹងគេមកវ៉ៃកូននៅនឹងមុខខ្ញុំ ខ្ញុំជាម្ដាយខ្ញុំចង់ប្រេះទ្រូងហើយ ដូច្នេះ ខ្ញុំត្រូវបង្អត់ខ្លួនឯង។ តែខ្ញុំហាក់ដូចជាមានដែរ យាយមួយគាត់ដាំបបរឈ្មោះ យាយញ៉ៃ។ យាយហ្នឹងគាត់ជាប់គុកមួយពូជ គាត់ឲ្យក្នុងមួយពេលហ្នឹងគាត់ឲ្យអំបិលខ្ញុំពីរបីគ្រាប់ និងដូងយើង អាដូងទុំហ្នឹងប្រហែលពីរផ្ទាប់អ៊ីចឹង ព្រោះអីគាត់អត់ឃើញខ្ញុំហូបបបរសោះ រយៈពេលបីថ្ងៃ។

បន្ទាប់មកទៀត គាត់ថាបើ អ៊ីរុន ឯងមិនហូប អ៊ីរុន ឯងពិតជាស្លាប់នឹងអត់បាយហើយ តស៊ូឡើង គាត់និយាយអ៊ីចឹង ព្រោះអីគាត់អ្នកជាប់គុកដែរ។ តស៊ូឡើង គេក៏ធ្វើបាបខ្ញុំដូច អ៊ីរុនឯងដែរ។ ដល់ពេលហ្នឹងខ្ញុំចាប់ផ្ដើមហូបតិចៗទៅ។ ដល់រយៈពេលប្រាំពីរថ្ងៃ គេមកបណ្ដើរខ្ញុំទៅសួរចម្លើយ ពេលដែលខ្ញុំចេញផុតតែពីផ្ទះ ខ្ញុំដួលព្រូស ដួលពីរបីជំហានដួលៗ គេយារដៃវ៉ៃ ចង់វ៉ៃអ៊ីចឹង ខ្ញុំខំស្រវាងើបតតេះតតះដើរទៅអត់មានកម្លាំង ហើយជើងខ្ញុំត្រូវដែកដាក់កង ដាក់ហ្នឹងវាស្ពឹក ដើរអត់ដឹងជើង។ ទៅដល់កន្លែងគេសួរចម្លើយខ្ញុំ គេឲ្យខ្ញុំអង្គុយលើអាកៅអីដែកប្លូនជ្រុង អ្នកសួរគេមាន។

ឈប់មួយភ្លែតសិន ខ្ញុំអត់មានកម្លាំងនិយាយទេ ខ្ញុំនឹកឃើញរឿងនេះ។

*(សម្រាករយៈពេលខ្លី - សាក្សីយំ)*

[០៩:៥១:៤៧]

**ប្រធានអង្គជំនុំ៖**

សហព្រះរាជអាជ្ញារងផ្អាកបន្តិចសិន!

បាទ អង្គុយចុះសិនចុះ!

*(សម្រាករយៈពេលខ្លី)*

*(ចៅក្រមពិភាក្សាគ្នា)*

[០៩:៥៤:០៥]

**ប្រធានអង្គជំនុំ៖**

បាទ ឥឡូវនេះ គប្បីសម្រាកសិនទៅ!

អង្គជំនុំជម្រះប្រកាសសម្រាកចាប់ពេលនេះទៅ រហូតដល់ម៉ោងដប់ ដប់នាទី សូមអញ្ជើញចូលវិញ ដើម្បីបន្តកិច្ចដំណើរការសវនាការ ហើយមន្ត្រីរដ្ឋបាលតុលាការសម្របសម្រួលផ្តល់កន្លែងសម្រាកនៅបន្ទប់រង់ចាំសម្រាប់សាក្សី និងអ្នកជំនាញ ដល់សាក្សីរូបនេះ រួមទាំងបុគ្គលិកអង្គការ ធី.ភី.អូ ផង ហើយឱ្យអញ្ជើញគាត់ត្រឡប់មកកាន់កន្លែងផ្តល់សក្ខីនៅបន្ទប់សវនាការនេះវិញនៅវេលាម៉ោងដប់ និង ដប់នាទី។

បាទ សម្រាកចុះ!

*(សវនាការសម្រាកពីម៉ោង ៩:៥៤ នាទី ដល់ម៉ោង ១០:១៣ នាទី)*

[១០:១៣:០៨]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ និងផ្តល់វេទិកាជូនទៅតំណាងសហព្រះរាជអាជ្ញាអន្តរជាតិដើម្បីបន្តការតាំងសំណួរចំពោះសាក្សី។

**លោក ឌេល លីសាក់៖**

សូមអរគុណលោកប្រធាន។

**សួរដោយលោក ឌេល លីសាក់៖**

**ស៖** សូមអរគុណលោកស្រីសាក្សី។ ខ្ញុំដឹងថាមានអារម្មណ៍តានតឹងនូវអ្វីដែលកើតឡើងចំពោះលោកស្រី ប៉ុន្តែខ្ញុំនឹងត្រឡប់មកសួរពាក់ព័ន្ធទៅនឹងសួរចម្លើយលោកស្រី។ ប៉ុន្តែឥឡូវនេះ ខ្ញុំសូមសួរឲ្យបានលម្អិតបន្តិចចំពោះរឿងរ៉ាវដែលលោកស្រីទើបតែជម្រាបជូនតុលាការអម្បាញ់មិញ។ លោកស្រីបានបញ្ជាក់ថា ក្រោយពេលប្តីលោកស្រីគេចាប់ទៅ គេបញ្ជូនលោកស្រីទៅធ្វើការនៅកងមេម៉ាយ។ តើលោកស្រីអាចជម្រាបជូនអង្គជំនុំជម្រះបានទេ លោកស្រីធ្វើការនៅកងមេម៉ាយអស់រយៈពេលប៉ុន្មានដែរ មុនពេលគេចាប់ខ្លួន? ឬក៏ថារយៈពេលប៉ុន្មានដែរ គិតពីពេលគេចាប់ខ្លួនប្តីលោកស្រី និងមកដល់ពេលគេចាប់ខ្លួនលោកស្រីបញ្ជូនទៅគុកក្រាំងតាចាន់?

[១០:១៥:៤៥]

**លោកស្រី វង សារុន៖**

**ឆ៖** ប្តីខ្ញុំគេបញ្ជូនទៅខែស្ទូង។ ដល់ពេលគេចាប់គាត់ទៅ រយៈពេលខែច្រូតហើយ គេឲ្យយើងច្រូតហើយហ្នឹង ធ្លាក់ទឹកភ្លៀង គេឲ្យយើងទៅៗលើកភ្លឺប្រឡាយ ភ្លឺភ្លោះពេលហ្នឹង។ អាហ្នឹងពេលហ្នឹងគេចាប់ខ្ញុំ ប៉ុន្តែខ្ញុំអត់បានគិតថារយៈពេលប៉ុន្មានខែទេ គ្រាន់ចំណាំថាកាលខែស្ទូងមកដល់ខែច្រូត។

**ស៖** អំឡុងពេល ចន្លោះពីពេលចាប់ខ្លួនប្តីលោកស្រី និងចាប់ខ្លួនលោកស្រី តើវាមានរយៈពេលតែពីរបីសប្តាហ៍ទេ ឬក៏វាមានរយៈពេលច្រើនខែដែរ?

**ឆ៖** បើខ្ញុំចាំអត់ភ្លេច ពេលដែលគេចាប់ប្តីខ្ញុំ កូនស្រីខ្ញុំឈឺខ្លាំង។ ពេលដែលឈឺខ្លាំងហ្នឹង អត់អីមើលកូនៗ។ គេថាមិនបាច់នៅមើលកូនទេ ឲ្យយាយៗមើលទៅ យើងហ្នឹងទៅធ្វើការ។ ពេលនោះ កូនខ្ញុំទើបតែជាងមួយខួប បានសេចក្តីថាចេះដើរតេះតះៗហ្នឹង។ ហើយអីចឹង ចន្លោះពេលដែលគេចាប់គាត់មកហ្នឹង ខ្ញុំគិតថាមិនយូរប៉ុន្មាន ព្រោះអីកូនខ្ញុំឈឺៗ -- អើ យើងច្រូតបានពាក់កណ្តាល កណ្តាលច្រូតហ្នឹងជិតហើយ របៀបថាច្រូតជិតហើយ ប៉ុណ្ណឹង។ ខ្ញុំមិនបានគិតថាវាប៉ុន្មានខែទេ ព្រោះអី វារៀងឆាប់ដែររយៈពេលច្រូតបានពាក់កណ្តាលហើយ បានកូនខ្ញុំឈឺ គេបញ្ជូនទៅ ថាឲ្យទៅមើលពេទ្យណា ដល់ហើយភូមិគេអត់ឲ្យទៅ។

[១០:១៧:២៧]

**ស៖** សូមអរគុណលោកស្រីសាក្សី។ លោកស្រីក៏បានជម្រាបផងដែរ ថានៅពេលដែលគេចាប់ខ្លួនលោកស្រី កូនស្រីអាយុ១ឆ្នាំរបស់លោកស្រីនៅជាមួយលោកស្រី។ លោកស្រីមានកូនក្រៅពីកូនស្រី

ម្នាក់នេះទៀតទេ ហើយបើមាន តើមានអ្វីកើតឡើងចំពោះកូនៗទាំងនោះដែរទេ?

**ឆ៖** ពេលដែលគេចាប់ខ្ញុំមក គឺខ្ញុំមានតែ -- ខ្ញុំមានកូនពីរ តែអាមួយទៀតតូចស្លាប់។ ចាស អាមួយទៀត កូនក្រោយ បានជាងខួបហ្នឹង គេយកប្ដីទៅសម្លាប់ទៅ។ ដល់ពេលមកពីរត់នេះ បានខ្ញុំមានគ្រួសារក្រោយ មានកូនបីទៀត។

**ស៖** កូនលោកស្រីរបស់លោកស្រីដែលស្លាប់ទៅនោះ ថាកូននេះ ស្លាប់មុនពេលលោកស្រីទៅក្រាំងតាចាន់ ឬក៏ស្លាប់នៅឯក្រាំងតាចាន់ដែរ?

**ឆ៖** ស្លាប់មុន។

**ស៖** តើកូនដែលស្លាប់មុនពេលដែលបញ្ជូនទៅក្រាំងតាចាន់ហ្នឹងមានអាយុប៉ុន្មានដែរ? ពេលស្លាប់ជាកូនប្រុស ឬក៏ជាកូនស្រី? ហើយស្លាប់ដោយសារមូលហេតុអ្វីដែរ?

[១០:១៩:០៦]

**ឆ៖** កូនខ្ញុំប្រុស។ ស្លាប់ដោយមូលហេតុ ពេលយើងសម្រាលអត់មានបានសម្រាលត្រឹមត្រូវ វាហើមរនាំងខួរក្បាល អាហ្នឹងប្ដីខ្ញុំគាត់ប្រាប់ថាអ៊ីចឹង បានវាស្លាប់។

**លោក ខេល លីសាក់៖**

សូមអរគុណលោកស្រី។ លោកប្រធាន ខ្ញុំសូមការអនុញ្ញាតពីអង្គជំនុំជម្រះផ្ដល់ជូនសាក្សីនូវឯកសារបញ្ជីអ្នកទោសគុកក្រាំងតាចាន់ ដើម្បីជួយទៅដល់សាក្សី ថាតើគាត់អាចនឹកឃើញដល់ពេលវេលាដែលគេបញ្ជូនគាត់ទៅក្រាំងតាចាន់បាន ឬក៏អត់ គឺឯកសារ E3/4164 – E3/4164។

បាទ សូមការអនុញ្ញាត ដើម្បីបង្ហាញឯកសារនេះ ទៅសាក្សី។

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះអនុញ្ញាត!

**សួរដោយលោក ខេល លីសាក់៖**

**ស៖** លោកស្រីសាក្សី ឯកសារដែលផ្ដល់ជូនទៅលោកស្រីនេះ គឺជាបញ្ជីអ្នកទោស និយាយអំពីប្រវត្តិរូបសង្ខេបរបស់អ្នកទោសនៅស្រុក -- នៅមន្ទីរអប់រំស្រុកត្រាំកក់។ អ្នកទោសទី២ លេខរៀងទី២ នៅលើបញ្ជីនេះ ដើម្បីជួយបញ្ជាក់ឲ្យបានស្រួលទៅដល់លោកស្រី គឺឃើញមានឈ្មោះលោកស្រីៗផ្ទាល់ឈ្មោះ វង សារុន ជាស្រី អាយុ២៧ឆ្នាំ មកពីភូមិខ្ជាយ ឃុំដងទង់ ស្រុកទូកមាស ខេត្តកំពត រៀបការជាមួយប្ដីឈ្មោះ ប្រាជ្ញ សែត។ ហើយបញ្ជីនេះ គឺនិយាយអំពីពេលវេលាដែលលោកស្រីទៅដល់គុកក្រាំង

តាចាន់ នៅថ្ងៃទី២៣ ខែឧសភា ១៩៧៧។ តើនេះវាអាចជួយរំឭកដល់ការចងចាំរបស់លោកស្រី នៅពេលដែលគេចាប់លោកស្រីបញ្ជូនទៅគុកក្រាំងតាចាន់ គឺនៅក្នុងអំឡុងខែឧសភា ១៩៧៧? តើវាជួយរំឭកដល់ការចងចាំរបស់លោកស្រីដែរទេ?

[១០:២១:៥៥]

**ចៅក្រម ក្លូឌា ហ្វេនស័៖**

នៅពេលលោកស្រីសាក្សីកំពុងតែគិតនេះ តើ -- លោកតំណាងសហព្រះរាជអាជ្ញាសូមផ្តល់ ERN ផង។

**សួរដោយលោក ឌេល លីសាក់៖**

គឺ ERN -- មនុស្សទី២ អ្នកទោសទី២ លេខរៀងទី២។ គឺ ERN ត្រង់អង់គ្លេស 00973147, បារាំង 00937104 ហើយខ្មែរ ដែលមានចំនួនពីរទំព័រ គឺនៅលើឯកសារនេះ ស្រាប់ហើយ គឺអង់គ្លេស សូមបញ្ជាក់ម្តងទៀត -- ឯកសារនេះ គឺ E3/4164។

**ស៖** លោកស្រីសាក្សី តើនេះជួយរំឭកដល់ការចងចាំរបស់លោកស្រីបានទេ នៅពេលដែលគេចាប់ខ្លួននិងបញ្ជូនលោកស្រីទៅគុកក្រាំងតាចាន់ គឺនៅអំឡុងខែឧសភា ឆ្នាំ១៩៧៧?

**លោកស្រី វង សារុន៖**

**ឆ៖** ចាស ខ្ញុំៗចងចាំបាន ប៉ុន្តែខ្ញុំមិនៗបាននិយាយ -- មិនបានសួរខ្ញុំថា តើខ្ញុំហ្នឹងនៅៗពេទ្យតាកែវដែរឬទេ។ អត់បានៗសួរខ្ញុំពីហ្នឹង ហេតុនេះ ខ្ញុំគិតរយៈពេលខ្ញុំធ្វើពេទ្យនៅពេលគេវាយបែកហើយហ្នឹង គេឲ្យយើងទៅនៅពេទ្យតាកែវៗ ទៅស្នួងពីរឆ្នាំ។ អ៊ីចឹងបានន័យថា ខ្ញុំពីរៗឆ្នាំដែរហើយ ខ្ញុំទៅស្នួងនៅខេត្តតាកែវ បានគេបញ្ជូនឲ្យខ្ញុំមកត្រាំកក់ ចាស។ ដោយអត់បានសួរខ្ញុំពីរយៈពេលនៅតាកែវ។

**ស៖** អ្នកទោសនៅខាងក្រោម មានលេខរៀងទី៣ នៅក្នុងបញ្ជីហ្នឹង គឺឈ្មោះ អ៊ុច ហាន អាយុ ២៦ឆ្នាំ ភេទស្រី មកពីភូមិត្រពាំងអង្រង ឃុំពាម ស្រុកកំពង់ត្រឡាចលើ កំពង់ឆ្នាំង។ តើឈ្មោះនេះជាឈ្មោះដែលលោកស្រីលើកឈ្មោះពីខាងដើម ដែលលោកស្រីបានជួប ហើយបញ្ជូនក្រាំងតាចាន់ជាមួយលោកស្រីដែរនោះ គឺឈ្មោះ ហាន ហ្នឹង ឬក៏យ៉ាងម៉េច?

[១០:២៤:៤៥]

**ឆ៖** ចាស ពិតប្រាកដហើយ តែខ្ញុំអត់ដឹងថា ដាក់នាមត្រកូលគេអីទេ ធ្លាប់តែហៅថា អ៊ីហានៗអ៊ីចឹង។

**សៈ** នៅជួរបន្ទាត់មួយគឺមានឈ្មោះរបស់ ហាន និងលោកស្រី បើមើលទំព័រទី២ទៅឃើញមានកូឡោនមួយហ្នឹងគឺបញ្ជាក់ថា លោកស្រីខ្លួនឯងផ្ទាល់ និងឈ្មោះ ហាន នេះត្រូវបានចាប់ខ្លួនដោយសារតែពាក់ព័ន្ធទៅនឹងចម្លើយរបស់ ហុង ហើយនិង ខន។ ខ្ញុំសួរសំណួរមួយចំនួនអំពីមនុស្សពីរនាក់ដែលគេលើកយកមកសំអាងនៅទីនេះ គឺឈ្មោះ ហង់ និង កង។

លោកស្រីបានបញ្ជាក់ហើយថា កង នេះគឺជាប្រធានមន្ទីរពេទ្យ២២។ លោកស្រីនៅចាំទេថា នៅពេលដែលលោកស្រីនៅមន្ទីរពេទ្យ២២ តើ កង នេះត្រូវបានគេចាប់ខ្លួននៅក្នុងពេលណាមួយដែរទេពេលលោកស្រីធ្វើការនៅមន្ទីរពេទ្យ២២?

**ឆះ** ចាស ពេលយប់មួយខ្ញុំគិតថា អត់ដឹងថ្ងៃណា គេហៅពេទ្យប្រជុំ។ ដល់ពេលពេទ្យប្រជុំតាកង ហ្នឹងគេប្រាប់ប្តីខ្ញុំ និងខ្ញុំ ប្រាប់ថា សែត ឯងត្រូវផ្លាស់ទៅនៅត្រាំកក់។ ហើយដល់តែប្រាប់ អ៊ីចឹងហើយ ចុះពីប្រជុំមកវិញ ឃើញឡាន ពីដើមគេហៅអាឡាំប៉ាតាកង់បីមកដឹកខ្ញុំ និងប្តីខ្ញុំចេញមកទាំងយប់ដល់ខ្ញុំដឹងថាទៅដល់ទីណាទេ។ ដល់ពេលភ្លឺឡើងបានខ្ញុំដឹងថា គេប្រាប់ថាហ្នឹងហើយត្រាំកក់ មន្ទីរស្រុកត្រាំកក់ ចាស។ ហើយទោះបីប្រាប់ខ្ញុំយ៉ាងណាក៏ខ្ញុំអត់ដឹងដែរ បើខ្ញុំអត់ដែលស្គាល់ស្រុកហ្នឹងផង ខ្ញុំអត់ដែលទៅនៅហ្នឹងផង។ អ៊ីចឹង វាមិនខុសនឹងមនុស្សម្នាក់ដែលអត់ដឹងអីសោះ ស្ថានភាពដីគេហ្នឹង។

ហើយក្រោយមក ខ្ញុំឮប្តីខ្ញុំប្រាប់ថា តាកង ហ្នឹងក៏គេចាប់ដែរ តែមិនដឹងចាប់ទៅណា។ ថ្ងៃយប់ហ្នឹង ខ្ញុំគិតថាមិនដឹងមានព្រឹត្តការណ៍អីខ្លះទេ បុគ្គលិកម-២២។ ខ្ញុំមើលឃើញដូចជាមានឡានធំដឹកបុគ្គលិក ម-២២ ចេញអស់ទាំងខ្លួនខ្ញុំ តែតាកងមួយ ខ្ញុំអត់ដឹងទេប្រធាន ព្រោះអីគេនៅឯណានោះ យើងអត់ដឹង ព្រោះអីខ្ញុំស្នាក់នៅជាមួយជិតបុគ្គលិកពេទ្យទាំងអស់។ ឃើញហៅគ្នាឡើងឡាន អាយ៉ូអាយ៉ាៗ ហាក់ដូចជាមានការសម្ងាត់អីមួយ។ ហ្នឹងខ្ញុំពេលក៏ចេញដឹកចេញ ដឹកចេញបុគ្គលិកពេទ្យ ហើយក៏ដឹកខ្ញុំហ្នឹងមកទាំងយប់ដែរ តែត្រង់ថា តាកង ហ្នឹង គេដឹកគាត់ចេញ តែក៏ខ្ញុំអត់បានដឹងដែរ តែដំណឹងថា តាកង គេក៏ចាប់ខ្លួនដែរ។ តែប៉ុណ្ណឹង។

[១០:២៨:៥២]

**សៈ** នៅក្នុងកិច្ចប្រជុំនៅឯមន្ទីរពេទ្យ២២ តើ កង មានបានប្រាប់លោកស្រី ឬក៏បុគ្គលិកពេទ្យដទៃទៀតថា ហេតុអ្វីបានជាគេត្រូវបញ្ជូនខ្លួនលោកស្រី ឬក៏បញ្ជូនខ្លួនបុគ្គលិកពេទ្យហ្នឹងទៅឯណានោះ?

**ឆះ** ប្រជុំហើយ អត់មានប្រាប់ថាអីទាំងអស់។ ប៉ុន្តែ ធម្មតាខ្ញុំហើយនិងបុគ្គលិកវានៅដេកជិតគ្នា ដល់ហើយ ឃើញឡាន ឡានអាឡានធំហ្នឹង គេមកហៅបុគ្គលិកឡើងព្រឹបៗទៅ។ ខ្ញុំគេហៅឲ្យឡើង

អាឡាំប៉ាតាកង់បីយើងកាលពីសង្គមចាស់ណ៎ា។ ពីរនាក់ប្ដីប្រពន្ធខ្ញុំឡើងមក។ ហើយព្រឹត្តការណ៍តទៀត គឺខ្ញុំអត់បានដឹង។

**ស៖** តើនៅមន្ទីរពេទ្យហ្នឹង បុគ្គលិកទាំងអស់ប្រហែលជាប៉ុន្មាននាក់ ធ្វើជាពេទ្យនៅមន្ទីរពេទ្យនុ៎ង ហើយនៅពេលដែលគេនាំខ្លួនចេញនៅពេលយប់នុ៎ង នាំខ្លួនប្រហែលជាប៉ុន្មាននាក់ដែរ?

**ឆ៖** ពេទ្យចំនួនជាង២០នាក់ បុគ្គលិកពេទ្យទាំងប្រុសទាំងស្រី។ តែដល់ពេលគេបញ្ជូនចេញខ្ញុំអត់ដឹងៗថា គេចាប់អ្នកណាយកទៅខ្លះទេ ព្រោះអីគេចាប់ទាំងយើងបញ្ជូនដាក់ឡាន បុគ្គលិកគេបញ្ជូនដាក់ឡាននោះ ដោយហេតុនេះយើងរន្ធត់ យើងបានមើលឃើញតែត្រឹមគេឲ្យឡើងឡានទេ។ អត់ដឹងថាចំនួនប៉ុន្មាន ឬប៉ុន្មានទេ បើពេលនោះយើងកំពុងតែមានបញ្ហាដែរ។

[១០:៣១:០១]

**ស៖** ឥឡូវនេះ ខ្ញុំសូមសួរមនុស្សម្នាក់ផ្សេងទៀត ដែលគេបានយកមកយោងនៅក្នុងឯកសារដែលខ្ញុំជូនទៅលោកស្រីនេះ ថាលោកស្រីត្រូវបានចាប់ខ្លួន ដោយសារតែមានមនុស្សពីរនាក់ឆ្លើយដាក់លោកស្រី គឺឈ្មោះ ហង់ និង កង។ តើលោកស្រីមានស្គាល់បុគ្គលិក ឬក៏កម្មាភិបាលម្នាក់ធ្វើការនៅមន្ទីរពេទ្យ២២ ឈ្មោះ ហង់ នេះដែរទេ?

**ឆ៖** ខ្ញុំដូចជាអត់មានស្គាល់ឈ្មោះ ហង់ ទេ ប៉ុន្តែក្រែងគេមានឈ្មោះក្រៅសម្រាប់ហៅ បែបមានឈ្មោះក្រៅ។

**លោក ឌេល លីសាក់៖**

លោកប្រធាន ខ្ញុំសូមការអនុញ្ញាតបង្ហាញឯកសារមួយទៀត ជូនទៅដល់សាក្សី ដើម្បីជួយរំឭកដល់ការចងចាំរបស់គាត់ពីមនុស្សម្នាក់ឈ្មោះ ហង់ គឺកំណត់ត្រាក្រាំងតាចាន់ D157.13 ។ ERN ខ្មែរគឺ 00270827 ដល់ 29, អង់គ្លេស 01064174 ដល់ 76, បារាំង 00971285 ដល់ 88។ បាទ យើងខ្ញុំសូមការអនុញ្ញាតបង្ហាញឯកសារនេះ ជូនទៅសាក្សីលោកប្រធាន។

**ប្រធានអង្គជំនុំ៖**

បាទ អង្គជំនុំជម្រះអនុញ្ញាត!

[១០:៣៣:២០]

**សួរដោយលោក ឌេល លីសាក់៖**

**ស៖** លោកស្រី ឯកសារដែលប្រគល់ជូនលោកស្រីអម្បាញ់មិញនេះ ជាកំណត់ត្រាដែលបានមក

ពីគុកក្រាំងតាចាន់ នៅក្នុងសៀវភៅកត់ត្រានេះ គឺពាក់ព័ន្ធទៅនឹងមនុស្សម្នាក់ឈ្មោះ ហ៊ុន ហង គឺយើងឃើញនៅខាងដើម គឺឈ្មោះ ហ៊ុន ហង ជា -- ERN ជាភាសាខ្មែរគឺ 00270827 បុគ្គលនេះ គឺថាមានអាយុ២៩ឆ្នាំ កើតនៅឃុំជាងទង ស្រុកត្រាំកក់ -- គឺគាត់អាយុ៥៩ ថា គេ -- កំណត់ត្រា ថាគេចាត់ឲ្យធ្វើជាបុគ្គលិកមន្ទីរពេទ្យ នៅមន្ទីរពេទ្យ២២ ទទួលបន្ទុកខាងផ្នែកចែកចាយថ្នាំពេទ្យ។ តើលោកស្រីនៅចាំឈ្មោះម្នាក់នេះទេ ថាមកពីមន្ទីរពេទ្យ២២ ឈ្មោះ ហង ធ្វើការខាងផ្នែកថ្នាំពេទ្យ?

[១០:៣៤:៤០]

**លោកស្រី វង សារុន៖**

**ឆ៖** ខ្ញុំអត់ស្គាល់ឈ្មោះហ្នឹង។

**ស៖** ប្រសិនជាលោកស្រីមើលទៅទំព័របន្ទាប់ជាភាសាខ្មែរ គឺត្រង់ERN 00270828 លោកស្រីឃើញថាមានបញ្ជីឈ្មោះ គេរៀបរាប់មនុស្សមួយចំនួន ដែលឈ្មោះ ហង ហ្នឹង សូមដកស្រង់៖ "ថាបានធ្វើសកម្មភាពក្បត់ជាមួយនឹង អាហង់។" នៅក្នុងទំព័រពាក់ព័ន្ធគេឆ្លើយដាក់ និង ១៣ នាក់។ ហើយខ្ញុំសូមឲ្យលោកស្រីមើលទៅមនុស្សលេខរៀងទី១៣ ឈ្មោះ រុន (ស្រី) ជាប្រពន្ធ សែត។ តើលោកស្រីត្រូវបានគេហៅឈ្មោះ លោកស្រី កាត់នៅក្នុងរបបខ្មែរក្រហមថាឈ្មោះ រុន អ៊ីចឹង ឬក៏អត់ទេ?

**ឆ៖** ចាស គេហៅខ្ញុំឈ្មោះ រុន។

**ស៖** សូមឲ្យលោកស្រីមើលបញ្ជីឈ្មោះចំនួន ១៦នាក់ ហើយសូមជម្រាបជូនអង្គជំនុំជម្រះផងថាតើលោកស្រីចាំឈ្មោះណាម្នាក់ក្នុងចំណោម មនុស្សដែលគេរៀបរាប់ឈ្មោះចំនួន១៦នាក់ហ្នឹង តើមាននៅចាំថា អ្នកណាខ្លះដែលធ្វើការនៅឯមន្ទីរពេទ្យ ២២ ជាមួយលោកស្រីដែលឬទេ?

**ប្រធានអង្គជំនុំ៖**

កុំទាន់អាលឆ្លើយតប! សូមអញ្ជើញលោកមេធាវី ការពារក្ដីលោក ខៀវ សំផន!

[១០:៣៦:៥១]

**លោក គង់ សំអុន៖**

បាទ សូមអរគុណលោកប្រធាន។ ខ្ញុំសូមធ្វើការកត់សម្គាល់ ទៅលើការបង្ហាញរបស់របស់តំណាងសហព្រះរាជអាជ្ញា អម្បាញ់មិញថាឈ្មោះ ហង។ ខ្ញុំបានពិនិត្យទៅលើឯកសារ D157.13 ត្រង់ ERN ជាភាសាខ្មែរដូចដែលសហព្រះរាជអាជ្ញាបានបង្ហាញអម្បាញ់មិញនេះ គឺមានឈ្មោះថា ហ៊ុន ហាន់ ហើយឈ្មោះនេះ សរសេរវាមានភាពមិនច្បាស់លាស់ ប៉ុន្តែ មិនទំនងថាជាឈ្មោះ ហង នោះទេ។ អ៊ីចឹង

សូមអង្គជំនុំជម្រះមេត្តាពិនិត្យទៅលើចំណុចនេះតើជាឈ្មោះ ហង ឬឈ្មោះ ហន់ ដែលសាក្សីអាចធ្វើការបញ្ជាក់ទៅលើចំណុចនេះបាន។ បាទ សូមអរគុណ។

**លោក ខេល លីសាក់៖**

ខ្ញុំមិនអាចអានជាភាសាខ្មែរបានទេ ប៉ុន្តែការបកប្រែទៅជាភាសាអង់គ្លេស និងភាសាបារាំងហ្នឹង គឺ គេបានថា ហ៊ុន ហង់ ឬក៏ ហ៊ុន ហង។ បារាំង ក៏ថាអ៊ីចឹង។ មេធាវីការពារក្ដីលើកឡើងនេះត្រឹមត្រូវ ហើយការ សរសេរជាភាសាខ្មែរនេះគឺថា នាំឲ្យមានការអានច្រឡំ មិនដឹងថាឈ្មោះមួយណា។

**សួរដោយលោក ខេល លីសាក់៖**

**ស៖** លោកស្រីសាក្សី សំណួរដែលខ្ញុំសួរលោកស្រីហ្នឹង មើលទៅលើបញ្ជីអ្នកទោសចំនួន១៦នាក់ហ្នឹង តើក្នុងចំណោម១៦នាក់ហ្នឹង លោកស្រីមានចាំថាមានឈ្មោះណាខ្លះដែលធ្វើការជាមួយលោកស្រីនៅឯមន្ទីរ២២ នោះដែរទេ?

**លោកស្រី វង សារុន៖**

**ឆ៖** ចាស ឈ្មោះ ខ្លះខ្ញុំអានអត់បានផង រលុបៗ។ ឃើញតែឈ្មោះខ្លួន ឯងហ្នឹងរាងច្បាស់។

[១០:៣៩:១៦]

**ស៖** មិនជាអ្វីទេលោកស្រី។ ឯកសារយោងមួយនៅក្នុងសៀវភៅកត់ត្រានេះ គឺមានការយោងទៅឈ្មោះប្ដីរបស់លោកស្រី សែត ហើយនិងកម្មាភិបាលម្នាក់ទៀត ដែលគេកំណត់ថាជាកម្មាភិបាលមកពីហាណូយដែរ ឈ្មោះ ឌឿន។ លោកស្រីមានចាំឈ្មោះម្នាក់មក ឈ្មោះ ឌឿន ឬក៏ ឌឿង នេះជាកម្មាភិបាលមកពីហាណូយ ហើយធ្វើការជាមួយនឹងប្ដីលោកស្រីនោះដែរទេ?

**ឆ៖** ចាស បើៗកម្មាភិបាលហាណូយ ធ្វើជាមួយប្ដីខ្ញុំវះកាត់ហ្នឹង មិនមែនឈ្មោះ ឌឿន ទេ ឈ្មោះ តាដួង។

**ស៖** សូមអរគុណលោកស្រី។ សូមទោសផង ចំពោះអំណាន ការអានឈ្មោះរបស់ខ្ញុំ វាមិនបានច្បាស់លាស់។ តើត្រឹមត្រូវទេថា ដួង គាត់ធ្វើការនៅមន្ទីរពេទ្យ២២ ជាមួយលោកស្រីនិងប្ដីលោកស្រីដែរនោះ?

**ឆ៖** ចាស ឈ្មោះគាត់ ឈ្មោះ ដួង គាត់ខាងវះកាត់ជាមួយប្ដីខ្ញុំ។

**ស៖** តើមានអ្វីកើតឡើងទៅដល់គាត់នេះ ឈ្មោះ ដួង នេះ។ តើគេចាប់ខ្លួនគាត់ដូចប្ដីលោកស្រីនិងដូចលោកស្រីដែរទេ?

[១០:៤១:១០]

**ឆ៖** ចាស ពេលដែលដឹកខ្ញុំនិងប្តីខ្ញុំ ពេលយប់ហ្នឹងចេញ គឺដឹកប្តីខ្ញុំ និងពេទ្យ ដួង និងប្រពន្ធគាត់ ប្រពន្ធគាត់ចិនសុទ្ធ។ តែដល់មក គេឱ្យឈប់ត្រង់កន្លែងមន្ទីរស្រុកត្រាំកក់គេហ្នឹង គេបញ្ជូនគាត់អត់ដឹងទៅណា បំបែកគ្នា ដាក់ខ្ញុំត្រឹមហ្នឹងជាមួយប្តីខ្ញុំ ពេទ្យដួង ហ្នឹងជាមួយប្រពន្ធ គេដឹកបន្តទៀត តែអត់ដឹងថាទៅទីណាទេ។

**ស៖** តើលោកស្រីធ្លាប់បានដឹង ឬក៏ឮថាមានអ្វីកើតឡើងទៅដល់ឈ្មោះ ដួង និងប្រពន្ធរបស់គាត់នេះដែរទេ?

**ឆ៖** ចាស អត់ដឹងដំណឹងទេ។

**ស៖** លោកស្រីបានប្រាប់អំពីការចាប់ខ្លួនលោកស្រី។ ឥឡូវនេះ ខ្ញុំសូមសួរទៅលោកស្រី តើលោកស្រីអាចជម្រាបអង្គជំនុំជម្រះថា ប្តីរបស់លោកស្រីនេះត្រូវបានគេចាប់ខ្លួន នាំយកចេញទៅហ្នឹងក្នុងពេលណាដែរ?

**ឆ៖** ក្នុងពេលថ្ងៃៗជិតត្រង់។ ដល់ពេលថ្ងៃត្រង់ កងខ្ញុំមកពីធ្វើការហ្នឹង អ៊ំដែលជាម្ចាស់ផ្ទះខ្ញុំស្នាក់នៅហ្នឹង គាត់ប្រាប់ថា អ៊ីរុន ហ៎ា គេចាប់ តាសែត -- អ៎! គេហៅ តាសែត ទៅរៀនសូត្រហើយ។ ខ្ញុំគ្រាន់តែឮពាក្យរៀនសូត្រហ្នឹង ខ្ញុំយំហើយៗ ខ្ញុំដឹង។ តែមុននឹងខ្ញុំបានមកដល់ផ្ទះ ខ្ញុំសូមជម្រាបអស់លោកឱ្យដឹងថា ខ្ញុំហាក់ដូចជាមានស្អីប្រាប់ខ្ញុំនៅផ្លូវរទេះថា ប្តីគេចាប់ហើយ ដូចមានសំឡេងស្រែកប្រាប់។ ពេលនោះ ខ្ញុំដួលសន្លប់ អត់ដឹងផង ដល់តែអ៊ំម្ចាស់ផ្ទះ គាត់មកឃើញអ៊ីចឹង បានគាត់យកទៅផ្ទះ។ គាត់សួរថា វាអី? ខ្ញុំថា ខ្ញុំៗងងឹតមុខដួលអ៊ំ។ ដល់ហើយគាត់ក៏ប្រាប់ថា អឺ! តាសែត គេហៅគាត់ទៅគេកូនង៉ែតនៅ -- គេអត់ប្រាប់ថា ក្រាំងតាចាន់ទេ គ្រាន់ថា គេហៅគាត់ទៅ កូនង៉ែតគេឆ្លងទន្លេនៅឯត្រពាំងធំឯនោះ។ ខ្ញុំគ្រាន់តែឮពាក្យថា គេហៅគាត់ទៅ។ ខ្ញុំយំហើយៗ ខ្ញុំ -- ព្រោះអីរឿងៗអារឿងសម្លាប់ហ្នឹងមិនមែនខ្ញុំមិនដឹង ខ្ញុំដឹង។ ខ្ញុំដឹងថា ជីវិតខ្ញុំតែចេញពីអង្គភាព បើមិនស្លាប់ មានតែគេយកទៅដាក់គុកហ្នឹង។ ព្រោះអីយើងមកក្លាយខ្លួនជាអនុប្រជាជនហើយហ្នឹង។ ហ្នឹងខ្ញុំដឹងច្បាស់អ៊ីចឹង។

[១០:៤៤:៥៣]

**ស៖** តើលោកស្រីបានជួបប្តីលោកស្រីជាថ្មីឡើងវិញទេ ក្រោយពេលចាប់ខ្លួនហើយ?

**ឆ៖** អត់បានជួបទេ។ តែពេលនោះ គេបញ្ជូនឱ្យខ្ញុំមក មករែកដីប្រឡាយ មិនដឹងគេជាភូមិអីទេ នៅពីខាងជើងក្រាំងតាចាន់ កងមេម៉ាយខ្ញុំមករែកដីកន្លែងហ្នឹង។ ហើយអ៊ំដែលម្ចាស់ផ្ទះនោះ គាត់

ស្រឡាញ់ខ្ញុំណាស់ គាត់ថាខ្ញុំហ្នឹងដូចកូនគាត់ គាត់ប្រាប់ថា៖ “ម៉ែច្រិបហ៊ា! (កូនខ្ញុំឈ្មោះច្រិប) ម៉ែច្រិបហ៊ា! អ្វែងកុំយំ អញប្រាប់អ្វែងឱ្យត្រង់ ប្តីអ្វែងគេយកទៅដាក់គុកក្រាំងតាចាន់”។ ខ្ញុំ ហេតុតែជីវិតខ្ញុំវាមិនស្លាប់ ដល់ពេលខ្ញុំមកជីកប្រឡាយ ខ្ញុំសួរភូមិគេហ្នឹងថា ក្រាំងតាចាន់ៗហ្នឹងនៅណាទៅអ្វី? គេថា “ណោះអ៊ីរុនឯងដើរទៅត្បូង។ អី! ឆ្ងាយបន្តិចដែរ អាហ្នឹងឃើញរបងគេពីរបីជាន់ហ្នឹងហើយ”។ ដល់ពេលនោះ ខ្ញុំដើរ ខ្ញុំដើរតាមគេ ប្រាប់អ៊ីចឹងមែន ដូចខ្ញុំគិតថាប្តីខ្ញុំនៅរស់។ ដល់ហើយមានម្នាក់គេរត់មកតោងដៃថា “កុំ កុំទៅ! តែទៅជិតកន្លែងហ្នឹងអត់បានទេ កុំទៅ!”។ ខ្ញុំថា ក្នុងចិត្តខ្ញុំគិតថាដើរស្ទុងចូលចូលមកកន្លែង កន្លែងគុកក្រាំងតាចាន់ហ្នឹងហ្មង ខ្ញុំដឹងមុន គេចាប់ខ្លួនខ្ញុំ ព្រោះអី ម៉ែធម៌ខ្ញុំ គាត់ប្រាប់ត្រង់គេយកគាត់ទៅដាក់គុកក្រាំងតាចាន់។ អ៊ីចឹងដល់ពេលគេបើកសមរភូមិរែកប្រឡាយហ្នឹង ខ្ញុំសួរគេថាក្រាំងតាចាន់នៅឯណា? គេប្រាប់ ដល់គេប្រាប់ ខ្ញុំដាក់ចិត្តថា ពេលសម្រាកថ្ងៃត្រង់ ខ្ញុំដាក់ចិត្តថា ខ្ញុំដើរដើរទៅហ្នឹង ក្រែងលោឃើញប្តីខ្ញុំខ្លះ។ តែអត់ អត់ឃើញ។ គេប្រាប់ខ្ញុំថា គាត់ហ្នឹងដាំថ្នាំ គេឱ្យរែកទឹកដាំថ្នាំ។ អ៊ីចឹងចិត្តខ្ញុំ អារម្មណ៍ខ្ញុំនៅតែគិតថា បើខ្ញុំមកលបមើល ប្រហែលជាឃើញហើយ។ តែតាមការពិត អត់ អត់ដែរឃើញទេ។

[១០:៤៧:២៤]

**ស៖** សូមអរគុណចំពោះចម្លើយរបស់លោកស្រី។ ឥឡូវនេះ ខ្ញុំសូមចូលទៅអំឡុងពេលដែលគេឃុំខ្លួនលោកស្រីនៅគុកក្រាំងតាចាន់ លោកស្រីក៏បានជម្រាបជូនអង្គជំនុំជម្រះហើយ អំពីពេលដែលលោកស្រីទៅដល់ ហើយនិងពេលដែលគេដាក់ខ្នោះជើងលោកស្រីអស់រយៈពេលប្រាំពីរថ្ងៃ មុននឹងគេយកទៅសួរចម្លើយ។ ប្រសិនបើជាលោកស្រីអាចរៀបរាប់បាន សូមជួយរៀបរាប់លម្អិតបន្តិចអំពីអគារដែលគេឃុំលោកស្រីនេះ អគារមានទ្រង់ទ្រាយយ៉ាងម៉េចដែរ? ហើយតើមានអ្នកទោសគេឃុំជាមួយលោកស្រីនៅក្នុងអគារហ្នឹងប្រហែលជាប៉ុន្មាននាក់ដែរ? ដូច្នេះសូមឱ្យលោកស្រីរៀបរាប់អំពីទិដ្ឋភាពទូទៅនៃអគារដែលគេឃុំលោកស្រីនេះ និងចំនួនអ្នកទោសដែលឃុំជាមួយលោកស្រី។

**ឆ៖** ចាស អគារដែលគេដាក់អ្នកទោសមានបី។ ពីខាងជើងផ្លូវចូលហ្នឹងមួយ បន្ទាប់មក អាផ្ទះមេគេ នៅខិតខាងកើត និងខិតខាងត្បូងផ្ទះមេគេបន្តិចមក មានអគារពីរ វែងៗដូចគ្នា។ អគារនោះ គេសង់ -- មិនដឹងគេសង់ថាអាម៉េចទេអាហ្នឹង អាហ្នឹងគេសង់ហើយមានមេដំបូល ហើយវែងៗអ៊ីចឹងហើយប្រក់ស្លឹក ជញ្ជាំងក្តារ ពេលដែលយើងចូលទៅមុនដំបូង យើងអត់មានចាប់អារម្មណ៍ទេ ថាតែផ្ទះស្អី ព្រោះអីអត់មានស្អីដែលគួរឱ្យយើងចាប់អារម្មណ៍ទេ។ ដល់ពេលយើងចូលទៅ បានដឹងថា វាៗចង់

ងាប់ហើយ វាពិបាកចិត្តណាស់ ពេលគ្រាន់គុកគេភ្ជាម យើង ដើរនៅខាងក្រៅ មើលអត់ដឹងថាៗអាហ្នឹង ជាកន្លែងអីទេ ដល់យើងចូលក្នុងបានដឹង។ គេព័ទ្ធរបងក្រឡាចត្រង្គអ៊ីចឹង ពីជញ្ជាំងក៏ក្រឡាចត្រង្គ អាពីខាងលើគេក៏ព័ទ្ធបន្លាលួសអ៊ីចឹង អាខាងក្រោមក្តារយើងដេក ក៏គេព័ទ្ធបន្លាអ៊ីចឹងដែរ ហើយអាកន្លែងយើងដាក់ជើងហ្នឹងៗ ក៏គេព័ទ្ធដែរ។ និយាយរួម សឹងតែថាកណ្តុរ កន្លាត ក៏វាចេញមិនរួច អត់មានកន្លែងណាដែលរត់ចេញរួច ហើយមាត់ទ្វារគេចូល គេធ្វើរាងខ្ពស់អ៊ីចេះបន្តិច ក៏គេដាក់បន្លា -- ដាក់អាលួសបន្លាហ្នឹងប្រទាក់គ្នាអ៊ីចឹងដែរ។ ហេតុនេះខ្ញុំគិតថា កន្លែងនេះកន្លែងងាប់ អត់មានកន្លែងរត់រួចទេ អត់មានកន្លែងគេចខ្លួនបានទេ។ អ៊ីចឹងផ្ទះបីហ្នឹងគឺគេសម្រាប់ដាក់អ្នកទោស។ អ្នកទោស ខ្ញុំទៅដំបូង មាន ខ្ញុំ អ៊ីផុន ការឿន អាហ្នឹងៗនៅក្នុងគុកជាមួយខ្ញុំ ប៉ុន្តែគ្រួសារយាយញ៉ គាត់មានទោសដែរ តែគេអនុញ្ញាតឲ្យគាត់ ឲ្យកូនប្រុសគាត់ពីរបីនាក់ ហើយមីកូនស្រីមួយពៅ អាយុប្រហែលជា ៤-៥ឆ្នាំយ៉ាងច្រើន នៅក្រៅ។ គាត់អ្នកធ្វើចុងភៅបបរបាយឲ្យៗពួកអ្នកទោស។ ក្រៅពីហ្នឹង ផ្ទះផ្សេងៗទៀតដែលខ្ញុំ -- ពេលដែលគេឲ្យខ្ញុំចេញក្រៅហើយ ខ្ញុំឃើញថាសុទ្ធតែជាកសិករថ្មីទាំងអស់។ មានយប់មួយ កណ្តាលយប់ ឮតែសន្ទឹកជើងព្រូសៗ គេបើកទ្វារឃ្នាំង គួរឲ្យរន្ធត់ណាស់ គេចងដៃមនុស្សប្រហែល១ម៉ែត្រមួយៗជាមួយអាពោះធ្នោតយើងហ្នឹង បណ្តើរដោយក្មេងតូចមួយកាន់កាំភ្លើង បណ្តើរចូលផ្ទះពេញមួយយប់ហ្នឹង គឺយើងទាំងអស់គ្នាអត់បានដេក កូនង៉ែត កូនង៉ាតូចៗ វាយំ។ យប់នោះទាន់ហន់ណាស់លោក ដោយមនុស្សវាពេញ វាណែនពេញរោងពេក គេក៏បញ្ចេញមនុស្សភ្លឺស្រាងៗឡើង គេបញ្ចេញមនុស្សឲ្យទៅផ្ទះ ខ្ញុំទៅដល់ដំបូង គេថាឲ្យអ្នកទោសទៅផ្ទះ ខ្ញុំអរណាស់ ខ្ញុំហាមាត់ មានអ៊ីមួយ អ៊ីផុន គាត់មួលខ្ទាច់ ហាមាត់គេថាសុំទៅផ្ទះ គេមួលខ្ទាច់។ ដូចនេះ ធ្វើឲ្យខ្ញុំមិនបាននិយាយអ្វីទាំងអស់ជាមួយពួកគេ។ គេឲ្យទៅផ្ទះ ខ្ញុំស្មានតែទៅផ្ទះ មនុស្សទាំងខ្សែៗ។

[១០:៥២:១២]

អ្នកដែលៗនៅយូរ គេក្រយកទៅសម្លាប់ស្គមដើរអត់រួច គេដាក់រទេះរុញ ពេលដែលយកទៅសម្លាប់ហ្នឹង។ ដល់ពេលអ៊ីចឹង ខ្ញុំអត់ដឹងថាវាឲ្យទៅផ្ទះ ឬស្លាប់ គេយកទៅសម្លាប់ទេ។ គេចាក់មេក្រូស្រែកឡូងៗ ផ្លង់ហឹងត្រចៀកទាំងអស់។ ដល់ពេលគេយកមនុស្សទៅបាត់អស់ អ៊ីផុន ដែលក្តិចមួលៗខ្ញុំហ្នឹង គាត់ប្រាប់ថាអ៊ីរុនឯងអត់ដឹងទេ គេឲ្យទៅផ្ទះហ្នឹង គេយកទៅវ៉ៃចោលណ៎ា។ ខ្ញុំអត់ដឹង ថាជីវិតខ្ញុំវាហាក់ដូចជាមិនចង់ឲ្យខ្ញុំស្លាប់បានជាមានអ្នកជិតខាងគេចេះតែជួយខ្ញុំ ដោយខ្ញុំធ្វើអំពើល្អ ខ្ញុំមើលតែគេឲ្យជា ខ្ញុំអត់មានព្យាបាទអ្នកណាទាំងអស់។ អ៊ីចឹងទិដ្ឋភាពមនុស្សច្រើនណាស់លោក ខ្ញុំអត់ដឹងថាប្រាប់ថា

យ៉ាងម៉េចទេ។ មកដល់ថាគេយកអ្នកទោសមកដល់ក្រាំងតាចាន់ បើដល់ខែស្ទូង គេអត់ទាន់យកទៅវ៉ៃចោលទេ គេឱ្យទៅស្ទូងជាមួយពួកខ្ញុំប៉ុន្មាននាក់ហ្នឹង តាដាំ ពូសែម អ៊ីហាត់(រ៉ាត់) អ៊ីផុន ក្បឿន។ អាហ្នឹងទៅស្ទូងជាមួយអ្នកទោសដូចគ្នា ប៉ុន្តែអ្នកទោសយើង គឺជាអ្នកទោសដែលគេអាចឱ្យចេញក្រៅពេលធ្វើការ ដល់ពេលអីចឹងស្ទូងហើយ កាលណាស្ទូងហើយ អាហ្នឹងគេឱ្យទៅផ្ទះហើយ គេឱ្យទៅផ្ទះហ្នឹង គេយកមនុស្សទៅវ៉ៃចោលហើយ វ៉ៃដល់តែអស់រលីងនៅតែពួកខ្ញុំប៉ុន្មាននាក់ហ្នឹង ស្ទើរតែល្ងួសថ្ងៃមិនបានទេលោក មនុស្សចូលមកបន្តបន្ទាប់ៗ ការទៅសួរចម្លើយក៏បន្តបន្ទាប់។ តែខ្ញុំមានមិត្តភក្តិខ្ញុំម្នាក់ឈ្មោះ រ៉ុម វាកូនគណៈស្រុកអង្គជ័យ គេចាប់ម៉ែឪ វាអត់ដឹងៗថាម៉ែឪវាគេចាប់ទេ វានឹកម៉ែ រត់មកលេងដល់ហើយគេចាប់បញ្ជូនទៅគុកក្រាំងតាចាន់។ ខ្ញុំ -- ចុះមនុស្សស្គាល់គ្នាហេតុអីមិននិយាយគ្នាបាន ខ្ញុំក៏សួរថា “រ៉ុម ហ្អែងអាម៉េចបានមកនេះដែរ?” វាមិនទាន់ឆ្លើយខ្ញុំមួយម៉ាត់ផង គេឱ្យខ្ញុំចូលក្នុងផ្ទះហ្នឹងដែរ គេដាក់គុកសាជាថ្មី លែងឱ្យចេញ ដាក់កងជើងសាជាថ្មី ឈប់ឱ្យខ្ញុំចេញរហូតដល់មួយអាទិត្យបាន គេឱ្យខ្ញុំចេញ។ តែរយៈពេលដែលខ្ញុំនៅក្នុងហ្នឹងមួយយប់ គេហៅ អារ៉ុម ទៅ។ លោកខ្ញុំលែងនិយាយហើយ ខ្ញុំឈប់និយាយរកអ្នកណា ដោយគេថាខ្ញុំពូកែស្គាល់ ពូកែនិយាយ។

[១០:៥៥:០៥]

ដល់ពេលហ្នឹងយប់ឡើង អាដេកហ្នឹងវាមានប្រលោះកណ្តាលដើរ អាខាងៗយើងដេក។ ខ្ញុំហ្នឹងក៏តតេះតតះយកដៃទៅស្ទាបវា។ លោកអើយ គួរអនិច្ចាណាស់ ខ្លួនរួមរឹត ខ្ញុំអត់មានកន្លែងដែលសាច់ម៉ែចែកទេ កន្ទួលប៉ុនៗមេដៃ ប៉ុនៗមេជើង ទាំងអស់។ យើងបានជួបមុខគ្នាតែពេលយប់ទេ។ ដល់គ្រប់៧ថ្ងៃគេបញ្ចេញខ្ញុំឱ្យមកវិញ។ គេថា “អាមាត់ហ្នឹងកុំពូកែដឹង កុំពូកែឮ កុំពូកែនិយាយគេ មកដល់កន្លែងនេះហើយ យើងអត់មានសិទ្ធិនិយាយជាមួយអ្នកណាទាំងអស់”។ ហេតុនេះ ទិដ្ឋភាពនេះ ខ្ញុំចងចាំ វាអត់ភ្លេចមិនដឹងថាភ្លេចទៅធ្វើម៉េចកើតទេ។

**ស៖** សូមអរគុណលោកសាក្សីនូវរាល់ព័ត៌មានទាំងអស់។ លោកស្រីក៏បានជម្រាបថាអគារដែលគេឃុំលោកស្រីហ្នឹង គឺថាគេឃុំអ្នកទោសច្រើនពេក ចង្អៀតណែនណាន់តាន់តាប់ណាស់។ លោកស្រីអាចប៉ាន់ប្រមាណចំនួនអ្នកទោសនៅក្នុងអគារដែលគេឃុំលោកស្រីនេះ ឃុំជាមួយលោកស្រីនេះ ប៉ាន់ប្រមាណថាមានប្រហែលជាប៉ុន្មាននាក់ដែរ?

**ឆ៖** អគារហ្នឹង បើគេដាក់យើងពេញ វាចូលខ្ទង់៤០ហើយលោកគ្រូ ប៉ុន្តែប្រជ្រៀតគ្នា។ ដេកប្រជ្រៀតគ្នាហើយពេលហ្នឹង។ អាហ្នឹងខ្ទង់៤០ ហើយខាងរោងពីរទៀត គឺរោងហ្នឹងប៉ុនៗគ្នា តាមខ្ញុំ

មើល អត់ៗមានតូចធំជាងគ្នាទេ គ្រាន់តែមានកន្លែងដេកហ្នឹង សងខាង គេឲ្យធ្វើផ្លូវដើរកណ្ដាល។

**ស៖** លោកស្រីក៏បាននិយាយអំពីឈ្មោះអ្នកទោសខ្លះទៀត ដែលគេឃុំខ្លួនតែមួយជាមួយលោកស្រី។ លោកស្រីនិយាយអំពីយាយ ញ៉ និងអ្នកទោសដទៃទៀត ដែលនៅទីនោះរួចទៅហើយ។ ហើយលោកស្រីស្គាល់ យាយញ៉ ច្បាស់ ហើយលោកស្រីក៏និយាយថាអ្នកទោសថ្មីៗខ្លះ ក៏គេយកមកដាក់នៅក្នុងអគារជាមួយលោកស្រីនោះដែរ។ សូមលោកស្រីជួយប្រាប់ឈ្មោះអ្នកទោសដែលគេឃុំនៅក្នុងអគារជាមួយលោកស្រី ដែលលោកស្រីស្គាល់ហ្នឹង តើអ្នកទាំងអស់នោះ ឈ្មោះអី? ហើយធ្វើអ្វីដែរ?

[១០:៥៨:២៨]

**ឆ៖** ខ្ញុំអត់ដែលបានសួរឈ្មោះគេទេ ដោយខ្ញុំរាងអារឿងសួរមិត្តភក្តិខ្ញុំស្គាល់ម្ដងហើយ តែខ្ញុំដឹងតែអ្នកដែលនៅជាប់គុកជាមួយខ្ញុំ ពេលដែលខ្ញុំមកដល់ គេជាប់មុនខ្ញុំហើយ។ ខ្ញុំជាអ្នកមកជាប់ក្រោយគេក្រោយគេបំផុត ដែលគេហៅថាយើងហ្នឹងចេញពីអង្គភាព។ អាហ្នឹងគេហៅថា យើងអ្នកធ្វើការ គឺមានតែឈ្មោះខ្ញុំហ្នឹងចូលក្រោយគេបង្អស់។ ពេលដែលខ្ញុំមកដល់ ខ្ញុំឃើញអ្នកជាប់ទោសជាមួយខ្ញុំប៉ុន្មាននាក់ហ្នឹង ខ្ញុំឃើញមុនខ្ញុំទៅហើយ ហើយអ្នកថ្មី ខ្ញុំអត់បានសួរឈ្មោះគេទេ ដោយខ្ញុំខ្លាចមានទោសទៀត។

**ស៖** លោកស្រីជម្រាបពីខាងដើមនេះបន្តិច ថានៅពេលលោកស្រីទៅដល់គុកក្រាំងតាចាន់ កូនលោកស្រីឃំបីថ្ងៃជាប់ៗគ្នា ហើយកូនលោកស្រីហ្នឹង ក៏ត្រូវគេវាយដំដែរ។ តើ -- សូមលោកស្រីជម្រាបជូនអង្គជំនុំជម្រះ ថាមានអ្វីកើតឡើងចំពោះកូនស្រីលោកស្រីហ្នឹង? កូនស្រីហ្នឹងត្រូវបានគេវាយដំ ឬក៏អត់? ហើយបើត្រូវបានគេវាយដំ អ្នកណាជាអ្នកវាយដំកូនរបស់លោកស្រីហ្នឹង?

**ឆ៖** កូនខ្ញុំពេលដែលយំ គេចូលមកវាយហ្នឹង ឈ្មោះ ដែលវាយកូនខ្ញុំហ្នឹងឈ្មោះ ស៊ីម។ ដល់ពេលខ្ញុំចេញក្រៅមកធ្វើការ ខ្ញុំឮគេហៅឈ្មោះថា ស៊ីមៗ។ មិនត្រឹមតែវាយទេលោក គេទៅរកត្រីបានមានសុទ្ធតែត្រីអណ្ដែង ត្រីកញ្ចុះ គេឲ្យកូនខ្ញុំចាប់ ឲ្យចាប់នៅនឹងមុខហ្នឹង។ លោកគិតមើល ត្រីអណ្ដែងវាៗ វាៗមិនមុតមនុស្ស។ ត្រីកញ្ចុះ សុទ្ធតែសត្វពិស គេឲ្យចាប់។ ហើយគេថា “ឲ្យវាងាប់ទៅ ឲ្យវាផុតពូជ អាសែត” គេនិយាយអ៊ីចឹង នៅមុខខ្ញុំ។ ពេលហ្នឹង ខ្ញុំគ្មានអីក្រៅពីថា សូមព្រះអង្គ សូមទេវតា ជួយកូនខ្ញុំ កុំឲ្យមានសត្វអស់ហ្នឹងមុត។ កូនខ្ញុំ សត្វហ្នឹងអត់មុតមែន លោក។ វាបានរួចផុតពីអាសត្វហ្នឹង។

[១១:០១:៣៥]

**ស៖** លោកស្រីសាក្សី លោកស្រីនិយាយថាកូនលោកស្រីអាចរស់រានមានជីវិតនៅក្នុងរបបនោះនៅពេលដែលលោកស្រីត្រូវបានគេឃុំនៅក្រាំងតាចាន់។ ឥឡូវនេះ ខ្ញុំចង់សួរសំណួរផ្សេងពាក់ព័ន្ធទៅនឹង

ការរស់នៅនៅក្នុងគុកនោះ។ តើលោកស្រីអាចជម្រាបបានទេថា មានអ្នកទោសឈឺជាញឹកញាប់ទេនៅក្នុងគុកនុ៎ង ហើយនៅពេលដែលមានអ្នកទោសឈឺនោះ មានគេផ្ដល់ថ្នាំព្យាបាលអីទេ?

**ឆ៖** ចាស និយាយជាក់ស្ដែង គឺក្នុងផ្ទះដែលខ្ញុំនៅ ពូយឿន ។ ពូយឿន ហ្នឹងគាត់ជាអតីតកងទ័ព ប៉ុន្តែគាត់ពិការខ្វាក់ភ្នែកទាំងសងខាង។ ប្រពន្ធគាត់ឈ្មោះ អ៊ីផុន ។ កូននោះឈ្មោះ អាពិ។ គឺគេដាក់នៅជាមួយខ្ញុំ។ មុនដំបូង គេឲ្យគាត់ចេញក្រៅ តែក្រោយមក គាត់ប្រាប់ខ្ញុំថាគាត់ហេវពេក គាត់លួចពងមាន់គេហុតមួយទៅ។ ដល់ពេលគេរកឃើញ គេក៏ចាប់គាត់ទៅដាក់ក្នុងគុកហ្នឹង លែងឲ្យចេញត្រូវថ្ងៃរហូត។ ពូយឿន ហេតុតែហេវពេក -- គាត់នៅកន្លែងនោះ ខ្ញុំប្រាប់ថា កណ្ដុររត់ប៉ះមនុស្ស រត់លើក្បាលមនុស្ស រត់លើខ្លួនមនុស្ស។ ដល់អ៊ីចឹង ពូយឿន គាត់ចាប់បានកណ្ដុរ គាត់ហែកៗកណ្ដុរទាំងស្រស់ហ្នឹង។ ហែកពន្លាត់ហើយនឹងដៃ ហើយគាត់ខាំសាច់កណ្ដុរទាំងឈាមហ្នឹង ហូប។ ហើយឲ្យកូនប្រុសគាត់ អាកូនហ្នឹងដើរតេះតះ ជាងមួយខួបដែរ ដូចកូនខ្ញុំ ឲ្យវាស៊ីជាមួយគាត់ទៅ។ ដល់ប្រពន្ធគាត់ជាប់ដែរ ប្រពន្ធគាត់អត់ហូបទេ។ ចាស អត់បានរយៈពេលមួយខែទេ ពូយឿន គាត់ឈឺហើម កូនក៏ឈឺហើម តែគេមិនដែលឲ្យថ្នាំ ឬក៏មកសាកសួរយើងថា ឈឺយ៉ាងម៉េចៗ អត់ទេ។ ដល់ទីចុងបំផុត គាត់ស្លាប់។ កូនក៏ស្លាប់។ ពេលដែលស្លាប់នោះ គេអត់មានថា សែងអីទេ។ គេឲ្យអ្នកទោសដែរ -- ចងកជើង អូសទម្លាក់ពីរានដេកហ្នឹងមក អូសរូមក កន្លងអាៗទ្វារចេញហ្នឹង វាមានល្អសបន្ទា និយាយពីខ្លាចដាច់អាខ្មោចហ្នឹង ខ្ញុំពិចារណាក្នុងហ្នឹងយំ តែយំមិនហ៊ានគេឃើញទេ។ ខ្លាចគេសម្លាប់ខ្លួនទៀត។ អាហ្នឹងឃើញនៅជាក់ស្ដែងនឹងភ្នែក ដែលគេដាក់គុកកន្លែងតែមួយ។ តែអ្នកផ្សេងទៀត តែពេលគេវាយមនុស្សចោល គេឲ្យពួកខ្ញុំចូលក្នុងផ្ទះហើយ។ ខ្ញុំលបមើលតាមជញ្ជាំងក្ដារវាជាប់គ្នា ខ្ញុំឃើញអ្នកខ្លះហើម គេដាក់រទេះរុញៗទៅ។ ហើយខ្ញុំពិចារណា គេស្លាប់ អញអត់យូរទេ ក៏ស្លាប់ដូចគេដែរ។ ហ្នឹងគឺឃើញជាក់ស្ដែងនឹងភ្នែក វាជាការពិត ដែលជីវិតខ្ញុំ ភ្នែកខ្ញុំមើលឃើញផ្ទាល់។

[១១:០៥:៣៦]

**ស៖** អតីតទាហានដែលលោកស្រីនិយាយនុ៎ង ដែលថាតាមពិតទៅគឺគាត់ខ្វាក់ភ្នែក ហើយគាត់បានស្លាប់ក្រោយពីគាត់ស៊ីកណ្ដុរ។ អ៊ីចឹងនៅពេលដែលលោកស្រីនិយាយថា គាត់ជាអតីតលន់នល់ នោះលោកស្រីចង់សំដៅថា ជាអតីតលន់ នល់ ខ្មែរក្រហម ឬក៏ជាទាហានរបស់លន់ នល់?

**ឆ៖** ពូយឿន គាត់កងទ័ពខ្មែរក្រហម។

**ស៖** លោកស្រីបានចាប់ផ្ដើមនិយាយអំពីពេលដែលគេនាំលោកស្រីទៅសួរចម្លើយ។ លោកស្រី

បញ្ជាក់ថា គេឃុំខ្លួនលោកស្រីអស់រយៈពេលជាច្រើនថ្ងៃ គេដាក់ខ្នោះ ហើយបន្ទាប់មកប៉ុន្មានថ្ងៃក្រោយមក គេដោះលែងលោកស្រី គេឲ្យអង្គុយលើកៅអីដែកមួយនៅកន្លែងសួរចម្លើយ។ តើលោកស្រីអាចរៀបរាប់អំពីការចងចាំលោកស្រីពាក់ព័ន្ធទៅនឹងអ្វីដែលកើតឡើងនៅពេលដែលគេសួរចម្លើយលោកស្រីទេ?

**ឆ៖** ចាស ពេលទៅដល់ គេឲ្យខ្ញុំអង្គុយលើកៅអីដែកតូចមួយបួនជ្រុងហ្នឹង។ មុនដំបូង គេសួរថាខ្ញុំហ្នឹងលាក់កាំភ្លើងខ្លីនៅឯណា? ហើយខ្ញុំអត់ដឹងថាកាំភ្លើងខ្លីហ្នឹងនៅឯណាផង។ ខ្ញុំថាខ្ញុំមានកាំភ្លើងខ្លីឯណាលាក់ បើខ្ញុំមកមួយចង្កេះហ្នឹង ហើយសូម្បីតែខោអាវខ្ញុំនៅសហករណ៍ ក៏ខ្ញុំអត់មានអ្នកណាឲ្យខ្ញុំយកមកដែរ ខ្ញុំមានកន្លែងណាលាក់។ ហ្នឹងរួចសំណួរមួយ។

សំណួរមួយទៀត គេសួរថា ដែលអ៊ីរុន ឯងហ្នឹងរៀនដល់ថ្នាក់ទីប៉ុន្មាន? ខ្ញុំអត់លាក់ទេ ខ្ញុំប្រាប់ថាខ្ញុំរៀនថ្នាក់ទី៣ សង្គមចាស់ នៅវិទ្យាល័យទូកមាស។ គេថាអនុធនសោះអ៊ីចឹង បានវាអ៊ីចឹង ប្ដីដឹកនាំទៅបាន។ ដល់ហើយ ខ្ញុំក៏អត់មាត់នៅតែស្ងៀម ក្រោយគេសួរខ្ញុំថា ប្ដីដឹកនាំម៉េចខ្លះ? ឲ្យចូល អា.កា.បេ យួន? ខ្ញុំអត់ស្គាល់រហូតដល់ថ្ងៃហ្នឹងប៉ា! មិនដឹងថា អា.កា.បេ យួនហ្នឹងវាជាស្អី? ខ្ញុំអត់ដឹងរហូតដល់ថ្ងៃហ្នឹង។ ខ្ញុំឆ្លើយថា ខ្ញុំអត់ស្គាល់ទេ សូម្បីតែលោកថា អា.កា.បេ យួនហ្នឹង ខ្ញុំអត់ដែលដឹងផង ហើយប្ដីខ្ញុំនិងខ្ញុំ ណាស់តែប្ដីប្រពន្ធប៉ុន្តែមិនដែលបាននៅថិតថេរគៀបជាប់គ្នាទេ។ គាត់នៅសមរភូមិមុខសម្រាប់វះកាត់ ខ្ញុំប្រពន្ធនៅសមរភូមិក្រោយសម្រាប់លាងរបួសចាក់ថ្នាំឲ្យអ្នក ឲ្យកងទ័ពតែប៉ុណ្ណឹង។ ហើយហ្នឹងគាត់មិនដែលបានអីនិយាយអីជាមួយខ្ញុំអារឿង អា.កា.បេ យួនហ្នឹងខ្ញុំមិនដែលដឹង។ ដល់ពេលខ្ញុំឆ្លើយដល់កន្លែងហ្នឹង ខ្ញុំខិនយំ ដល់ខិនយំ ខ្ញុំឃើញគេលើកបន្ទះផ្ដៅប៉ិនៗមេជើងក្រហាមរលោង យារវ៉ៃជិតដល់ខ្ញុំហើយ តែមានអាមួយទៀតគេថា “កុំវ៉ៃ! វាអត់មានទោសអីទេ!” ដល់អ៊ីចឹងបាន តាពេញ ហ្នឹងដែលអ្នកចង់វ៉ៃខ្ញុំហ្នឹង គេដាក់អារំពាត់ហ្នឹងចេញវិញ។

[១១:០៩:០៣]

គេថា៖ “ឥឡូវហ្នឹងទៅវិញ! សរសេរប្រវត្តិរូបសង្ខេបឲ្យគេ! ប្ដីធ្វើអីខ្លះ? ម៉ែឪហ្នឹងធ្វើអី? បងប្អូនហ្នឹងធ្វើអី? យើងហ្នឹងរៀនដល់ថ្នាក់ទីប៉ុន្មាន ហើយធ្វើអីខ្លះមុនចូលមកធ្វើការហ្នឹង?” គេក៏ឲ្យខ្ញុំសរសេរ។ គេឲ្យវ៉ៃខ្ញុំទេ តែគេវាយផ្លូវចិត្តខ្ញុំ គេនិយាយឌឺដង និយាយថា៖ “ប្រពន្ធវាស្អាតអ៊ីចឹង បានជាប្ដីវានៅតែនឹក”។ ម៉េចដល់អ៊ីចឹង ខ្ញុំកំណត់ចិត្តថា ប្ដីខ្ញុំពិតជាគេយកវាយនៅហ្នឹងហើយ អត់មានគេកុហកទេ គឺគេប្រាប់ត្រឹមត្រូវហ្នឹងហ្មង។ គេពិតជាប្រាប់ថាស្លាប់នៅហ្នឹងមែន។

ដល់ពេលមួយ គោគេវារបួត គេឲ្យខ្ញុំមើលគោ ចាំមើលគោកុំឲ្យវារត់ទៅលិច អាកន្លែងជិតគេស្លួរចម្លើយ។ អ៊ីផុន គេប្រាប់ខ្ញុំថា "ហ្នំ! ឆ្អឹង តាសែត គេវ៉ៃ តាសែត នៅក្រោមដើមឈើទាលពីខាងលិចហ្នឹង"។ ខ្ញុំដាច់ចិត្ត ខ្ញុំពិតជា -- ពិតជាខ្ញុំចង់ងាប់មែន វាមិនគួរខ្ញុំមានជីវិតដល់ថ្ងៃនេះទេ។ ខ្ញុំនឹកឃើញថា ខ្ញុំសម្រេចចិត្តថា ដេញគោហ្នឹងចូល ខ្ញុំទៅមើលៗ ក្បាលៗប្ដីខ្ញុំដែរអត់? ដល់ពេលគោទៅ ខ្ញុំមាត់ខ្ញុំក៏ស្រែកដែរ "ពូអើយគោរត់ទៅលិចហើយពូ"។ ពិតមែនតែមាត់ខ្ញុំថា គោរត់ទៅលិច តែខ្ញុំទៅ គ្រាន់តែស្រែកប្រាប់ថាគោរត់ទៅលិច។ ខ្ញុំទៅ ខ្ញុំឃើញឆ្អឹងមែន ខ្ញុំឃើញលលាដ៍ល្បាលច្រើនមែន តែខ្ញុំអត់ដឹងថាជាឆ្អឹង ជាធាតុរបស់អ្នកណាទេ ខ្ញុំអត់ដឹង។

ពេលនោះ លោកដឹងទេថា តើជីវិតខ្ញុំវាត្រូវយ៉ាងម៉េច? គេយកខ្ញុំមកឲ្យនៅមកកន្លែងទៀតហើយ គេថាខ្ញុំហ្នឹងចេះដឹងណាស់ គេមិនឲ្យទៅកន្លែងណា ទៅកន្លែងហ្នឹង។ មានថ្ងៃមួយ គេឲ្យមនុស្សចេញពីផ្ទះ គេឲ្យខ្ញុំ អ៊ីផុន តាដាំ ពូសែម យាយញ៉ នៅក្នុងរោង។ ខ្ញុំហ្នឹងពិតជាជីវិតចង់ស្លាប់មែន គេនាំចេញទៅក្រៅ ចេញទៅកន្លែងម្ដុំត្រពាំង ផ្ទះប្រជាជនហ្នឹងអត់មានអ្នកណានៅទេ។ តែមុនហ្នឹងពេលព្រឹក ថ្ងៃម៉ោងប្រហែលប្រាំបី ប្រាំបួនហ្នឹង ឃើញគេសំលៀងកាំបិត អាកាំបិតដងអ៊ីចឹង ហើយមានក្រង៉ុកបន្តិចល្មមតែផ្ដក់ម៉ា-កឃើងហ្នឹង។ ខ្ញុំឃើញគេសំលៀងតែខ្ញុំឆ្ងល់។ ស្រាប់ដល់ពេល ហ៎ក! គេឲ្យទៅផ្ទះ គេចាក់មីក្រូតែម្ដង។

[១១:១១:៥៤]

ដល់អ៊ីចឹង ខ្ញុំលបមើលតាមរន្ធបង្អួច បណ្ដើរទៅទាំងខ្សែអ៊ីចឹងមែន បណ្ដើរអត់មានចងទេ ព្រោះអីយើងជាប់គុក គេអត់មានឲ្យហួបបាយឯណា មានកម្លាំង បបរមួយវែកវាវអត់មានអង្ករផងហ្នឹង។ អ៊ីចឹងអ្នកទោសទាំងប៉ុន្មានដើរៗល្ងើយ អ៊ីចឹងវាអត់ចង ខ្ញុំឃើញវាចង។ តែខ្ញុំមិនដឹងថា គេទៅសម្លាប់ដោយវិធីណា គ្រាន់តែគេចាក់សោរភ្លាម ខ្ញុំចេញរត់ខ្ទាច់ទៅបង្គន់ បង្គន់ហ្នឹងផ្លូវគេដឹកមនុស្សទៅ។ ខ្ញុំមិនមែនទៅបត់ជើងធំ ខ្ញុំទៅចង់មើលថា ពួកនេះវាសម្លាប់មនុស្សដោយរបៀបណា។ មែនលោក ខ្ញុំអត់ដឹងថាយ៉ាងម៉េចទេ តែបើកាប់ធ្វើម៉េចឈាមប្រឡាក់វាពេញអស់ ពេញខ្លួន។ ធម្មតាតែៗវាសម្លាប់ហើយ វាងូតទឹកនៅត្រពាំងហ្នឹង។ ខ្ញុំគ្រាន់គេបើកភ្លាម ខ្ញុំរត់រ៉េវៗទៅចូលបង្គន់មែន ប៉ុន្តែខ្ញុំអត់មានបត់ជើងទេ ខ្ញុំចង់ដឹងថា គេៗយកមនុស្សទៅវ៉ៃដោយវិធីណា។ ហើយខ្ញុំចង់ដឹងថា គេវ៉ៃម៉េច ប្ដីខ្ញុំក៏ស្លាប់អ៊ីចឹងដែរ ខ្ញុំចង់ដឹងថា គេវ៉ៃ ហើយគេកាប់? ព្រោះអីខ្ញុំ -- ប្ដីខ្ញុំស្លាប់ហើយ ខ្ញុំមិនដឹងថា គេសម្លាប់ដោយវិធីណា ខ្ញុំតាមៗ ឃើញថា អត់ -- ពេល អត់មានឃើញថា ពេលរៀបកាប់ទេ វាយកទៅវ៉ៃឯណាខ្ញុំដឹង តែវាមក

ងូតទឹកត្រពាំង ឃើញឈាមបាញ់ប្រឡាក់ពេញខ្លួនទាំងអស់ អាអ្នកទៅហ្នឹង។ អ៊ីចឹង ខ្ញុំសន្មតថាប្ដីខ្ញុំក៏ស្លាប់ដោយសារគេកាប់ដែរ។ គេអត់មានវ៉ៃនឹងគល់ឫស្សីទេ ពិតជាគេកាប់ដូចដែលខ្ញុំបានឃើញៗគេអ៊ីចឹង។

[១១:១៣:៤៧]

**ស៖** លោកស្រីសាក្សី លោកស្រីទើបតែនិយាយអំពីអ្នកទោសដែលឈ្មោះ យាយផុន ដែលគាត់ប្រាប់លោកស្រីថា ប្ដីរបស់លោកស្រីហ្នឹងគេសម្លាប់នៅកន្លែងណា។ តើលោកស្រីអាចជម្រាបបានទេថា យាយផុន ជាអ្នកណា? ហើយលោកស្រីដឹងអ្វីខ្លះពីគាត់ដែរ?

**ឆ៖** អ៊ុំផុន ហ្នឹងគាត់ជាប្រពន្ធរបស់ ពូឃឿន ដែលស្លាប់ទៅហ្នឹង។ គាត់អត់មានទោសអីទេ កាលបែកភ្លាមហ្នឹងគាត់ប្រធានជនពិការ។ គេថាគាត់ហ្នឹងសេរី ដំរីដូរឡាន គាត់យកដំរីហ្នឹងទៅដូរឡានកសិករថ្មី ដែលចេញពីភ្នំពេញ។ អ៊ីចឹងគេយកគាត់មកអប់រំ។ មុនដំបូងគេឲ្យគាត់នៅដេកក្រៅជាមួយប្រពន្ធគាត់ អ៊ុំផុន ហ្នឹង អ៊ីចឹងបានជាអ៊ុំផុន គាត់ដឹងថា តាសែត គេយកទៅវ៉ៃចោលកន្លែងហ្នឹង ព្រោះអីគាត់អត់មានចូលផ្ទះគុកដូចខ្ញុំទេ។

**ស៖** តើ អ៊ុំផុន ហ្នឹងគាត់នៅរស់រានមានជីវិត ឬក៏គាត់ស្លាប់នៅក្នុងគុកនោះ?

**ឆ៖** មុនៗបែកភ្នំពេញ គេប្រាប់អ៊ុំផុនថា រៀបចំអីវ៉ាន់ទៅ ឲ្យទៅផ្ទះវិញហើយ ព្រោះអីជាប់យូរហើយ រៀនសូត្រហ្នឹងបាន វាដឹងហើយ។ គេក៏បញ្ជូនអ៊ុំផុន ហ្នឹង ហើយមួយកុមារីមួយទៀតឈ្មោះ រឿន ឲ្យទៅ តែខ្ញុំមិនដឹងថាគេនាំគាត់ទៅណា ឮតែថាជូនទៅផ្ទះហើយបាត់រហូតអ៊ីចឹងទៅ។ ព្រោះអីគេបានចេញមុនខ្ញុំ។

[១១:១៥:៥៨]

**ស៖** ឥឡូវនេះ ខ្ញុំចង់ត្រឡប់មកនិយាយអំពីការសួរចម្លើយដែលលោកស្រីបានរៀបរាប់មុននេះ។ តើលោកស្រីអាចជម្រាបបានទេថា មានកម្មាភិបាលប៉ុន្មាននាក់ដែលនៅទីនោះ សួរចម្លើយលោកស្រីនោះ? ខ្ញុំចង់ដឹងថាតើមានមនុស្សប៉ុន្មាននាក់ដែលជាអ្នកសួរចម្លើយនុំង ហើយលោកស្រីស្គាល់ឈ្មោះកម្មាភិបាលគុកដែលសួរចម្លើយលោកស្រីទេ?

**ឆ៖** ចាស ខ្ញុំស្គាល់។ មេគេហ្នឹងឈ្មោះ តាអាន់ បន្ទាប់ទៀតមកដែលសួរចម្លើយខ្ញុំហ្នឹង បន្ទាប់មកឈ្មោះ តាពេញ ហើយមានម្នាក់ទៀតឈ្មោះ តាចេង តែខ្ញុំមិនដឹងថាគេហ្នឹងជាមេដែរឬអត់ទេ ខ្ញុំអត់បានដឹង។ សួរខ្ញុំ -- ចម្លើយខ្ញុំមានពីរបីមេៗគេហ្នឹង។

**ស៖** លោកស្រីបាននិយាយថា មានមនុស្សម្នាក់ចង់យករំពាត់មកវាយលោកស្រី ក៏ប៉ុន្តែមានម្នាក់ទៀតឃាត់កុំឱ្យវ៉ៃ។ អ៊ីចឹងលោកស្រីអាចជម្រាបបានទេ អ្នកណាដែលថាចង់វ៉ៃលោកស្រីហ្នឹង ហើយអ្នកណាជាអ្នកឃាត់មិនឱ្យម្នាក់នុំងវ៉ៃលោកស្រី?

**ឆ៖** ឈ្មោះ ពេញ ដែលទាញបន្ទះផ្តៅប្រុងវ៉ៃខ្ញុំហ្នឹង។ ដល់ហើយមេគេឈ្មោះ អាន់ ហ្នឹងថា “អត់មានទោសអីទេព្រោះប្តី” ថាអ៊ីចឹង ហើយថាឱ្យធ្វើប្រវត្តិរូបហើយ ឱ្យធ្វើការទៅវាគង់តែងាប់ទេ។

[១១:១៨:១៧]

**ស៖** ក្រោយពីលោកស្រីសរសេរប្រវត្តិរូបហើយហ្នឹង គេធ្លាប់យកលោកស្រីទៅសួរចម្លើយទៀតទេ?

**ឆ៖** គេឈប់យកខ្ញុំទៅសួរចម្លើយហើយ គេដាក់គុកខ្ញុំក្នុងផ្ទះហ្នឹងរយៈពេលមួយអាទិត្យទៀត ហើយគេក៏បញ្ចេញខ្ញុំឱ្យធ្វើការជាមួយអ្នកជាប់ទោសដូចគ្នា។ ជាមួយកូនយាយញ៉ៅ ជាមួយតាដាំ ជាមួយពូសែន ជាមួយភឿន ក្រុមគ្រួសារយាយញ៉ៅ ទាំងអស់ គឺគេឱ្យយើងទៅរែកដីៗដំបូក។ រែកដីដំបូកគេបង្គីធំៗណាស់លោក។ ខ្ញុំមានជំងឺទាល់ដល់ថ្ងៃនេះ គឺជំងឺធ្លាក់ស្បូន ដោយខ្ញុំកូនតូចហើយ ខ្ញុំទៅរែកបង្គីធំៗប្រឹងសឹងតែណាណីលើកបង្គីគេរែកមិនចង់បានផង។ ពេលគេឱ្យទៅស្ទូង លោកដឹងអីទេ យើងខំប្រឹងស្ទូង បើមិនអស់តាមកាលកំណត់ គេអត់ឱ្យបបរហូប ហើយពេលស្ទូងបណ្តើរ លោកដឹងទេ? ក្នុងស្រែមានក្អាត់ កូនក្អាត់ខ្ញុំចាប់កូនក្អាត់ញេចឱ្យស្លាប់ហើយដាក់ក្នុងហោប៉ៅ ដើម្បីអី? ដើម្បីមកដល់វិញគេចែកបបរមួយវែក កូនមួយវែក ម៉ែមួយវែក ហើយគេចែកសម្លព្រលឹត អត់បង់អំបិលហ្នឹងឱ្យយើង។ ដោយអាណិតកូន ខ្ញុំក៏រត់យកឆ្នាំងចាស់ៗដែលគេយកកសិករថ្មីទៅ ដែលគេថាដូរភូមិ ឃុំហ្នឹង កសិករថ្មីគាត់មិនរែកចានរែកឆ្នាំងគាត់ទៅ យកអាឆ្នាំងចាស់អ្នកទោសទាំងអស់ ដែលបានធ្វើការជាមួយខ្ញុំហ្នឹង យកមកបន្តុបធ្វើដាំ ហើយបង់អាក្អាត់ហ្នឹងទៅ ហើយនាំកូនចៅហូបទៅ អាហ្នឹងមួយ។ មួយទៀតខែគេៗផ្ទុះកង្កែប លោកដឹងថាយ៉ាងម៉េចទេ គេចោលក្បាលកង្កែប គេចោលក្រពះកង្កែប សួរថាពួកយើងមកធ្វើការយ៉ាងម៉េច ទៅរើសយកមកលាងទឹក ហើយបង់ក្នុងសម្ល អាសម្លគេឱ្យយើងហ្នឹង នាំកូនហូបទៅ ហូបដើម្បីរស់ ក្រែងលោមានជីវិតអាចនៅរស់ បើថាស្លាប់ក៏វាស្លាប់ទៅ។ គេធ្វើបាបយើងគ្រប់ជំហាន។ លោកដឹងថា ពេលដែលគេៗមិនវ៉ៃយើងមែន ប៉ុន្តែខ្ញុំសួរ អ៊ីផុន ហើយពេលមកៗវិញសួរថា “ហេតុអ្វីគេមិនវ៉ៃខ្ញុំ? ហេតុអ្វីគេគ្រាន់តែសម្លុតខ្ញុំ ហើយឱ្យគេប្រើខ្ញុំអ៊ីចឹង?” គេថា “ប្អូនឯងអត់ដឹងទេ អ្នកដែលគេមិនវ៉ៃ គឺគេមិនសម្លាប់ គេទុកយើងប្រើនៅក្នុងគុករហូតដល់ថ្ងៃយើងស្លាប់”។ ដល់ អ៊ីផុន

និយាយអ៊ីចឹង ខ្ញុំៗជឿថាអ្នកដែលគេមិនវ៉ៃអត់ស្លាប់មែន ហើយអ្នកដែលគេវ៉ៃអត់មានអ្នកណារស់ម្នាក់គត់។ គឺរស់តែខ្ញុំប៉ុន្មាននាក់ដែលគេមិនវ៉ៃហ្នឹង ដើម្បីទុកយើងប្រើជាទាសកររបស់វានៅក្នុងគុកហ្នឹង។

[១១:២១:៥១]

**លោក ឌេល លីសាក់៖**

លោកប្រធានខ្ញុំចង់បង្ហាញឯកសារមួយផ្សេងទៀត គឺជាកំណត់ត្រានៅក្រាំងតាចាន់ គឺឯកសារលេខ D157.7, ERN គឺ 00270874, ជាភាសាអង់គ្លេស 00866443, ជាភាសាបារាំង 00872809។ នេះគឺជាកំណត់ត្រាពាក់ព័ន្ធទៅនឹងការសួរចម្លើយសាក្សីរូបនេះនៅក្រាំងតាចាន់។

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះអនុញ្ញាត។

**ចៅក្រម ក្លូឌា ហ្វេនស៍៖**

មុនពេលធ្វើកិច្ចការនេះយើងចង់សួរអំពីភស្តុតាង។ ថាតើវាទទួលបានពីការធ្វើទារុណកម្ម ឬក៏យ៉ាងម៉េចភស្តុតាងនេះ? អ៊ីចឹងតើកំណត់ត្រានេះនិយាយអំពីអ្វីដែរ?

**លោក ឌេល លីសាក់៖**

គឺមានព័ត៌មានពាក់ព័ន្ធទៅនឹងប្រវត្តិរូបៗរបស់គាត់ ហើយនិងមានការសង្ខេបអំពីសំណួរដែលគេសួរចម្លើយគាត់។ ដូច្នេះ គោលដៅនៃការសួរសំណួរពាក់ព័ន្ធនឹងឯកសារនេះ គឺថាមានចំណុចជាច្រើនដែលខ្ញុំចង់សួរទៅសាក្សីដើម្បីចង់ដឹងថាតើគាត់មានព័ត៌មានអំពីរបៀបនៃការថែរក្សាកំណត់ត្រានេះយ៉ាងម៉េច? ហើយគាត់ដឹងថាតើសំណួរដែលគេសួរគាត់ហ្នឹងយ៉ាងម៉េចខ្លះ?

**ចៅក្រម ក្លូឌា ហ្វេនស៍៖**

សូមកុំអាលឱ្យឯកសារអី។ ចាំយើងសម្រេចសិន លោកមន្ត្រីតុលាការសូមយកឯកសារហ្នឹងចេញវិញ យើងសម្រេចសិនចាំយកឯកសារទៅឱ្យគាត់។

*(ចៅក្រមពិភាក្សាគ្នា)*

[១១:២៧:៣៣]

**ប្រធានអង្គជំនុំ៖**

បាទ អង្គជំនុំជម្រះអនុញ្ញាត!

ហើយសូមបញ្ជាក់ថា ការតាំងសំណួរជៀសវាងឱ្យសួរពាក់ព័ន្ធជាមួយនឹងសារធាតុ។

បាទ យកទៅជូនគាត់ដើម្បីពិនិត្យចុះ!

**ចៅក្រម ក្លូឌា ហ្វេនស៍៖**

ខ្ញុំចង់បានការបំភ្លឺ។ ខ្ញុំគិតថា មានការពិភាក្សាដែលនឹងត្រូវធ្វើឡើងពាក់ព័ន្ធទៅនឹងភស្តុតាងដែលទទួលបានដោយការធ្វើទារុណកម្ម។ អ៊ីចឹងកុំឲ្យចូលទៅលម្អិត ប្រសិនបើខ្ញុំយល់ខុស សូមលោកប្រាប់ខ្ញុំ។ លោកចង់ឲ្យសាក្សីបញ្ជាក់អំពីបញ្ហាដែលលោកចង់ទទួលបានការអះអាងឡើងវិញ ឬក៏យ៉ាងម៉េច? ដូច្នេះ លោកចង់តទល់គាត់ជាមួយនឹង -- ទៅនឹងចម្លើយដែលគាត់ឆ្លើយកាលពីសម័យនោះ ឬក៏យ៉ាងម៉េចលោកសហព្រះរាជអាជ្ញា?

**លោក ឌេល លីសាក់៖**

មិនមែនទេ លោកស្រីចៅក្រម។ អនុសញ្ញាស្ដីពីការធ្វើទារុណកម្មមានគោលដៅធ្វើយ៉ាងម៉េចជៀសវាងក្នុងការបង្ហាញភស្តុតាងដែលទទួលបានដោយការធ្វើទារុណកម្ម។ ដូច្នេះ បញ្ហាដែលចង់សួរនៅទីនេះ គឺខ្ញុំចង់ដឹងថាតើគេសួរគាត់អំពីរឿងអ្វី ហើយគាត់ពិតជាបានឆ្លើយអ៊ីចឹងមែនអត់ពេលនុ៎ង? ហើយអ្នកណាជាអ្នកថែរក្សាកំណត់ត្រានេះ? ខ្ញុំអត់មានការ -- អ៊ីចឹងការប្រើប្រាស់ងហ្នឹង គឺថាវាអត់មានពាក់ព័ន្ធទៅនឹងមាត្រា១៥ នៃអនុសញ្ញាទេ។

**ចៅក្រម ក្លូឌា ហ្វេនស៍៖**

អត់មានបញ្ហាអ្វីទេ ថាតើគាត់ឆ្លើយ ឬមិននោះនៅពេលនោះ ក៏ប៉ុន្តែវាអាចពាក់ព័ន្ធ វាអាចមានបញ្ហានៅពេលដែលយើងសួរគាត់ថា តើគាត់ឆ្លើយអ៊ីចេះ ឆ្លើយអ៊ីចឹង ឬក៏យ៉ាងម៉េច?

[១១:២៩:៣៥]

**លោក ឌេល លីសាក់៖**

ខ្ញុំមិនចង់ផ្ទៀងផ្ទាត់ថា គាត់ឆ្លើយអ៊ីចឹង ឬក៏មិនឆ្លើយអ៊ីចឹងទេ។ ខ្ញុំគិតថាយើងអាចសួរបាន គឺសួរចង់ដឹងថា គេសួរគាត់អំពីរឿងអ្វី ហើយតើវាពិតជាឆ្លុះបញ្ចាំងនៅក្នុងឯកសារហ្នឹងមែនក៏អត់? ខ្ញុំអត់មានប្រើព័ត៌មានដែលគាត់បានឆ្លើយយ៉ាងម៉េចៗទេ គ្រាន់តែសួរថាគេសួរគាត់អំពីអ្វី?

**សួរដោយលោក ឌេល លីសាក់៖**

**ស៖** លោកស្រីសាក្សី ទំព័រដែលពាក់ព័ន្ធទៅនឹងលោកស្រីនេះ សូមលោកស្រីពិនិត្យមើល។ ខ្ញុំបានបញ្ជាក់ហើយគឺលេខ 00270874។ ខ្ញុំចង់ដឹងថានៅពេលហ្នឹងមានអ្នកណាកត់ត្រាទេ មានអ្នកណាសរសេរចម្លើយទេនៅពេលដែលគេសួរចម្លើយលោកស្រីនោះ?

**ឆ៖** មានគេកត់, ឈ្មោះ អាន់ អ្នកកត់។

**ស៖** តើលោកស្រីចាំពីអក្សរដែលគេកត់ត្រានៅពេលហ្នឹងទេ លោកស្រីអាចចាំទេថាអក្សរហ្នឹងជាអក្សររបស់ អាន់?

**ឆ៖** ខ្ញុំ -- គេសួរយើងនៅឆ្ងាយ គេអ្នកសរសេរនៅចុងតុម្ខាងនោះ យើងអត់បានដឹងថា -- ដឹងជាអក្សរអ្នកណាទេ តែខ្ញុំសូមជម្រាបលោកថា រឿងមួយដែលបញ្ជាក់ថា ទោះបីយើងមិនឆ្លើយ ក៏គេសរសេរដាក់។ អាហ្នឹងខ្ញុំសូមបញ្ជាក់ថា ថ្ងៃមួយគេឲ្យខ្ញុំយកបាយឲ្យជ្រូកស៊ី ហើយផ្ទះចង្ក្រានបាយគេហ្នឹង ហើយនិងកន្លែងសួរចម្លើយ ប្រហែលជា៥០ម៉ែត្រយ៉ាងឆ្ងាយចុះ តែវាមានដាំដើមដំឡូងមី ថាមើលទៅអត់ឃើញទេ ព្រៃស៊ុបទ្រុបចាស។ ខ្ញុំឮគេសួរចម្លើយ ឮពេញត្រចៀក គេស្រែកឮៗ ព្រោះអីគេអត់ខ្លាចខ្ញុំដឹងទេ ព្រោះអីគេដឹងថាខ្ញុំវាៗគុកអស់ជីវិតហើយ មិនអាចចេញទៅណាបានទេ សួរកសិករថ្មីមួយគេសួរថា "ហ្អែងនៅភ្នំពេញ ហ្អែងពាក់ស័ក្តិ៣អត់?" កសិករថ្មីហ្នឹងថា "អត់ទេ ខ្ញុំអត់មានធ្វើទាហានពាក់ស័ក្តិប៉ាក់អីទេ"។ គ្រាន់តែពាក្យប៉ុណ្ណឹងណាលោក ខ្ញុំឮសន្ទឹកវ៉ៃខ្ទឹបៗ វ៉ៃអស់ចិត្តបានសួរទៀតថា "ហ្អែងពាក់ស័ក្តិ៣ដែរអត់?" ឆ្លើយថា "អត់" វ៉ៃបន្តទៀត។ រហូតដល់អ្នកទោសវាឈឺដល់ចិត្តហើយ វាបងប្អូនងាប់ហើយ ឆ្លើយថា "ខ្ញុំពាក់ស័ក្តិ៣មែន" ដើម្បីឈប់ឲ្យគេវ៉ៃ អាហ្នឹងខ្ញុំសូមបញ្ជាក់លោក។

[១១:៣៣:០៥]

អ៊ីចឹងចម្លើយរបស់ខ្ញុំ ស្រេចតែគេដាក់ក៏មិនដឹង អាហ្នឹងៗតាមចិត្តខ្ញុំដឹង ព្រោះអីវ៉ៃអាម្នាក់នោះឲ្យឆ្លើយស័ក្តិ៣តាមៗគោលបំណងរបស់វាហើយហ្នឹង។ អ៊ីចឹងសំណួរដែលវាសួរខ្ញុំ វាអាចសរសេរទៅជាយ៉ាងម៉េចក៏បានដែរ អាហ្នឹង ខ្ញុំគិតថាអ៊ីចឹង។

**ស៖** សំណួរចុងក្រោយពាក់ព័ន្ធនឹងកំណត់ត្រានេះ និយាយ -- នៅទីនេះ គឺយើងនិយាយអំពី កង ដែលជាប្រធានមន្ទីរពេទ្យ២២។ លោកស្រីចាំទេ តើគេមានសួរចម្លើយលោកស្រីពាក់ព័ន្ធនឹងឈ្មោះ កង ហ្នឹងទេ នៅពេលដែលគេយកលោកស្រីទៅសួរចម្លើយនោះ?

**ឆ៖** អត់មានសួរ ៗតែរឿងប្តីថាដឹកនាំធ្វើអីៗខ្លះ។

**លោក ខេល លីសាក់៖**

លោកប្រធាន ខ្ញុំចង់សុំការអនុញ្ញាត១០នាទីបន្ថែមទៀតដើម្បីសួរ បើសិនជាអាច ខ្ញុំនឹងអាចសួរឥឡូវនេះតែម្តង ឬបើមិនអ៊ីចឹងទេ បន្ទាប់ពីការសម្រាកក៏បានដែរលោកប្រធាន អាស្រ័យលើការសម្រេចរបស់លោកប្រធាន ប៉ុន្តែខ្ញុំសុំពេលវេលាបន្ថែម១០នាទី។

**ប្រធានអង្គជំនុំ៖**

បាទ អង្គជំនុំជម្រះអនុញ្ញាតឥឡូវនេះចុះ ព្រោះដោយសារយើងព្រឹកមិញយើងមានការចូលមកយឺតដោយសារមូលហេតុបញ្ហាស្ទះចរាចរណ៍។ បាទ សូមអញ្ជើញ បាទ!

**លោក ខេល លីសាក់៖**

សូមអរគុណលោកប្រធាន។

**សួរដោយលោក ខេល លីសាក់៖**

**ស៖** លោកស្រីសាក្សី លោកស្រីឆ្លើយថា លោកស្រីឃើញគេនាំមនុស្សចេញទៅសម្លាប់។ លោកស្រីក៏បាននិយាយផងដែរថា គេចាក់ភ្លើងនៅពេលនុ៎ង។ អ៊ីចឹងខ្ញុំចង់សួរសំណួរមួយចំនួនពាក់ព័ន្ធទៅនឹងការសម្លាប់អ្នកទោសនៅក្រាំងតាចាន់។ តើលោកស្រីអាចជម្រាបបានទេថា គេនាំអ្នកទោសពីកន្លែងឃុំឃាំងចេញហ្នឹង ញឹកញាប់ប៉ុនណាដែរ នៅពេលដែលលោកស្រីជាប់ឃុំដែរនោះ? លោកស្រីឃើញអ្នកទោសគេនាំយកចេញទៅ ទៅខាងលិចគុកហ្នឹង លោកស្រីបាននិយាយអម្បាញ់មិញ ថាទៅខាងលិច។ អ៊ីចឹងលោកស្រីឃើញហ្នឹង ញឹកញាប់កម្រិតណាដែរ?

[១១:៣៦:១០]

**លោកស្រី វង សារុន៖**

**ឆ៖** ចាស ញឹកញាប់រហូតដល់ពេញរណ្ដៅគេពីរបីកន្លែងហ្នឹង ហើយបន្ទាប់មក ឃើញនាំអ្នកទោសចេញទៅក្រោយហើយ ប៉ុន្តែក្រៅហ្នឹងក្នុងរបងទី២ ដែលភូមិប្រជាជន គេអត់ឲ្យនៅទេ កន្លែងហ្នឹងគេ -- ១គីឡូម៉ែត្របួនជ្រុងកន្លែងក្រាំងតាចាន់ហ្នឹង មិនអនុញ្ញាតឲ្យប្រជាជនចេញចូល ទោះបីមានផ្ទះមានសម្បែងក៏ដោយ។ ចាស គេយក ពេលដែលចេញពេញគ្រហុកកន្លែងៗមន្ទីរគេហ្នឹងហើយ គេទៅយកទៅវ៉ៃខាងហ្នឹង។ ខ្ញុំសូមជម្រាបលោកថា ខ្ញុំនឹងនិយាយប្រាប់លោករឿងមួយ ដែលអាណោចអាធ័មជាទីបំផុត ខ្ញុំដេកនៅតែយល់សប្តិឃើញនឹងភ្នែក។ ថ្ងៃមួយ គេយកកងទ័ពម្នាក់ យកទៅដេកនៅក្បែរខ្ញុំ។ ខ្ញុំលបសួរតិចៗហ្នឹង ថានឹកផ្ទះគាត់មកលែងផ្ទះ ដល់ពេលគេចាប់ គេមិនចាប់ទៅកងណា គេចាប់មកដាក់ក្រាំងតាចាន់។ ពេលដែលគេទៅសួរចម្លើយ លោកដឹងម៉េចទេ? វ៉ៃខ្លាំងណាស់ លោកអើយ! ហ្នឹងអ្នកទោសដេកជាប់នឹងខ្ញុំ។ វ៉ៃៗថាគ្មានសាច់ម៉ែបង្កើត។ ពេលបណ្ដើរមកវិញ មួយយប់ទាល់ភ្លឺ កងទ័ពនោះយំ។ លោកដឹងថាម៉េចទេ យំថាម៉ែអើយជួយផង ម៉ែ។ ខ្ញុំពិចារណាទៀត អឺ! ដល់តែមានគ្រោះថ្នាក់អីដល់ជីវិត ឬក៏ឈឺខ្លាំង មិនដែលហៅឪជួយទេ ហៅតែម៉ែ។ យំទាល់ភ្លឺ។ អ្ហ៎! ដល់ក្រោយគេយក

ទៅសួរចម្លើយទៀតលោកដឹងយ៉ាងម៉េចទេ? ហាក់ៗរំលងរបងលួស ពេលនោះ ពួកខ្ញុំប៉ុន្មាននាក់អ្នកទោស ទៅរែកដីដំបូកនៅពីខាងលិច ខាងលិចកន្លែងវាសួរចម្លើយហ្នឹង រំលងស្រែមួយ។ បើខ្ញុំមិនច្រឡំ ខ្ញុំថា មានតែពេលសួរចម្លើយទេ ដែលអ្នកទោសអាចរត់ ព្រោះអីគេអត់ចងទេ។ ដល់ពេល -- អើ គេវ៉ៃខ្លាំង ហើយ រត់ហាក់របង។ អារបងទី១ ហាក់រួច របងទី២ ភិតៗរួច។ លោកដឹងថា វារត់រួចទេ បើកុំមាន អ្នករែកដីនៅកន្លែងហ្នឹង រត់រួច ហ្នឹងហើយកងទ័ព។

[១១:៣៨:៤១]

ដល់ពេលហើយដឹងយ៉ាងម៉េច គេស្រែកថា អាពួកកាប់ដី ហ្អែងនៅធ្វើអី មិនដេញ។ លោកដឹង ម៉េចទេ? ចបកាប់អីអ៊ីចឹង រត់កាប់ភិតៗ។ ទីចុងបញ្ចប់បាន លោកដឹងថាគេធ្វើអីទេ។ គេវ៉ៃខ្លាំងណាស់ លោកអើយ។ ទីចុងបំផុត សន្លប់ គេចងជើងអូស អូសតាំងពីក្នុងស្រែ រហូតដល់របងលួសពីរជាន់ លោកគិតមើលថាវាដាច់ប៉ុន្មាន។ ខោអាវគ្មានទេ ដាច់ រយ៉ីរយ៉ៃសាច់ឈាម ខ្វាចអាបន្លាលួសហ្នឹង ឈាមហូរហាម ហើយគេយកមកដាក់ដេកជិតខ្ញុំវិញដដែល។ នេះជាព្រឹត្តិការណ៍ដែលឃើញនឹងភ្នែក ជាមួយ។ លោកដឹងទេ វាឃំ មិនដឹងថាវាឈឺប៉ុន្មាន ពិតមែនតែមិនមែនប៉ះចំលើខ្លួនយើង។ ប៉ុន្តែ ខ្ញុំពិចារណា អាហ្នឹងឃើញជាក់ស្តែងនឹងភ្នែក។ ស្អែកឡើង គេយកម៉ូតូឌុប គេថាជូនទៅអង្គភាពវិញ ប៉ុន្តែម្នាក់ជិះពីក្រោយ កាន់អាកា។ ខ្ញុំគិតថាបើរត់ក៏រត់មិនរួចដែរ មានតែគេយកទៅវ៉ៃចោល រឿងទៅ អង្គភាព ទៅអង្គអី គ្មានទេ ខ្ញុំឈប់ជឿហើយ ព្រោះអីខ្ញុំជាប់គុកយូរ ខ្ញុំដឹង ដឹងពីរបៀបវាថា អាឲ្យទៅ មិនឲ្យទៅ។ អាហ្នឹងរឿងមួយលោក។

ជាក់ស្តែងមួយទៀត នារីកសិករថ្មី គេឲ្យទៅស្ទូងជាមួយខ្ញុំ លោកដឹងម៉េចទេ? វាចង់រត់។ វាថា ដែល "អ៊ីរ៉ុន អ្នំា ខ្ញុំគិតថាសូមនោមបន្តិច" ខ្ញុំថា "អឺ ទៅនោមទៅអូនអើយ ជិតៗណា កុំទៅឆ្ងាយពេក ខ្លាចគេធ្វើបាប"។ គុម្ពោតព្រៃមួយក្នុងដំបូក លោកគិតមើល៍ មានតែទន្ទ្រានខែត្រទេ ហេតុអីក៏យើងមើល អត់ឃើញ។ គេឲ្យពួកខ្ញុំប៉ុន្មាននាក់ហ្នឹង គេថា "តែរកមិនឃើញវ៉ៃចោលតែទាំងអស់ អាអ្នកស្ទូងហ្នឹង"។ ទៅរកអត់ឃើញ មិងដឹងថាមានអីបាំងមិនឲ្យឃើញ យើងឃើញ។ ដល់តែពេលគេទៅរក នៅលើដើម ទន្ទ្រានខែត្រហ្នឹង គេរែកទៅឃើញ។ វ៉ៃ លោកអើយ វ៉ៃអូសជើង សំពត់ដាច់ប៉ុន្មាន យើងស្រីដូចគ្នា យើងដឹងហើយ។

[១១:៤០:៤០]

នេះ គឺជា -- ដែលយើងបានឃើញ បានដឹង បានឮនឹងភ្នែក ចំពោះព្រឹត្តិការណ៍ដែលពួកៗវាធ្វើ

បាបអ្នកទោស។ ច្រើនណាស់ដែលខ្ញុំដឹងជាក់ស្តែងហើយនឹងភ្នែក ព្រោះអីខ្ញុំនៅច្រើនឆ្នាំណាស់ ក្នុងគុកនេះ។ អ៊ីចឹង វាមិនមែនពិតមកលើរូបខ្ញុំមែន ប៉ុន្តែវាធ្វើឲ្យខ្ញុំរន្ធត់ខ្លាំងណាស់។ អ៊ីចឹង បងប្អូនខ្ញុំ ក៏អាចគេធ្វើបាបអ៊ីចឹងដែរ ខ្ញុំនឹកឃើញថានៅស្រុក មិនដឹងម៉ែឪ បងប្អូនខ្ញុំ គេធ្វើយ៉ាងម៉េចទេ ព្រោះអីខ្ញុំមកខ្លួនមួយ ក្បាលមួយតែឯងតាមប្តី។

**ស៖** សូមអរគុណលោកស្រីសាក្សី។ លោកស្រីបាននិយាយថា លោកស្រីបានឃើញអ្នកយាមសំលៀងកាំបិត ហើយមានអ្នកនាំមនុស្សទៅជីកផ្នូរ ហើយលោកស្រីក៏ឃើញអ្នកយាមសម្អាតឈាមដែលប្រឡាក់ជាប់នឹងដាវ។ អ៊ីចឹង អ្នកណាជាអ្នកសំលៀងដាវហ្នឹង? ហើយបន្ទាប់មកទៀត អ្នកណាជាអ្នកជូតសម្អាតឈាមដែលប្រឡាក់នៅលើដាវហ្នឹង? តើលោកស្រីអាចជម្រាបបានទេ?

**ឆ៖** ខ្ញុំគិតថា ខ្ញុំតក់ក្រហល់ចង់ដឹងតែមួយប៉ព្រិចភ្នែកទេ ខ្ញុំអត់បានគិតថា ណាគេហ្នឹង? ស្គាល់គេច្បាស់លាស់ទេ ព្រោះអីវាមានព្រៃៗរាងអ៊ីចឹង ហើយយើងក៏អត់មានពេលណាទៅសង្កេតដែរ។ គ្រាន់តែឃើញតែមួយភ្លឹបហ្នឹង យើងគេចខ្លួនមកវិញបាត់។

**ស៖** តើលោកស្រីអាចជម្រាបបានទេ នៅពេលណាដែលលោកស្រីចាកចេញពីក្រាំងតាចាន់? ហើយលោកស្រីអាចរស់រានមានជីវិតពីក្រាំងតាចាន់ហ្នឹង បានដោយរបៀបណាដែរ?

[១១:៤៣:២៣]

**ឆ៖** ចាស ពេលៗរដូវច្រូត គេឲ្យខ្ញុំច្រូត ឲ្យបោក ឲ្យរោយស្រូវអស់ហើយ ប៉ុន្តែដល់ពេលដាក់ជង្រុកខ្ញុំ ខ្ញុំចាប់ផ្តើមឆ្ងល់ ចេះតែឮសូរស្នូរកាំភ្លើងៗល្វើយៗ ចាស។ បានប៉ុន្មានថ្ងៃ ស្រាប់ពួកអ្នកគុកហ្នឹង គេថា "យើងអ្នកឆ្អាស រៀបចំអីវ៉ាន់ទៅ ប្រុងប្រៀបចេញទៅទៀត នៅនេះអត់បានទេ" ចាស។ ដល់ពេលយប់មួយ គេចាប់ផ្តើម -- អ្នកដែលគេមិនទុក គេវាយចោល។ គេធ្វើយ៉ាងម៉េច គេដាក់មីក្រូនិយាយថា ឥឡូវបងប្អូនយើង បើកន្លែងនេះយើងអត់មានស្ថិរភាពទេ អ៊ីចឹងយើងនឹងផ្លាស់ទីតាំងទៅកន្លែងផ្សេង ចាស។ អ៊ីចឹង កណ្តាលយប់ យើងនឹងចេញទៅ។ ដល់ពេលគេនិយាយអ៊ីចឹងហើយ ពួកខ្ញុំក៏អត់មានអ្នកណាដេកដែរ នឹកឃើញថា យើងធ្លាប់ដឹងថាគេមុខតែយកទៅវៃចោល អត់មានដេកទេ នៅបញ្ឈរភ្នែកចាំតែគេហៅ ន្ទាលនឹងងាប់ទេ។ ដល់ពេលអ៊ីចឹង គេអត់ហៅយើងទេ គេហៅអ្នកទោសដែលគេកំណត់ថាគេយកទៅវៃចោល។ ក្នុងនោះមាន អារ៉ុម ដែលខ្ញុំនិយាយថា មិត្តភក្តិដែលខ្ញុំសួរ ដែលខ្ញុំសួរហើយ គេដាក់គុកខ្ញុំទៀត។ វាមានកន្សែងស្លូត្រ ដែលខ្ញុំស្គាល់ច្បាស់ ទៅធ្វើការជាមួយគ្នា។ ដល់ពេលគេនាំទៅ គេថា "ទៅផ្លាស់កន្លែង អ៊ីចឹងឲ្យខាងនេះទៅមុន ពួកអ៊ីរុន ឯងហ្នឹងចាំជិតភ្លឺចាំចេញ"។ ពួកខ្ញុំអត់មានដេក

ទេ នឹកឃើញថា មិនដឹងថាចេញទៅកន្លែងណា គេវៃចោលកន្លែងណា។ ដល់តែពេលគេឲ្យអ្នកមុនចេញទៅ ពួកខ្ញុំគេអត់ឲ្យចេញ នៅដល់ភ្លឺៗ គេថាទៅរែកទឹកមក គិតគូបបរគិតគូអីហ្នបទៅ។ ដល់ពេលអ៊ីចឹងខ្ញុំចេញទៅដងទឹកនៅមាត់ត្រពាំង អាមាត់ត្រពាំងខ្ញុំឃើញគេយកវៃមនុស្សៗទៅចូលតាមរន្ធហ្នឹង។ ខ្ញុំទៅដល់កន្លែងហ្នឹងឃើញកន្សែងស្បូត្រ ទាក់ហែកបន្ទាបង្ក្រាប។ អ៊ីចឹង ខ្ញុំនឹកឃើញថា "អូ៎! រ៉ុម អញគេយកវៃចោលហើយ!" កំណត់ក្នុងចិត្តច្បាស់អ៊ីចឹងហ្នង ថាពិតជាគេយកទៅវៃចោលអត់មានដូរកន្លែងណាទេ ព្រោះអីកន្សែងទាក់ជាមួយបន្លាហើយ បន្លាផ្ទូវ។ អ៊ីចឹងបានសេចក្ដីថាពេលដែលទាញទៅហ្នឹងវាប្រតាយប្រទង់គ្នាហើយ បានជាកន្សែងស្បូត្រហ្នឹងនៅជាប់ ហើយខ្ញុំកំណត់ថា គេអត់ដូរកន្លែងទេ គេវៃចោល។ ខ្ញុំក៏មិនដឹងថ្ងៃណាគេវៃចោលដែរ។

[១១:៤៦:១៦]

ហើយរហូតដល់ពេល ផ្ទេរចេញទៅមែនទែនហើយ គេឈប់ថាយកទៅវៃចោលហើយ។ ពេលនោះអ្នកទោសនៅមានខ្ញុំ និង អ៊ីហាន។ អ៊ីហាន ដែលពេលជាប់គុកហ្នឹងកូនវាបីខែ។ កូនខ្ញុំហ្នឹងជាងមួយខួប ហើយមកជាប់ប៉ុន្មានឆ្នាំហើយ កូនវាចេះដើរ កូនខ្ញុំក៏ទ្រើសដែរហើយ បណ្ដើរដើរបានហើយ ជាប់យូរឆ្នាំហើយ។ ដល់ហើយគេនាំទៅតាមប្រជាជនយើងរត់ រត់ឡើងទៅលើហ្នឹង។ គេក៏អត់មានឲ្យខ្ញុំរត់ហើយទី១ ក៏មិនដឹងរត់ទៅកន្លែងណា អត់ស្គាល់អ្នកស្រុកអ្នកភូមិ មិនដឹងថាដីហ្នឹងកន្លែងណា បើអត់ដែលទៅផង។ អ៊ីចឹង សុខចិត្តគេប្រើឲ្យទៅណាទៅហ្នឹងនឹងគេ។ ទៅពីរនាក់អ៊ីហាន។ ទៅដល់ឆ្ងាយដល់ពោធិ៍សាត់ អ៊ីហាន គេសំណាងគេល្អ គេជួបប្ដីគេ។ គេក៏ឲ្យអ៊ីហានហ្នឹងទៅប្ដីគេទៅ។ ដោយឡែកតែខ្ញុំមនុស្សកម្សត់ក្រាស់ សូម្បីតែបងប្អូនញាតិសន្ដាន ដែលគេរត់ពេញភូមិពេញដីហើយ អត់មានឃើញអ្នកណាម្នាក់សោះ។ ដល់ពេលរត់បានប៉ុន្មានខែ ដល់ពេលថាវៀតណាមមកដល់ហើយ គេបាញ់ គេទម្លាក់គ្រាប់បែកឡានហោះបាញ់ពីលើហ្នឹង ពេលហ្នឹងហើយដែលខ្ញុំរត់ចេញរួច ពីរនាក់កូនខ្ញុំ។ មកបានវិលត្រឡប់មកស្រុកភូមិវិញ។ ដល់ស្រុកខ្ញុំនៅ គេសាបហើយៗខ្ញុំមកដល់ក្រោយ។ ហ្នឹងជាប្រវិត្តដែលខ្ញុំបានមករស់ បានរស់ត្រឡប់វិលវិញ។

**សៈ** ខ្ញុំចង់សួរសំណួរចុងក្រោយ លោកស្រីសាក្សី។ គឺខ្ញុំយោងទៅលើឯកសារ E319/20.2 ខ្ញុំចង់និយាយអំពីអ្នកទោសដែលនៅរស់រានមានជីវិត។ ក្នុងនោះមានការនិយាយថាលោកស្រីមានទំនាក់ទំនងជាមួយនឹងប្រធានគុកឈ្មោះ អាន់។ តើពិតជាត្រឹមត្រូវទេ? លោកស្រីពិតជាមានរឿងរ៉ាវស្នេហាជាមួយនឹងឈ្មោះ អាន់ ទេ? ហើយគឺអ្នកទាំងពីរបានព្រមព្រៀងគ្នា ឬក៏មានការបង្ខំលោកស្រីក្នុងរឿង

នេះ? អ៊ីចឹង លោកស្រីអាចពន្យល់បានទេថា លោកស្រីពិតជាមានទំនាក់ទំនងស្នេហាជាមួយឈ្មោះ អាន់ ដែលជាមេគុកនោះ?

[១១:៤៨:៥១]

**ឆ៖** ចាស ខ្ញុំឆ្លើយថា នេះគ្រាន់តែពាក្យចចាមអារាមទេ ធម្មតាយើងអ្នកជាប់គុក ហើយគេមេ ប៉ុន្តែតាមពិតគឺខ្លួនខ្ញុំមិនបានទៅទាក់ទងប្រឡាក់ប្រឡូសជាមួយអ្នកវ៉ៃប្តីខ្ញុំចោលឡើយ។ ខ្ញុំអត់ភ្លេចសារ-ធាតុថាខ្ញុំជាអ្នកទោស ហើយប្តីខ្ញុំត្រូវគេវ៉ៃចោល។ ហេតុនេះ ខ្ញុំមិនអាច។

**លោក ឌេល លីសាក់៖**

សូមអរគុណលោកស្រីសាក្សី។ លោកប្រធានខ្ញុំអស់សំណួរហើយ សូមអរគុណលោកប្រធាន។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ ឥឡូវនេះដល់ពេលសម្រាកថ្ងៃត្រង់ហើយ អង្គជំនុំជម្រះប្រកាសសម្រាកចាប់ពីពេលនេះតទៅរហូតដល់ម៉ោងមួយសាមសិបនាទី រសៀលនេះ សូមអញ្ជើញចូលវិញ ដើម្បីបន្តកិច្ចដំណើរការសវនាការ។

មន្ត្រីរដ្ឋបាលតុលាការសម្រុះសម្រួលផ្តល់កន្លែងសម្រាកនៅបន្ទប់រង់ចាំសម្រាប់សាក្សីនៅក្នុងអំឡុងពេលសម្រាកថ្ងៃត្រង់ និងឲ្យអញ្ជើញគាត់រួមទាំងបុគ្គលិកអង្គការ ធី.ភី.អូ មកកាន់កន្លែងផ្តល់សក្ខីកម្មនៅក្នុងបន្ទប់សវនាការនេះនៅវេលាម៉ោងមួយ និងសាមសិបនាទី។

បង្គាប់ឲ្យអនុរក្សមន្ទីរឃុំឃាំងនាំខ្លួនលោក ខៀវ សំផន ទៅកាន់បន្ទប់សម្រាកខាងក្រោមសាលសវនាការនេះ និងបង្គាប់ឲ្យនាំខ្លួនគាត់ត្រឡប់ចូលរួមសវនាការនៅក្នុងបន្ទប់សវនាការនេះវិញនៅរសៀលនេះឲ្យបានមុនម៉ោងមួយ សាមសិបនាទី។

សម្រាកចុះ!

**ក្រឡាបញ្ជី៖**

សូមអញ្ជើញក្រោកឈរ!

*(សវនាការសម្រាកពីម៉ោង ១១:៥០ នាទី ដល់ម៉ោង ១៣:៣៣ នាទី)*

[១៣:៣៣:៤៩]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ។ ជាដំបូងនេះតើអស់លោក លោកស្រី មានសំណួរអ្វីចង់សួរដល់សាក្សីរូបនេះដែរឬទេ? បើមានសូមអញ្ជើញបាទ។

សូមអញ្ជើញលោកស្រីចៅក្រម ហ្វេនស៍!

**ចៅក្រម ក្លូឌា ហ្វេនស៍៖**

សូមអរគុណលោកប្រធាន។ មុននឹងខ្ញុំសួរសំណួរទៅកាន់លោកស្រី ខ្ញុំចង់ជម្រាបលោកស្រីពីរចំណុច។ ទី១ បើសិនណាជាលោកស្រីមិនចាំរឿងរ៉ាវណាមួយទេ ដោយសារវាកើតឡើងយូរមកហើយ គឺថាមិនបញ្ហាអីទេ លោកស្រីគ្រាន់តែឆ្លើយថា ខ្ញុំមិនចាំទេ។ ហើយបញ្ហាទី២ បើសិនណាលោកស្រីមានវិវេកភាព គឺថាលោកស្រីអាចស្នើសុំសម្រាកបាន ក្រែងលោមានអារម្មណ៍ទុក្ខសោកអីរំជួល។ លោកស្រីយល់ពីចំណុចនេះទេ?

[១៣:៣៥:១២]

**លោកស្រី វង សារុន៖**

ចាស យល់។

**សួរដោយចៅក្រម ក្លូឌា ហ្វេនស៍៖**

**ស៖** បើយល់ហើយ អ៊ីចឹងសូមចាប់ផ្តើម ខ្ញុំចាប់ផ្តើមសួរតែម្តង។ ជាសំណួរមួយសួរនូវអ្វីដែលលោកសហព្រះរាជអាជ្ញាបានសួរទៅលោកស្រីកាលពីព្រឹកមិញ។ លោកស្រីបានជម្រាបនូវរឿងរ៉ាវមួយចំនួនដែលចៅក្រមមិនបាន ក៏ដូចជាអ្នកដទៃទៀតមិនបានស្តាប់ឮរឿងរ៉ាវថ្មីៗ ដូចលោកស្រីជម្រាបនោះទេ។ ដូច្នេះខ្ញុំសួរ សូមសំណួរទៅលើអ្វីដែលតំណាងសហព្រះរាជអាជ្ញាបានសួរកាលពីព្រឹកមិញនេះហើយ។ សូមលោកស្រីនិយាយឡើងវិញមកថា លោកស្រីត្រូវបានគេនាំខ្លួនយកទៅក្រាំងតាចាន់នៅពេលណា ថ្ងៃខែឆ្នាំណាដែរ បើចាំ? ហើយដោះលែងមកវិញ រួចខ្លួនមកវិញនៅពេលណាដែរ?

**លោកស្រី វង សារុន៖**

**ឆ៖** ចាស ខ្ញុំសូមឆ្លើយថា ពេលដែលគេយកខ្ញុំមកដាក់នៅគុកក្រាំងតាចាន់ គឺខ្ញុំវាអត់ចាំបានថ្ងៃខែអីពិតប្រាកដទេ។ តែដល់ពេលរួចទុក្ខទោសមកវិញក៏គ្មានអ្នកណាលែងខ្ញុំដែរ គឺពេលដែលវៀតណាមចូលដល់ គេនាំយើងរត់ យើងរត់គេចចេញពីគេ ពេលដែលមានអំណោយផលឲ្យថា វៀតណាមមកដល់ហើយ គេទម្លាក់គ្រាប់បែកតាមយន្តហោះហ្នឹង។ អ៊ីចឹងបានខ្ញុំរត់គេចមករួច។

[១៣:៣៧:១២]

**ស៖** អរគុណច្រើន។ លោកស្រីមិនចាំពេលវេលាច្បាស់លាស់ ប៉ុន្តែគិតឆ្លើយត្រឹមឆ្នាំទៅចុះ។ ឆ្នាំ បើគិតជាឆ្នាំ ក្នុងឆ្នាំណា? ហើយវានៅក្នុងរដូវកាលណាជាដើម។ល។

**ឆ៖** ចាស ដោយព្រឹកមិញគាត់សួរខ្ញុំមិនអស់សេចក្តីថា ខ្ញុំទៅនៅពេទ្យតាកែវ។ អ៊ីចឹងបានជាខ្ញុំឆ្លើយថា ១៩៧៥ គឺគេបញ្ជូនខ្លួនខ្ញុំទៅគុកក្រាំងតាចាន់។ ប៉ុន្តែបើពេលខ្ញុំនឹកឃើញ សំណួរនេះអត់បានសួរខ្ញុំ ទើបខ្ញុំឆ្លើយថា ពេលដែលរយៈពេលគេបញ្ជូនឱ្យទៅនៅពេទ្យតាកែវ គឺរយៈពេលពីរឆ្នាំ ទើបបានគេបញ្ជូននាងខ្ញុំមកគុកក្រាំងតាចាន់។

**ស៖** ខ្ញុំសួរសំណួរពាក់ព័ន្ធទៅនឹងការសម្លាប់មនុស្ស។ ខ្ញុំមានសំណួរមួយពាក់ព័ន្ធទៅនឹងបរិបទនេះ។ លោកស្រីឆ្លើយថា លោកស្រីបានឃើញដើមឈើ និងឃើញទីកន្លែងដែលលោកស្រីបានចោទប្រកាន់ថា ប្តីលោកស្រីអាចត្រូវបានគេសម្លាប់នៅទីនោះ។ លោកស្រីបានឃើញសាកសព ប៉ុន្តែលោកស្រីមិនអាចកំណត់អត្តសញ្ញាណណាបានច្បាស់ថា សាកសពណាជាប្តីលោកស្រីបានទេ។ អ៊ីចឹងសំណួររបស់ខ្ញុំក្នុងចំណោមសាកសពទាំងអស់ហ្នឹង តើសាកសពទាំងអស់ហ្នឹងត្រូវគេសម្លាប់ហើយ គ្រាន់តែគេផ្តេកចោលនៅលើដីតែម្តង ឬក៏ទម្លាក់ចូលក្នុងរណ្តៅ ឬក៏ត្រូវគេកប់ ឬក៏យ៉ាងម៉េច? តើស្ថានភាពរបស់សពទាំងអស់នោះគឺ ស្ថិតនៅរបៀបម៉េចដែរ?

[១៣:៣៩:១៦]

**ឆ៖** ចាស ពេលដែលខ្ញុំបានឱកាសចូលទៅដល់កន្លែងគេសម្លាប់ប្តីខ្ញុំហ្នឹង មិនមែននៅលើវាលទេ គឺគេជីកគ្រហុក គ្រហុករាងវែង។ ហើយពេលដែលឃើញសាកសពនោះមិនបានថា ផ្តេកក្បាលទៅណាទៅហ្នឹងដូចគ្នាទេ គឺវា -- បើខ្ញុំគិតថាប្រហែលជាគេសម្លាប់ហើយ គេច្រានចូលទៅ វាដួលទៅយ៉ាងម៉េចយ៉ាងហ្នឹងអ៊ីចឹងទៅ តាមសភាពខ្មោចដួលអ៊ីចឹងទៅ។

**ស៖** ខ្ញុំមិនមានចំណាប់អារម្មណ៍ជាក់លាក់ទៅនឹងទីកន្លែងសម្លាប់មនុស្សឱ្យច្បាស់លាស់នោះទេ ក៏ប៉ុន្តែពេលទៅដល់ទៅនោះ លោកស្រីបានឃើញអ្វីខ្លះ? លោកឃើញសាក្សីហ្នឹងដួលទៅលើដី មិនបានកប់ ឬក៏យ៉ាងម៉េចដែរ?

**ឆ៖** ចាស ពេលដែលខ្ញុំចូលទៅហ្នឹងមិនមែនមានសាកសពថា នៅមានសាច់មានអីទេណ៎ា គឺឃើញមានតែឆ្អឹង ហើយអត់មានបានកប់ទេ បើកប់យើងមើលឆ្អឹងអត់ឃើញទេ។ អ៊ីចឹងសេចក្តីថា សាកសពដែលស្លាប់ទៅ គឺដេកស្ងកនៅក្នុងរណ្តៅអ៊ីចឹង ឬមួយក៏ដួលផ្ងារផ្កាប់អី អាហ្នឹងយើងទៅតាមសភាពអ៊ីចឹងទៅ។

**សៈ** គឺយើងកំពុងនិយាយអំពីឆ្អឹងហើយនិងក្បាល ឆ្អឹងដងខ្លួន និងឆ្អឹងលលាដ៍ក្បាល។ ថាតើលោកស្រីកំពុងនិយាយអ៊ីចឹង ឬក៏ម៉េច ឬក៏បញ្ហាបកប្រែ។ លោកស្រីឃើញអ្វីខ្លះ ឃើញឆ្អឹងដងខ្លួនផង ឃើញឆ្អឹងក្បាលផងអ៊ីចឹង ឬយ៉ាងម៉េច?

**ឆៈ** *(មីក្រូហ្វូនមិនទាន់ដំណើរការ)*

**ប្រធានអង្គជំនុំៈ**

កុំអាលទាន់ឆ្លើយតប!

[១៣:៤១:១៧]

**លោកស្រី វង សារុនៈ**

**ឆៈ** ចាស ពេលដែលខ្ញុំឃើញឆ្អឹងហ្នឹង គឺឃើញឆ្អឹងទាំងអស់ អត់មានទាន់បាត់ទៅណាទេ។ មានក្បាល មានខ្នងវែងអ៊ីចឹង មានឆ្អឹងភ្លៅ ឆ្អឹងដៃយើងអ៊ីចឹង។

**សួរដោយចៅក្រម ក្លូឌា ហ្វេនស៍ៈ**

**សៈ** នៅពេលលោកស្រីទៅដល់ទីនោះ តើលោកស្រីមានឃើញកន្លែងណាផ្សេងទៀត ដែលលោកស្រីអាចមើលឃើញឆ្អឹងលលាដ៍ក្បាល ឬក៏ឃើញដងខ្លួនរបស់សាកសពទាំងមូលដែរទេ កន្លែងផ្សេងទៀត?

**ឆៈ** ចាស កន្លែងផ្សេងទៀត ខ្ញុំអត់ដែលបានបានទៅទេ ព្រោះអីខ្ញុំចង់ទៅតែកន្លែងដែលប្ដីខ្ញុំគេសម្លាប់ហ្នឹង ដោយគេប្រាប់ហ្នឹងបានខ្ញុំប្ដូរអាយុជីវិតថាទៅមើលមើល៍វាមានអ៊ីចឹងដែរអត់។ ព្រោះកន្លែងដទៃទៀតខ្ញុំម៉េចបានទៅ ខ្ញុំខ្លាច។

[១៣:៤២:៣៩]

**សៈ** សំណួរបន្ទាប់របស់ខ្ញុំ គឺសួរអំពីការសម្លាប់មនុស្ស។ លោកស្រីជម្រាបអង្គជំនុំជម្រះថា គេយកអ្នកទោសទៅសម្លាប់ចោល ប៉ុន្តែលោកស្រីមិនធ្លាប់បានឃើញការសម្លាប់ដោយផ្ទាល់ទេ។ លោកស្រីឃើញព្រឹត្តិការណ៍តែមួយគត់ តែម្ដងគត់នៅពេលដែលឆ្មាំគុកមួយក្រុមបាននាំមនុស្សម្នាក់ទៅកន្លែងមួយ នៅកន្លែង ហើយក្រោយមកឃើញអ្នកទាំងអស់នោះត្រឡប់មកវិញ គឺថាមានឈាមប្រឡាក់ខោអាវ មានឈាមប្រឡាក់ខ្លួន។ តើនេះជាករណីតែមួយគត់ឬ ដែលលោកស្រីបានឃើញ ហើយលោកស្រីគិតថា នេះការសម្លាប់គឺវាសម្លាប់មានលក្ខណៈប្រហាក់ប្រហែលហ្នឹង? លោកស្រីឃើញតែម្ដងហ្នឹងទេ ឬក៏អាចឃើញការសម្លាប់ស្រដៀងៗគ្នានេះដែរ?

**ឆ៖** ចាស ពេលដែលខ្ញុំឃើញជាក់ស្ដែងអាពេលដែលគេវៃហើយ គេអត់ទាន់លាងខ្លួនគេ ខ្ញុំទៅបង្គន់ហ្នឹងឃើញ គឺវាជាក់ស្ដែងថា យើងមិនបានឃើញគេកាប់គេអីទេ តែបញ្ជាក់ត្រង់ថា យើងឃើញឈាម។ របៀបថាឈាមបាញ់ប្រឡាក់ខ្លួនអ្នកដែលទៅពិឃាដហ្នឹង។ ហើយការ -- អានេះ គឺការឃើញផ្ទាល់។ តែជាកាឃើញប្រយោល ឃើញតែគេសំលៀងកាំបិតអ៊ីចឹងហើយ គេដាក់មីក្រូហើយ ហើយគេហៅអ្នកទោសចេញដែលថា ជូនផ្ទះទៅអីវិញ អាហ្នឹងថាអ៊ីចឹង ឃើញញឹកញាប់។

[១៣:៤៤:២៨]

**សៈ** តើមានអ្វីកើតឡើងជាញឹកញាប់?

**ឆ៖** ចាស អ៊ីចឹងខ្ញុំសូមបង្ហាញការពិតមួយទៀត វា -- ប៉ុន្តែយើងមិនបានឃើញនឹងភ្នែកតែឮសំឡេង។ ម្ដាយកូន ម៉ែគាត់ចាស់ គាត់មានកូនស្រីមួយទើបនឹងមានប្ដីហ្នឹងកូនតែមួយគត់ ហើយគេយកគាត់មកដល់ហ្នឹង អាថ្ងៃខ្ញុំថាគេចេញ ឲ្យចេញទាំងព្រឹកព្រលឹម ថ្ងៃនុំងចូលច្រើនឡើងពេញហ្នឹង។ ពេលគេមកហៅយាយហ្នឹង យាយគាត់ថា "ខ្ញុំចាំទៅជាមួយកូនខ្ញុំ" គេថា "មិនបាច់ទេគង់តែជួបគ្នានៅមុខនោះទេហ្ន៎"។ ចាស យាយក៏ទៅៗ ខ្ញុំអត់បានតាមដានថាទៅជើង ឬទៅលិច តែដល់មួយសន្ទុះ គេក៏មកហៅ មីងៗកូនខ្ចីហ្នឹង ចៅគាត់ហ្នឹងឲ្យទៅ ទៅបានមួយសន្ទុះ ខ្ញុំឮសូរមាត់កូនង៉ែតយំពីជ្រុងខាងលិច តែខ្ញុំមិនដឹងថាគេយកទៅធ្វើដោយវិធីណាទេ។ អាហ្នឹង ខ្ញុំឮផ្ទាល់ត្រចៀកខ្ញុំ គ្រាន់ថាភ្នែកមិនបានមើល។

**សៈ** តើលោកស្រីធ្លាប់ស្ដាប់ឮសម្រែកបែបនេះតែម្ដងទេ ឬក៏ធ្លាប់ឮគេស្រែកហ្នឹងញឹកញាប់ដែរ?

**ឆ៖** ចាស តែម្ដងនេះទេ កូនង៉ែត ព្រោះអីវាដូចថា គ្រាន់តែមកដល់កណ្ដាលយប់ព្រឹកឡើងយកទៅ។ អាហ្នឹងដូចថាពួកខ្ញុំចាប់អារម្មណ៍ដែរ។ ហើយពួកខ្ញុំហ្នឹង គេដាក់ក្នុងហ្នឹងអត់លែងទេ គ្រាន់ថាអាចឮសំឡេងដោយកន្លែងហ្នឹងអត់ឆ្ងាយៗពីកន្លែងខ្ញុំដេកនៅទេ គ្រាន់តែបាំងដើមដំឡូងមី មើលទៅគេអត់ឃើញតែប៉ុណ្ណឹង។

[១៣:៤៦:៤៦]

**សៈ** លោកស្រីសាក្សីព្រឹកមិញលោកបានឆ្លើយថា អ្នកទោសជាច្រើនត្រូវបានគេសម្លាប់ចោល គឺថា លោកស្រីថា គេៗប្រហែលជាគេនាំ មិននាំខ្លួនយកទៅឆ្ងាយទេ គេសម្លាប់ជិតហ្នឹង។ តើលោកស្រីដឹងដោយរបៀបណា?

**ឆ៖** ចាស ខ្ញុំដឹងដោយអ្នកជាប់គុកមុនៗ ពូផុន អ៊ីហាត ដែលគេធ្លាប់ជាប់មុនខ្ញុំ ខ្ញុំជាប់មកក្រោយ គេធ្លាប់ជាប់មុនខ្ញុំ ហើយគេមានសិទ្ធិដូចថាពួកអ្នកគុកហ្នឹងគេទុកចិត្តណាស់ អ៊ីចឹងអ្នកទាំងហ្នឹង

អាចដឹងហើយប្រាប់ខ្ញុំហ្នឹងហ្នង។ ប្រាប់ថា "នុះ! កន្លែងនោះអ៊ីរុនឯងកុំទៅ!" ថាអ៊ីចឹង គេចង្អុលប្រាប់អ៊ីចឹងហើយ។ តាមការពិតពេលដែលខ្ញុំជាប់គុក ខ្ញុំអត់ដឹងថារណ្ដៅប៉ុន្មានទេ តែមកដល់ពេលខ្ញុំ -- នេះបីឆ្នាំមុនហ្នឹងខ្ញុំទៅដល់គុកក្រាំងតាចាន់បានខ្ញុំ ខ្ញុំទៅឈរ ខ្ញុំទៅសម្លឹង បានខ្ញុំដឹងថារណ្ដៅដែលគេវៃមនុស្សចោលហ្នឹង មានបីទៅបួន នៅក្នុងហ្នឹង។

**សៈ** ព្រឹកមិញនេះដែរ លោកស្រីឆ្លើយថា នៅពេលគេសម្លាប់មនុស្ស គេចាក់មីក្រូ។ តើនេះជា -- តែម្ដងទេឬ ដែលលោកស្រីស្ដាប់ឮសំឡេងគេចាក់មីក្រូអ៊ីចឹង ឬក៏លោកស្រីស្ដាប់គេ ឮគេចាក់មីក្រូញឹកញាប់ដែរ នៅពេលគេសម្លាប់មនុស្សនោះ?

[១៣:៤៨:៣៧]

**ឆៈ** ខ្ញុំអត់ដឹងថាគេចាក់មីក្រូហ្នឹងធ្វើអីទេ តែដល់ពេលក្រោយតែចាក់មីក្រូ ឮគេថាឲ្យអ្នកទោសហ្នឹងវិលត្រឡប់ទៅផ្ទះហើយ ព្រោះអីនៅកែខ្លួន កែប្រែខ្លួនបានហើយ។ អាហ្នឹងខ្ញុំឮផ្ទាល់ត្រចៀកនិងឃើញ។ តែកាលមុនខ្ញុំមកដល់ទៀត គ្រាន់តែអ៊ីចឹង ខ្ញុំសួរគេថា "ចុះម៉េចបានចាំចាក់មីក្រូម្ល៉េះវី?" គេថា "ហ៊ឺ ដែល អ៊ីរុន ឯងអត់ដឹងទេ ចាំបន្តិចទៀតដឹងហើយ"។ ដល់ពេលបន្តិចទៀត ខ្ញុំដឹងអ៊ីចឹងមែន។ ពេលគេយកមនុស្សទៅវៃចោល គឺគេចាក់មីក្រូ។ និយាយរួមចាក់ឲ្យថ្លង់ កុំឲ្យឮ យើងអ្នកនៅខាងក្នុងហ្នឹង ឮគេស្រែក ឬគេអ៊ីចឹងទៅ។ អាហ្នឹងតាមខ្ញុំស្មានចាស។

**សៈ** បាទសំណួរមួយពាក់ព័ន្ធទៅនឹងការសួរចម្លើយ លោកស្រីឆ្លើយថាគេបានសួរចម្លើយលោកស្រី ហើយបើខ្ញុំយល់មិនច្រឡំទេ លោកស្រីបានឃើញការធ្វើទារុណកម្មទៅលើអ្នកដទៃទៀត។ តើត្រឹមត្រូវឬក៏មិនត្រឹមត្រូវទេ?

**ឆៈ** ចាស ពិតជាត្រឹមត្រូវ។

**សៈ** តើលោកស្រីបានឃើញគេធ្វើទារុណកម្មហ្នឹងញឹកញាប់ទេ ដូចជារាល់ថ្ងៃ ឬក៏មួយអាទិត្យម្ដង ឬក៏ញឹកញាប់ ឬក៏តែម្ដងម្កាលអ៊ីចឹង។ តើវាយ៉ាងម៉េចដែរចំពោះការឃើញការសួរចម្លើយហ្នឹង?

[១៣:៥០:២៣]

**ឆៈ** ចាស ពេលខ្ញុំទៅដល់ដំបូង ជិតមួយឆ្នាំ ខ្ញុំអត់បានជួបប្រទះរឿងហ្នឹងទេ ដល់ទៅនៅបានជាងមួយឆ្នាំ របៀបគេថាគេទុកចិត្តយើង ពិតដែលយើងវាមិនរត់ទៅណាហើយ ព្រោះអីមិនដែលស្គាល់ដីស្រុកហ្នឹងផង។ ហេតុនេះ គេឲ្យខ្ញុំទៅឲ្យបាយជ្រូកស៊ីនៅកន្លែងរោងបាយគេហ្នឹង រោងបាយ និងកន្លែងសួរចម្លើយជិតគ្នាហ្នឹង បើសិនជាគ្មានព្រៃទន្ទ្រានខែត្រ ព្រៃដំឡូងមី គឺអាចមើលគ្នាឃើញ សំឡេងឆ្លើយ

មកយើងឮពេញត្រចៀក អ្នកសួរ អ្នកឆ្លើយ។ ប៉ុន្តែមិនញឹកញាប់ទេ ព្រោះអីកាលណាគេប្រើយើងថា "អ៊ីរុន ទៅឲ្យជ្រូកស៊ីទៅ!" អាហ្នឹងបានយើងមានសិទ្ធិចូលទៅកន្លែងហ្នឹង ហើយបើគេអត់ប្រើយើង អត់អាច។

**ស៖** តើការសួរចម្លើយហ្នឹង -- ខ្ញុំសួរម្តងទៀតថា គេសួររាល់ថ្ងៃ ឬគេសួរមួយអាទិត្យម្តងទេ ឬក៏គេសួរមួយខែទើបសួរចម្លើយអ្នកទោសម្តង? វាមានលក្ខណៈបែបណាដែរ ញឹកញាប់ប៉ុនណាដែរ?

**ឆ៖** ចាស គេសួរចម្លើយនៅពេលដែលអ្នកទោសចូលមកដេកបានមួយយប់ អាហ្នឹងស្អែកឡើងគេសួរហើយ។ សួរចម្លើយទៅតាមអ្នកទោសហ្នឹង ចូលច្រើន ឬចូលតិច បើចូលច្រើន គេសួរក្នុងមួយថ្ងៃ -- មួយព្រឹកហ្នឹងពីរនាក់អ៊ីចឹងទៅ ហើយបានស្អែកឡើងគេបន្តទៅទៀតរហូតដល់អស់អ្នកទោសចូលមកហ្នឹង អាហ្នឹងបានគេឈប់សួរ។ ដល់អ្នកថ្មីចូលមកក្រោយទៀត អាហ្នឹងបានគេធ្វើដូចខ្ញុំបានរៀបរាប់។

[១៣:៥២:៣៦]

**ស៖** ខ្ញុំមិនសួរអំពីបែបបទបែបនេះទេ ខ្ញុំសួរសំណួរពីរចុងក្រោយទៀត។ ទាក់ទងទៅនឹងស្ថានភាពនៅក្នុងកន្លែងឃុំខ្លួន លោកស្រីគឺគេចាត់ទុកថាលោកស្រីស្ថិតនៅក្នុងវណ្ណៈអនុជន។ គឺលោកស្រីជាៗ -- មានន័យថាក្រោមប្រជាជនទៀត អនុប្រជាជន។ ហេតុអីបានជាគេៗ -- គេយល់ថាម៉េចដែរការដែលគេចាត់ថ្នាក់លោកស្រីថាជាអនុប្រជាជនយ៉ាងដូច្នេះ?

**ឆ៖** ចាស ព្រោះអីខ្ញុំមានមេភូមិ ដូចថាខ្ញុំទៅនៅស្រុកគេថ្មីអ៊ីចឹង គេអាណិតខ្ញុំ ខ្ញុំសួរថា "ចុះអាម៉េចវិញដែលបង គេឲ្យខ្ញុំមកនៅអ៊ីចឹង ខ្ញុំមកពីអង្គភាព" គេថា "អឺ! ហ្អែងសិទ្ធិក្រោមប្រជាជនគេនៅស្រុកនេះទេ" ហើយដល់ខ្ញុំពិនិត្យតាមសម្តីគាត់និយាយ អ៊ីចឹងមែន គេមានអីវ៉ាន់អីៗមកគេចែកតែគ្នាគេទៅ យើងគេអត់បានគិតដល់ទេ បានសេចក្តីថា ក្រោមប្រជាជនដែលគេនៅក្នុងស្រុកគេហ្នឹងទៀត។ ហើយសិទ្ធិយើងសុំដើរហើរទៅណាអី គេៗតាមដានយើងណាស់ ពេលយើងដេកយប់ក៏ៗគេតាមដានគេលបស្តាប់ដែរ ហេតុអីបានខ្ញុំដឹងរឿងហ្នឹង? កាលប្តីខ្ញុំនៅ គាត់ថាល្ងាចអ៊ីចឹងដែល "រុន អ្នំរុន ឯងបោសក្រោមផ្ទះឲ្យស្អាតទៅ ព្រលឹមឡើងយើងក្រោកឡើងពីភ្លឺ -- ពីយប់អត់បានបោសផ្ទះទេ"។ ខ្ញុំហ្នឹងចេះតែជឿប្តី ក្រោកបោសអ៊ីចឹងស្អាត--

[១៣:៥៤:២៤]

**ស៖** បាទ សូមបង្អង់បន្តិចលោកស្រី ដោយសារមិនមានការបកប្រែ។

**ឆ៖** ដោយពេលដែលខ្ញុំដឹងថាយើងក្រោមប្រជាជនហ្នឹងណ៎ា ពេលខ្ញុំទៅដេក គេឲ្យផ្ទះនៅសភាព

ផ្ទះដែលគេឲ្យខ្ញុំនៅ ដំបូលមើលឃើញមេឃ ជញ្ជាំងមើលឃើញសងខាង។ បានសេចក្ដីថាផ្ទះដែលគេបោះបង់ចោល ឬមួយក៏ផ្ទះថា គេយកមនុស្សហ្នឹងទៅវៃចោលនៅសល់ផ្ទះហ្នឹងទៅ។ ពេលដែលមកមានប្ដីមួយ កូនមួយ តែប្ដីខ្ញុំ បើតាមខ្ញុំដឹង បែបគាត់ដឹងរឿង តែគាត់អត់ហ៊ាននិយាយប្រាប់ខ្ញុំ ថាគេពិតជាយកយើងមកដាក់គុក ធ្វើទោស ធ្វើអីហ្នឹងណា គាត់អត់ហ៊ាននិយាយប្រាប់ខ្ញុំ។ "គ្រាន់តែថា ដែលជិតយប់ហើយបោសផ្ទះទៅ ដល់ស្អែកឡើង យើងឡើងតាំងពីមាន់រងាវ ឡើងទៅធ្វើការ អត់បានបោសផ្ទះទេ"។ គាត់ប្រើខ្ញុំរាល់ថ្ងៃ ហើយខ្ញុំ ពីរបីថ្ងៃបន្ទាប់ ខ្ញុំអត់ដឹង ប៉ុន្តែធ្លល់ៗ ពេលដែលខ្ញុំភ្ញាក់ឡើង ភ្លឺចុះមក ខ្ញុំឃើញដានជើងក្រោមផ្ទះខ្ញុំ តែខ្ញុំសួរប្ដីខ្ញុំ ប្ដីខ្ញុំអត់ហ៊ានប្រាប់ទេ ព្រោះអីខ្ញុំវាក្មេងដែរ ខ្លាចខ្ញុំភ្លាត់មាត់ភ្លាត់អីចឹង សួរគេសួរឯងទៅ អាហ្នឹងនាំឲ្យរឹតតែឆាប់ស្លាប់ គាត់អត់មាត់ទេ។ ដល់តែខ្ញុំគិតយូរៗទៅ ផ្ទះខ្ញុំដានជើងយប់រាល់ថ្ងៃ។ ដល់តែថ្ងៃមួយ ខ្ញុំប្រថុយ ប្រថុយសួរ សួរអ៊ំប្រពន្ធប្រធានភូមិចាន់ទាបហ្នឹង គាត់សុំខ្ញុំធ្វើកូនធម៌ ព្រោះអីកូនគាត់ដូចខ្ញុំណាស់ ខ្ញុំថា "ម៉ែអើយម៉ែ! ចុះផ្ទះខ្ញុំ ខ្ញុំបោសស្អាតៗរាល់តែថ្ងៃ ម៉េចបានឃើញសុទ្ធដានជើងអីចឹងម៉ែ?" គាត់ហ្នឹងក៏ឱបខ្ញុំ ឱបខ្ញុំហើយនិយាយរបៀបថាដែលចង់យំ គាត់ថា "កូនឯងអត់ដឹងទេ គេមកលបស្ដាប់កូនឯងរាល់យប់"។ អាហ្នឹង ខ្ញុំដឹងតាមម៉ែធម៌វិញដែលខ្ញុំទៅរស់នៅជាមួយគេ ខ្ញុំស្លូតបូត គាត់ប្រាប់អីចឹង បានខ្ញុំនឹកឃើញ អូ៎! គេតាមដានយើងរាល់តែថ្ងៃហ្នឹង អីចឹងបានសេចក្ដីថាអាពាក្យ "អនុប្រជាជន"ហ្នឹង គេថាអីចឹងត្រូវណាស់ ព្រោះអីយើងមិនបានប្រជាជនគេក្នុងហ្នឹងទេ គេតាមដានយើងគ្រប់ទាំងអស់អីចឹង។

[១៣:៥៧:០៦]

**ស៖** ខ្ញុំស្ដាប់ឮសួរតាមការបកប្រែថា ផ្ទះរបស់លោកស្រីហ្នឹង គឺអត់មានដំបូល អត់មានជញ្ជាំង បើអត់មានដំបូល អត់មានជញ្ជាំង។ អីចឹង វាមិនមែនជាផ្ទះទេ អីចឹងតើសូមបញ្ជាក់ឲ្យច្បាស់មើល៍ ផ្ទះហ្នឹងវាមានស្ថានយ៉ាងម៉េចដែរ វាអាចដោយសារបញ្ហាបកប្រែក៏ថាបាន?

**ឆ៖** ផ្ទះនោះ គេចម្រៀងអាពត គេថាហ្នឹងវាអត់ខុសទេ ដំបូលរហែក ជញ្ជាំងបាក់បែក មើលឃើញក្នុងក្រៅ។ ខ្ញុំឮតែចម្រៀងហ្នឹងច្រៀងទេ តែដល់ធាតុពិត ក៏ខ្ញុំ គឺខ្ញុំមករស់ក្នុងសភាពដូចចម្រៀងគេថាអីចឹងមែន គឺវាពិតប្រាកដ គឺមានសរសរ មានអីអីចឹងមែន ប៉ុន្តែដំបូលយើងមើលឃើញមេឃហ្នឹងដាច់ធ្លុះធ្លាយ។ ជញ្ជាំងខាងៗ យើងមើលឃើញ ទៅណាក៏ឃើញដែរ ដូចចម្រៀង ប៉ុល ពត គេច្រៀងអីចឹងមែន ជីវិតខ្ញុំពេលហ្នឹង គឺដល់កន្លែងហ្នឹង។

**ស៖** គឺថាខ្ញុំយល់ច្បាស់ហើយនៅពេលនេះ។ សំណួរចុងក្រោយរបស់ខ្ញុំ លោកស្រីបានឆ្លើយម្ដង

ថាគេបញ្ជូនមនុស្សយកទៅអប់រំកែប្រែ។ តើពាក្យថា "បញ្ជូនទៅអប់រំកែប្រែ" នេះ ពាក្យអប់រំកែប្រែនៅពេលនោះមានន័យដូចម្ដេចដែរ?

**ឆ៖** បើតាមខ្ញុំ គេសួរចម្លើយខ្ញុំ អត់មានកែប្រែ មានអប់រំអីទេ។ គេសួរថា ឲ្យតែយើងមានកំហុស គេសរសេរអីចឹងហើយ ប្រហែលខ្ញុំស្មានក្នុងចិត្តខ្ញុំទេ បែបគេសួរយើងហើយ គេបញ្ជូនឈ្មោះយើងហ្នឹងទៅថ្នាក់លើទៅ។ ទម្រាំដល់ពេលណា អាថ្នាក់លើហ្នឹងទម្លាក់ថា ឲ្យសម្លាប់ចោល គេសម្លាប់ចោល។ ខ្ញុំតាមខ្ញុំមើល ហើយខ្ញុំអ្នកទោសរង់ចាំមើលហ្នឹង។ ដល់តែបានយូរបន្តិច បើមនុស្សច្រើនមួយអាទិត្យបញ្ចេញហើយ ឲ្យទៅផ្ទះហើយ។ បើមនុស្សរៀងតិច បានមួយខែ មួយខែកន្លះហ្នឹង ប៉ុនអ្នកជំងឺហើមហើយ អ្នកទោសហ្នឹងមានជំងឺហើមហើយ។

**ស៖** លោកស្រីនិយាយអំពីកង្វះអាហារូបត្ថម្ភ ហើយនិងភាពអត់ឃ្លាន។

**ចៅក្រម ក្លូឌា ហ្វេនស៍៖**

ខ្ញុំអត់សំណួរហើយ។ សូមអរគុណ ច្រើនលោកប្រធាន។

[១៣:៥៩:៤៦]

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ ជាបន្តទៅនេះ អង្គជំនុំជម្រះផ្ដល់វេទិកាជូនទៅក្រុមមេធាវីការពារក្ដី។ ជាដំបូងក្រុម ជូនទៅក្រុមមេធាវីការពារក្ដីលោក នួន ជា ដើម្បីមានឱកាសតាំងសំណួរដេញដោលចំពោះសាក្សីរូបនេះ។ អ៎! មេធាវីខៀវ សំផន មុន។

បាទ សូមអញ្ជើញមេធាវីការពារក្ដីលោក ខៀវ សំផន!

**កញ្ញា អង់តា ហ្គីសសេ៖**

ចាស ជម្រាបសួរលោកប្រធាន។ សូមអរគុណ។ ខ្ញុំបានពិភាក្សាជាមួយមេធាវីក្រុម នួន ជា យើងនឹងបន្ត -- យើងចាប់ផ្ដើមមុនក្រុម នួន ជា ហើយក្រោយមកនៅសល់ពេលវេលាទុកឲ្យគាត់សួរតាមក្រោយលោកប្រធាន ប្រសិនជាមិនមានបញ្ហាអីទេ ពីព្រោះថាយើងមានសំណួរបន្តិចបន្តួចទេលោកប្រធាន។

**ការតាំងសំណួរដោយសហមេធាវីការពារក្ដី**

**សួរដោយកញ្ញា អង់តា ហ្គីសសេ៖**

**ស៖** ចាស ជម្រាបសួរលោកស្រីសាក្សី ខ្ញុំឈ្មោះ អង់តា ហ្គីសសេ ខ្ញុំជាសហមេធាវីអន្តរជាតិ

របស់លោក ខៀវ សំផន ហើយខ្ញុំមានសំណួរខ្លីទេសួរទៅកាន់លោកស្រីទាក់ -- ដើម្បីបន្ថែមទៅលើសំណួរដែលគេបានសួរលោកស្រីកាលពីព្រឹកមិញមកនេះ។ សំណួរទី១ របស់ខ្ញុំទាក់ទងទៅនឹង យាយញ៉ ដែលលោកស្រីបាននិយាយ ឆ្លើយជាមួយសហព្រះរាជអាជ្ញា។ លោកស្រីបានឆ្លើយប្រាប់គាត់ថា គាត់ជាចុងភៅនៅមន្ទីរក្រាំងតាចាន់ ហើយលោកស្រីក៏បាននិយាយអំពីកូនរបស់ យាយញ៉ នេះផងដែរ។ តើលោកស្រីចាំឈ្មោះកូនស្រី -- ឈ្មោះកូនប្រុសរបស់គាត់ដែរឬទេ?

**លោកស្រី វង សារុនៈ**

**ឆៈ** ចាស កូនប្រុសយាយញ៉ ឈ្មោះ ខុម មួយ, មួយទៀតខ្ញុំភ្លេចឈ្មោះហើយ។ កូនប្រុសហ្នឹងឈ្មោះ ខុម។

[១៤:០១:៥៦]

**សៈ** តើលោកស្រីនឹកឃើញឈ្មោះ សយ សែន ទេ?

**ឆៈ** ខ្ញុំនឹកឃើញ ហើយខ្ញុំនិងគាត់ហ្នឹង គ្រាន់ថាខ្ញុំជាប់គុកនៅក្នុងផ្ទះ គាត់គេឲ្យសិទ្ធិនៅក្រៅដើម្បីក្រែងមានខ្មោចងាប់ ខ្មោចអីទៅ គាត់យក គាត់អូស គាត់អីទៅចោលឯណា ស្រេចគេបញ្ជាគាត់។ ហើយគាត់ជាអ្នកយកអាលាមកពេលព្រឹកហ្នឹងយកទៅចាក់ចោល។ គាត់ជាអ្នកទោសរបស់ខ្ញុំ តែគាត់ជាប់មុនខ្ញុំ។

**សៈ** នៅក្នុងការងារដែលលោកស្រីទៅបំពេញនៅមន្ទីរក្រាំងតាចាន់ តើលោកស្រីធ្លាប់ធ្វើការជាមួយគាត់ដែរឬទេ? ខ្ញុំចោទសំណួរនេះ ទៅលោកស្រីពីព្រោះនៅក្នុងសវនាការថ្ងៃទី២៥ ខែមីនា ឆ្នាំ២០១៥ លោក សយ សែន នៅក្នុងឯកសារ E1/282.1 ប្រហែលជាម៉ោង ១៦:១៩:២៩ លោក សយ សែន គាត់និយាយថា ពេលខ្លះគាត់នាំក្រុមស្ត្រីទៅៗបរិវេណខាងក្រោមន្ទីរក្រាំងតាចាន់។ អ៊ីចឹង សំណួរខ្ញុំចង់ដឹងថា តើលោកស្រីស្ថិតនៅក្នុងក្រុមស្ត្រីដែលគេនាំទៅធ្វើនៅខាងក្រៅបរិវេណមន្ទីរក្រាំងតាចាន់ជាមួយ សយ សែន ហ្នឹងដែរឬទេ?

**ឆៈ** ចាស ពេលគេប្រើឲ្យយើងរែកអាជីលាមកហ្នឹងយកទៅដាក់ វាយយកទៅចាក់ស្រែ គឺគាត់ធ្វើជាមួយក្រុមពួកខ្ញុំហ្នឹង ដោយជួនកាលគាត់កាប់ជីដាក់បង្គីឲ្យយើងទៅ យើងហ្នឹង នារីៗបីបួននាក់ដែលជាប់នៅក្នុងហ្នឹងចេះតែរែកទៅ ហ្នឹងបានចូលធ្វើអ៊ីចឹងជាមួយគ្នា។ ហើយពេលខែគេដាំដំណាំឪឡឹក ត្រសក់អីហ្នឹងគឺ ក៏បានទៅធ្វើជាមួយគ្នាដោយគាត់ធ្វើលើករង លើកអីជាមួយពួកខ្ញុំទៅ ពួកខ្ញុំនាំគ្នារែកជីដាក់អ៊ីចឹងទៅ អាហ្នឹងគឺធ្វើអ៊ីចឹងជាមួយគ្នា។

**ស៖** តើលោកស្រីគិតថា គាត់ជាមេរបស់លោក គាត់ជាអ្នកចេញបញ្ជា ឬក៏បញ្ជាដែលគាត់ឲ្យដាក់មកលោកស្រីហ្នឹងគ្រាន់តែជាការណែនាំទេ?

**ឆ៖** ចាស ពូសែន គាត់មិនមែនជាអ្នកបញ្ជាពួកខ្ញុំទេ គឺគាត់ទទួលបញ្ជាពីមេគុកហ្នឹងមកថាឲ្យយើងធ្វើស្អីៗទៅ បានគាត់មកប្រាប់ហើយធ្វើជាមួយគ្នា។

[១៤:០៥:១១]

**ស៖** អ៊ីចឹង បានន័យថាលោកស្រីមិនបានគិតថាគាត់ហ្នឹងជាមេរបស់លោកស្រីទេ។ តើត្រឹមត្រូវដែរឬទេ?

**ឆ៖** ចាស ត្រឹមត្រូវ។

**ស៖** នៅថ្ងៃសវនាការដដែលហ្នឹង គឺឯកសារ E1/282.1 សយ សែន និយាយពីលោកស្រី។ អ៊ីចឹង ខ្ញុំសូមអានសម្រង់អំពីដែលគាត់បានឆ្លើយ។ ហើយបន្ទាប់មក ខ្ញុំសួរសំណួរទៅលោកស្រីនៅត្រង់ម៉ោង ១៥:៣៦:៥១ នៅថ្ងៃដដែល គឺថ្ងៃ២៥ មីនា ឆ្នាំ២០១៥ដដែល។ លោក សយ សែន និយាយដូចតទៅនេះ៖ “ខ្ញុំមិនដែលបាននិយាយជាមួយ រុន ទេ ប៉ុន្តែ រុន បានរត់ចូលព្រៃជាមួយ តាអាន់។ ហើយបន្ទាប់មកទៀត ខ្ញុំបានជួប រុន ហើយ រុន បានប្រាប់គាត់ថា តាអាន់ បានចេញបញ្ជានៅពេលដែល -- ណែនាំឲ្យគាត់ ពេលដែលគាត់នៅធ្វើការជាមួយគាត់។ អ៊ីចឹងហើយបានគាត់រស់រានមានជីវិត”។ អ៊ីចឹងសំណួរខ្ញុំសួរយ៉ាងដូច្នេះ តើលោកស្រីបានរត់ជាមួយ តាអាន់ មែនដែរឬទេ?

[១៤:០៦:៣១]

**ឆ៖** ចាស។ ពេលដែលទៅដល់នៅ -- រត់ទៅដល់ពោធិ៍សាត់ បាក់ចិញ្ចៀនហ្នឹង គេឲ្យខ្ញុំប្ដេជ្ញាជាមួយនឹងជនអ្នកទោសដូចខ្ញុំដែរ ប៉ុន្តែនៅស្រុកអង្គរជ័យ ឈ្មោះ សារ៉េត តែខ្ញុំអត់ព្រម។ អ៊ីចឹងអត់ព្រមអ៊ីចឹង យើងអត់មានពេលថា ពេលណាត្រូវរត់ទេ មិនដឹងថា គិតរត់ចេញពីគេដោយរបៀបណា។ ដល់ពេលយើងធ្វើដំណើរតាមផ្លូវ ពេលហ្នឹងកំពុងតែដាំបាយហូប ស្រាប់គេបាញ់គ្នាផ្ទួងផាំងៗ។ ពេលនោះហើយដែលខ្ញុំមានឱកាសរត់ចេញ។ តែពេលរត់ចេញហ្នឹង ខ្ញុំរត់ទៅជាមួយគ្នា ជាមួយ តាអាន់ ដែរ ប៉ុន្តែយើងបែកគ្នា នៅពេលដែលយើងចូលដល់ព្រៃឆ្ងាយ ព្រោះអីយើងស្រី ហើយខ្ញុំមានកូនតូច មិនអាចដើរតាមគេឡើងព្រៃ ឡើងភ្នំបានដូចគេអត់មានគ្នាទេ។ អ៊ីចឹង ហេតុនេះកន្លែងហ្នឹងហើយដែលខ្ញុំអាចៗចេញមកបាន។

**ស៖** តើលោកបានជួប សយ សែន ហើយបានរៀបរាប់អំពីការរត់ចេញរបស់លោកស្រីដែរឬទេ

ថានៅក្រោយឆ្នាំ១៩៧៩ហើយនេះ តើគាត់មានបានរៀប -- តើលោកស្រីមានបានរៀបរាប់ប្រាប់ សយ សែន ពីរបៀបដែលលោកស្រីលួចរត់ចេញដែរឬទេ?

[១៤:០៨:១០]

**ឆ៖** ចាស ខ្ញុំមិន -- ពេលដែលបីឆ្នាំមុន ខ្ញុំនឹងឃើញថា ខ្ញុំ -- កូនគេទិញម៉ូតូឲ្យខ្ញុំអាចធ្វើដំណើរបានមកក្រាំងតាចាន់ហើយ ខ្ញុំក៏ចូលឆ្នាំថ្ងៃទី១ហ្នឹង ខ្ញុំក៏ឲ្យកូនប្រុសខ្ញុំមក ជូនមកថា គោលបំណងថាមករកឈ្មោះប្ដីទេ តែបើកទៅអត់ឃើញ អាបញ្ជីគេនៅហ្នឹង។ ដល់តែឃើញ ឃើញឈ្មោះខ្ញុំតែម្ដង។ ហើយពេលនោះ តាគាត់គ្រប់គ្រង់កន្លែងហ្នឹង គាត់ថា “អ៊ឺៗ បើអ៊ំឯងឃើញឈ្មោះហើយ អ៊ំឯងសរសេរឈ្មោះអ៊ំឯងទៅថា “នៅរស់” ហើយដាក់លេខទូរស័ព្ទទៅ ហើយអ៊ំឯងធ្វើការនៅកន្លែងណា ដែលអ៊ំឯងដាក់ទៅ ដើម្បីក្រែងមានគេមកស្រាវជ្រាវសួរអ៊ំឯង ចាស។ ដល់ពេលនោះ ខ្ញុំដាក់លេខទូរស័ព្ទកត់ឈ្មោះថាខ្ញុំនៅរស់ទេអ៊ីចឹង តាមការណែនាំរបស់ដែលអ៊ំដែលគាត់គ្រប់គ្រងកន្លែងហ្នឹងទៅ ចំឈ្មោះដែលគេសរសេរឈ្មោះខ្ញុំហ្នឹងតែម្ដង។ ដល់ក្រោយមក ខ្ញុំមិនៗដែលបានទៅជួប សែន ទេ សែន ដឹងខ្ញុំនៅរស់ដោយគាត់ បើខ្ញុំស្មានមិនខុស គឺគាត់ទៅកន្លែងក្រាំងតាចាន់ហ្នឹងៗតែម្ដង។ តាហ្នឹង គាត់និយាយប្រាប់ថាឃើញអ៊ំមួយថា នៅរស់អីនៅគុកក្រាំងតាចាន់ហ្នឹង។ ដល់ហើយ គាត់ក៏តេទូរស័ព្ទទៅខ្ញុំ។ ហើយខ្ញុំក៏លើកមែន គាត់ថា “អី អ៊ុំរុន ឯងនៅរស់សំណាងណាស់”។ ខ្ញុំថា “ហ្នឹងហើយខ្ញុំនៅរស់ គិតទៅជីវិតខ្ញុំថ្លៃណាស់ វាមិនត្រូវងាប់ បើវាងាប់អាតាមផ្លូវរត់ក៏ងាប់ដែរ ពូសែន អ្ហា”។ អ៊ីចឹង តែខ្ញុំអត់បានដូចថាអត់បាននិយាយរឿងពាក់ព័ន្ធជាមួយ តាអាន់ តាអីហ្នឹងផង។ ខ្ញុំរៀងដូចអត់បាននិយាយសោះ អាហ្នឹង។

[១៤:១០:០០]

**សៈ** ក្រៅពីការនិយាយទូរស័ព្ទជាមួយ សយ សែន ហ្នឹងគឺលោកស្រីមិនដែលបានជួបគាត់ទេឬ?

**ឆ៖** អត់ដែលបានជួបរហូតដល់ថ្ងៃហ្នឹង។ ថ្ងៃហ្នឹងក៏អត់ដែរ ជួបតែតាមទូរស័ព្ទ។

**សៈ** ឥឡូវខ្ញុំសុំដកស្រង់ពាក្យសម្ដីគាត់បន្តទៀត គឺនៅថ្ងៃដដែលថ្ងៃទី២៥ ខែមីនា ឆ្នាំ២០១៥ ឆ្លើយតបទៅនឹងសំណួរដែលសហព្រះរាជអាជ្ញាបានសួរព្រឹកមិញ។ គេសួរលោក សយ សែន ដូចតទៅនេះ លោកបាននិយាយថា លោកបានឆ្លើយក្រៅផ្លូវការទៅអ្នកស៊ើបអង្កេតថា លោកនិយាយថា រុន នោះមានទំនាក់ទំនងស្នេហាជាមួយក្រាំងតាចាន់ នៅពេលដែលរត់ចេញពីមន្ទីរក្រាំងតាចាន់ហើយ ហើយចម្លើយគាត់ឆ្លើយថា៖ “បាទ អ៊ីចឹងហើយ”។ អ៊ីចឹង បើតាមចម្លើយរបស់លោក សយ សែន នេះ គឺឃើញថា គាត់ -- ឃើញថា សយ សែន ហ្នឹងគាត់ធ្លាប់បាននិយាយចេញជាពាក្យចចាមអារាមថា

លោកស្រីហ្នឹងមានទំនាក់ទំនងស្នេហាជាមួយ តាអាន់ ហើយព្រឹកមិញនេះលោកស្រីបាននិយាយថាមិនអាចស្រឡាញ់អ្នកដែលសម្លាប់ប្ដីរបស់ខ្លួននោះទេ។ អ៊ីចឹង ខ្ញុំសំណួរ ខ្ញុំចង់សួរថាតើហេតុអីបានជាមានពាក្យចចាមអារាមហ្នឹង? ហើយហេតុអីបានក៏ សយ សែន ហ្នឹងនិយាយទៅកាន់អ្នកស៊ើបអង្កេតយ៉ាងដូច្នេះអ៊ីចឹង?

**ឆ៖** ចាស។ សែន ទូរស័ព្ទគេសួរខ្ញុំអ៊ីចឹងមែនថា "អ៊ីរុន ឯងស្រឡាញ់ តាអាន់ អីកាលរត់ទៅ?" ខ្ញុំថា ខ្ញុំអត់មានបានស្រឡាញ់ទេ។ កាលយើងរត់ទៅ គ្រាន់ថាគេបាញ់គ្នាប្រាវៗ យើងក៏អត់មានទិសដឹងថារត់ទៅណាដែរ គឺនាំគ្នារត់ទៅពីខាងលិចថ្នល់។ អ៊ីចឹង គាត់ក៏រត់ទៅខាងលិចផ្លូវ ខ្ញុំក៏រត់ទៅខាងលិចផ្លូវ តែត្រង់ថា ទៅជួបគ្នា ឬមិនជួបគ្នា អាហ្នឹងគឺវាអត់បានជួប ព្រោះអីការភ័យខ្លាចនឹងការបាញ់នេះ វាអត់មានគិតថាទៅនៅជាមួយអ្នកណាអ្នកនោះទេ គឺអត់ទេ គឺដូចថាវារត់ទៅដោយស្វ័យប្រវត្តិ ហើយគេឃើញថាយើងរត់អ៊ីចឹងទៅ ប្រហែលគេនឹកស្មានថាអ៊ីចឹងទៅ ចាស។ តែតាមការពិត វាបានត្រឹមតែទៅ ហើយរត់បែកគ្នាព្រោះអីគ្រាប់កាំភ្លើងប្រាវៗ អាចេញទិសទៅ ទៅតែមួយ តែដល់ហើយ វាមិនបានជួបគ្នាអ៊ីចឹង។

**ស៖** សំណួរចុងក្រោយរបស់ខ្ញុំទាក់ទងទៅនឹងអ្វីដែលលោកស្រីបានឆ្លើយអម្បាញ់មិញ គឺថានៅពេលដែលលោកស្រីត្រឡប់ទៅមន្ទីរក្រាំងតាចាន់ហ្នឹង លោកស្រីបានផ្ដល់លេខទូរស័ព្ទដាក់នៅកន្លែងនេះអ៊ីចឹងបាន សយ សែន បានទាក់ទងលោកស្រីបាន។ អ៊ីចឹង សំណួររបស់ខ្ញុំទី១ គឺចង់ដឹងថា តើមានអ្នកផ្សេងទៀតដែលគេទូរស័ព្ទទាក់ទងដោយ មកលោកស្រីដែរឬទេ? ហើយឬក៏ សយ សែន ហ្នឹងលោកស្រីមានដឹងទេថា សយ សែន គាត់មានទាក់ទងអ្នកផ្សេងទៀតដែរឬទេ?

[១៤:១៣:១៨]

**ឆ៖** ចាស ខ្ញុំអត់ដឹងគាត់ថាទាក់ទងអ្នកផង។ គ្រាន់តែគាត់ឃើញទូរស័ព្ទខ្ញុំ គាត់តែទៅសួរសុខទុក្ខអីអ៊ីចឹង ហើយក៏គាត់និយាយសួរថា "អី? ដែលខ្ញុំឮចចាមអារាមគេថា អ៊ីរុន ឯងស្រឡាញ់ តាអាន់ ហ្អេ?" ខ្ញុំថា "ពាក្យហ្នឹងគឺជាពាក្យចចាមអារាមទេ ប៉ុន្តែការពិតវានៅតែពិត យើងមិនអាចយកអ្នកដែលសម្លាប់ប្ដីខ្លួនឯង យើងសឹងតែថាឃើញហើយនឹងភ្នែក ពេលដែលយើងទៅជាប់គុកហ្នឹង។ អត់អាចបានទេ"។ ដល់ហើយពូសែនគាត់ថា៖ "អី បើអត់វាល្អហើយព្រោះអីអាពាក្យចចាមអារាម គេឃើញ អ៊ីរុន ឯងរត់ហ្នឹង"។ ខ្ញុំថា៖ "រត់ទៅមែនពេលដែលកំពុងតែបាញ់ បាញ់មកពីកើត យើងមិនរត់ទៅលិច? អ្នកណាក៏រត់ទៅលិចដែរ។ ទិសខាងលិចផ្លូវ។ អ៊ីចឹង ការរត់នេះវាគ្រាន់តែថាទិសតែមួយ តែដល់តែពេល

យើងចេញច្រកទៅណា វាជារឿងផ្សេង មិនបានទៅជួបគ្នាអ៊ីចឹង”។ គាត់ថា “អឺ បើពាក្យចចាមអារាម អ៊ីចឹង អ៊ីរុន ឯងអត់ហ្នឹងគឺវាអត់ហើយ យើងនិយាយតែត្រង់”។ អ៊ីចឹងបានខ្ញុំថា ពាក្យចចាមអារាមនេះ វាអាចគេឃើញថាយើងរត់ទៅអ៊ីចឹងមែនវាគេចេះតែថាទៅទេ។ តាមការពិតវាមិនមែន។

**កញ្ញា អង់តា ហ្គីសសេះ**

លោកប្រធាន ខ្ញុំអស់សំណួរហើយ ហើយលោកមេធាវី គង់ សំអុន ក៏អត់មានសំណួរដែរ។

លោកស្រីសាក្សីសូមអរគុណ។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។

បន្តទៅនេះ ផ្តល់វេទិកាជូនទៅក្រុមមេធាវីការពារក្តីលោក នួន ជា ដើម្បីមានឱកាសតាំងសំណួរ ដេញដោលចំពោះសាក្សីរូបនេះ។ សូមអញ្ជើញ!

**លោក វ៉ិចទ័រ កូប៉េះ**

ជម្រាបសួរលោកប្រធាន។

**សួរដោយលោក វ៉ិចទ័រ កូប៉េះ**

**ស៖** លោកសាក្សី តើអាចពន្យល់បានទេថា ហេតុអីបានជាលោកស្រីបានរត់ជាមួយ តាអាន់? ម៉េចក៏ តាអាន់ ហ្នឹងនាំយកលោកស្រីទៅជាមួយ ពេលរត់ហ្នឹង?

**លោកស្រី វង សារុន៖**

**ឆ៖** ចាស ខ្ញុំសូមបំភ្លឺ។ ពេលដែលខ្ញុំទៅដល់ពោធិ៍សាត់ គេឲ្យខ្ញុំប្តេជ្ញាជាមួយ រត ដែលជាអ្នកទោសដែរហ្នឹង។ ខ្ញុំហ្នឹងរករឿងតែថារត់ ប៉ុន្តែយើងចេះតែអឺជាអង្គការ ព្រោះអឺបើយើងមិនព្រមប្តេជ្ញា មិនព្រមអឺជាមួយគេ ដឹងថាស្លាប់ហើយ យើងដឹងទិសអ៊ីចឹង។ ទោះបីយើងមិនស្រឡាញ់ យើងបង្ខំចិត្តថា ធ្វើតាមគេមួយពេលហ្នឹង ដើម្បីជីវិតចាស។ ដល់ពេលៗចូលដល់ពោធិ៍សាត់ ពេលយួនបែកហ្នឹង យើងមិនត្រឡប់វិលវិញ។ ត្រឡប់វិលវិញ យើងក៏អត់ដឹងថា អ្នកណាជាអ្នកណាដែរ ព្រោះអឺបររទេះ ដើរឆ្វេងឆ្វាចពេញហ្នឹង ពេញតែផ្លូវហ្នឹង។ ចាស ពេលមកដល់កន្លែងៗភ្នំស្រួច ភ្នំស្រង់យើងនេះ គេបាញ់នៅហ្នឹង បាញ់ពីខាងកើតផ្លូវ ពេលដែលយើងថ្ងៃល្ងាចជិតយប់ហើយហ្នឹង យើងដាក់ដាំបាយ ដាក់រទេះដាំបាយ យួនបាញ់ៗមក ប្រជាជនទាំងអស់ មិនថាតែរូបខ្ញុំទេ គឺរត់មុខសញ្ញាទៅលិចដូចគ្នា ព្រោះអឺកាំភ្លើងបាញ់មកពីកើតចាស។

[១៤:១៦:៤៤]

**ស៖** បាទ ខ្ញុំដូចជាមិនយល់ចម្លើយលោកស្រីច្បាស់លាស់ទេ។ សំណួរដែលខ្ញុំចង់សួរដូចតទៅនេះ។ សួរថាហេតុអ្វីបានជាលោកស្រីរត់ជាមួយនឹងមេគុកវៀតណាមចូលមក? ហេតុអីក៏លោកស្រីរត់ជាមួយប្រធានគុកហ្នឹង?

**ឆ៖** ចាស ពេលនោះខ្ញុំមិនទាន់អាចរំដោះខ្លួនចេញបានទេ។ បានសេចក្ដីថាវាអត់ទាន់មានឱកាស ឱកាសហ្នឹងវាមិនទាន់ហុចឲ្យយើងថា យើងរត់ទៅណាមកណា ព្រោះអីយើងក៏អត់មានទិសដៅ អត់ដឹងថាស្រុកទេសទៅណាមកណាដែរ។ ដល់គេថាឲ្យប្ដេជ្ញាអ៊ីចឹង ពេលហ្នឹងវៀតណាមមកចូលដល់ហើយ ឮសន្ធឹកកាំភ្លើងបាញ់ល្វើយៗហើយ ហើយឡានហោះក៏ទម្លាក់គ្រាប់ដែរ។ ពេលហ្នឹងហើយដែលយើងនឹកឃើញថាពិតជាមានឱកាសៗរត់ចេញពីគេឲ្យបានរួចខ្លួន។ ចាស ពេលនោះ ដល់ឱកាសយើងគិតថាប្រហែលជាមានឱកាសគឺត្រឹមត្រូវមែន មកដល់ជិតយប់ហ្នឹងគេឲ្យយើងៗនាំគ្នាឈប់វាច្រើនគ្នា ប្រជាជនទាំងអស់ហ្នឹង មិនមែនតែខ្លួនខ្ញុំផ្ទាល់ ឬក៏មួយមេគុក ឬក៏មួយដែល រ៉េត ដែលគេឲ្យខ្ញុំប្ដេជ្ញាទេ គឺគ្នាច្រើន គឺច្រើន។ អ៊ីចឹងវាមានឱកាសត្រង់ថា គេបាញ់ហើយ អាណាក៏មិនបានមើលយើង មិនគិតគូររឿងថាយើងរត់ទៅណាមកណាដែរ យើងធ្វើម៉េចរត់ឲ្យរួចមួយពេលហ្នឹងទៅ។ ការពិតរបស់ខ្ញុំហ្នឹងគឺរត់បានរួចខ្លួនអ៊ីចឹងមែន។

**ស៖** តើលោកស្រីជាអ្នកទោសមន្ទីរក្រាំងតាចាន់តែម្នាក់ឯងគត់ ដែលបានរត់ជាមួយ តាអាន់ ឬក៏មានអ្នកទោសផ្សេងទៀតដែលរត់ជាមួយ តាអាន់ ដែរ?

**ឆ៖** ចាស មានគ្នាច្រើន។ ប៉ុន្តែមិនមែនអ្នកទោសក្រាំងតាចាន់ទេ អ្នកទោសដែលមកពីស្រុកអង្គរជ័យ ដែលគេឲ្យខ្ញុំប្ដេជ្ញាហ្នឹង ហ្នឹងហើយអ្នកទោសហ្នឹង។ តែខ្ញុំ -- របៀបថាយើងទើបជួបគ្នាភ្លាម ខ្ញុំអត់អាចស្គាល់អ្នកណាបានទេ។

[១៤:១៩:២៤]

**ស៖** ខ្ញុំបានឮលោកស្រីនិយាយអំពីឆ្អឹងដែលលោកស្រីបានឃើញ។ តើជាការត្រឹមត្រូវដែរឬទេលោកស្រីបានឃើញឆ្អឹងហ្នឹងក្រោយពីរំដោះមន្ទីរក្រាំងតាចាន់ហើយ គឺថាមកក្រោយថ្ងៃរំដោះដោយវៀតណាមហើយៗ ឬក៏យ៉ាងណា?

**ឆ៖** ចាស មិនមែនក្រោយរំដោះទេ។ មុនវៀតណាមចូលប្រហែលជាកន្លះឆ្នាំ ពេលនោះ ខ្ញុំជាប់គុកវាជាងពីរឆ្នាំហើយ។ អ៊ីចឹងគេឲ្យ យាយញ៉ ក្រុមគ្រួសារយាយញ៉ គេឲ្យវិលត្រឡប់ទៅផ្ទះវិញ។ នៅ

ខ្ញុំ នៅតាដាំ នៅសែន នៅអ៊ីហាន។ ចាស នៅគ្នាប្អូនប្រាំនាក់ហ្នឹង។ អ៊ីចឹង អ៊ីផុន ប្រាប់ខ្ញុំយូរហើយតាំងអីខ្ញុំចូលទៅបានមួយខែជាងថា ប្ដីអ៊ីរុនឯងគេវៃចោលនៅហ្នឹង។ គំនួចចិត្តខ្ញុំគុំថា តែមានឱកាសខ្ញុំនឹងទៅមើល ទៅឃើញឆ្អឹងប្ដីខ្ញុំដូចគេប្រាប់ដែរអត់។ ចាស នេះជាការជាក់ស្ដែងដែលខ្ញុំឃើញដោយផ្ទាល់ភ្នែក មិនមែនការឮគេថា ឬក៏ឃើញនៅក្រោយៗគេរំដោះបានហ្នឹងទេ មិនមែនទេ។ មុនពេលដែលខ្ញុំរត់ ពេលវៀតណាមចូលជិតដល់។

**សៈ** ខ្ញុំដូចជាមុនយល់ច្បាស់អំពីចម្លើយរបស់លោកស្រីទេ។ លោកស្រីបាននិយាយថាលោកស្រីបានឃើញឆ្អឹងក្រោយថ្ងៃរំដោះ ឬក៏យ៉ាងម៉េច? ខ្ញុំដូចជាមិនសូវយល់។

**ឆៈ** ចាស មិនមែនក្រោយរំដោះទេ គឺមុនរំដោះប្រហែលជាជិតកន្លះឆ្នាំ ពេលនុ៎ងខ្ញុំនៅជាប់ឃុំនៅហ្នឹង អត់ទាន់មានរត់ទៅណាទេ។ ចាស តែខ្ញុំមានឱកាសគេឲ្យមើលគោហ្នឹង ស្រែមាត់បណ្ដើរថា ពូអើយគោទៅលិចហើយ អាមាត់ក៏ស្រែក អាខ្លួនយើងក៏រត់ទៅ ដើម្បីៗថាមើលតែម្ដង បើគេថាម៉េច? ខ្ញុំថាខ្ញុំដេញចាប់គោ។ តែគោលបំណងមិនមែនចាប់គោទេ គោលបំណងទៅរកមើល តើមានឆ្អឹងដូចគេប្រាប់យើងអត់? ទៅជួបមែន ជួបភ្លែតដេញគោចេញមកភ្លាម មិនបាននៅឈរអែអង់ទេ ខ្លាចគេមកទាន់គេចាប់យើង។

[១៤:២១:៥៩]

**សៈ** តើបើធៀបនឹងបរិវេណមន្ទីរសន្តិសុខហ្នឹង កន្លែងដែលលោកស្រីឃើញឆ្អឹងទាំងអស់នុ៎ងនៅកន្លែងណាដែរ?

**ឆៈ** នៅក្នុងបរិវេណកន្លែងក្រាំងតាចាន់ហ្នឹង គេមានរបងទី១ គឺរបងខាងក្រៅ។ របងទី២ ព័ទ្ធលួសហ្នឹង របងខាងក្នុង ហើយបរិវេណដែលគេវៃមនុស្សយើងចោលហ្នឹង គឺផ្លងផ្លូវ គឺផ្លងផ្លូវមួយដូចថាក្នុងៗកន្លែងនុ៎ងមានផ្លូវលំគេមួយសម្រាប់ដើរកាត់ទទឹងកន្លែងៗគេហ្នឹង។ អ៊ីចឹងពីខាងលិចផ្លូវហ្នឹងគេមានដីគ្រហុក តែត្រង់ថា ឮមាត់មនុស្សកូនង៉ែតយំក៏នៅកន្លែងនុ៎ងដែរ តែយើងមិនសន្និដ្ឋានថា វាមានគ្រហុក ដែរអត់ទេ ព្រោះអីយើងបានទៅឃើញតែគ្រហុកប្ដីយើងតែមួយគត់។ តែដល់ពេលក្រោយរំដោះខ្ញុំទៅប៉ុន្មានឆ្នាំនេះ បានខ្ញុំឃើញរណ្ដៅហ្នឹង។ ខ្ញុំអង្គុយគិត អង្គុយមើលកន្លែងណាៗផ្ទះអ្នកទោស កន្លែងណាចង្ក្រានបាយ កន្លែងណាគេសួរចម្លើយ បានខ្ញុំដឹងថា "អូ៎! អាកន្លែងស្រែកយំហ្នឹង អាហ្នឹងមានគ្រហុកដែរ។ អាហ្នឹងខ្ញុំទៅឃើញជាក់ស្ដែងអាពេលរំដោះហើយ តែពេលរំដោះហ្នឹងមិនបានឃើញឆ្អឹងទេ ឆ្អឹងគេដាក់នៅស្តូបហើយៗ។

**ស៖** លោកឆ្លើយវែង។ លោកស្រីបាននិយាយថាលោកស្រីឃ្វាលគោក្របី។ តើឃ្វាលគោក្របីនោះ នៅក្នុងបរិវេណគុកហ្នឹង ឬក៏នៅក្រៅបរិវេណគុក?

**ឆ៖** ចាស នៅក្នុងបរិវេណគុក។ គេមិនឲ្យខ្ញុំឃ្វាលរាល់ថ្ងៃទេ តែថ្ងៃហ្នឹងចៃដន្យអីគេលែងគោអាគ្នាវានុំងលែងគោ ហើយក៏គេថា "រុន អ្នា! មើលគោផង"។ អ៊ីចឹងខ្ញុំបានឱកាសហើយ ខ្ញុំដេញគោហ្នឹងទៅលិចទៅ ទៅអាកន្លែងគេសម្លាប់ប្ដីខ្ញុំហ្នឹង ឃើញឆ្អឹងហ្នឹងតែម្ដង។

[១៤:២៤:៤៦]

**ស៖** តើនៅពេលដែលលោកស្រីឃើញឆ្អឹងហ្នឹង តើគោនុំងដើរទៅម្ដុំណាដែរ?

**ឆ៖** ចាស គោដើរទៅម្ដុំខាងលិចកន្លែងខ្ញុំដេក អាឆ្លងផ្លូវទៅលិចហ្នឹង កន្លែងរណ្ដៅខ្ញុំប្រាប់ថាគេវៃប្ដីខ្ញុំហ្នឹង គឺវាទៅដល់កន្លែងហ្នឹង យើងឃើញ មើលទៅឃើញ អារបៀបថា យើងមើលមួយឆាច់អ៊ីចឹង យើងមើលទៅឃើញយើងក៏ដេញគោ ដឹកគោត្រឡប់វិលវិញ ខ្លាចគេតាមៗដានយើង។

**ស៖** តើបើធៀបទៅនឹងកន្លែងលោកស្រីដេកនោះ កន្លែងឆ្អឹងខ្មោចហ្នឹង មានចម្ងាយប៉ុន្មានដែរធៀបនឹងកន្លែងលោកស្រីគេងនៅសម័យនោះ?

**ឆ៖** ចាស ប្រហែលជាជាង ១០០ ម៉ែត្រ។ ព្រោះអីគេនិយាយមកយើងឮ យើងអាចឮ គ្រាន់ថាឮតិច ឬឮខ្លាំងតាមគេនិយាយ។ គ្រាន់តែបាំងតែព្រៃដំឡូងមីទេ ដំឡូងមីគេដាំក្រាស់ ធានាថាយើងមើលអត់ឃើញគេ ដាំក្រាស់។

**ស៖** លោកស្រីសាក្សី ខ្ញុំចោទសំណួរមួយដែលទំនងជាលំបាក។ តើលោកស្រីអាចបែងចែកពីអ្វីដែលលោកស្រីបានឃើញនៅពេលដែលលោកស្រីចូលទៅមន្ទីរកាលពី-បី-បួនឆ្នាំមុននេះ ហើយនិងអ្វីដែលលោកស្រីបានឃើញនៅពេលដែលលោកស្រីជាអ្នកទោសនៅទីនោះ? តើលោកស្រីអាចបែងចែកឲ្យច្បាស់ទេនូវភាពខុសគ្នា កាលសម័យដែលលោកស្រីជាប់ឃុំឃាំង ហើយនិងប៉ុន្មានឆ្នាំនេះ ពីរបីឆ្នាំមុននេះ?

[១៤:២៧:០៨]

**ឆ៖** ចាស សម័យដែលខ្ញុំជាប់គុកនៅក្រាំងតាចាន់ គ្មានប្រជាជនដើរហើរ ជិតហ្នឹងទេ គឺខ្ញុំមិនបានដើរវាស់វែងទេ ប៉ុន្តែខ្ញុំឮអ្នកនៅក្នុងគុកហ្នឹងគេនិយាយថា ១គីឡូម៉ែត្របួនជ្រុង ជុំវិញកន្លែងហ្នឹង គឺប្រជាជនអត់មានសិទ្ធិធ្វើស្រែ ដើរហើរ ដឹងឮអ្វីទាំងអស់ចាស។ តែ -- ហើយស្វាត់ឈើង ស្វាត់ជ្រងំអត់មានឮសូរមាត់សត្វ មាត់អី អត់មានទេ ព្រោះអីវាជាកន្លែងឃុំឃាំងគេហាមឃាត់ ហើយគេក៏មិនបានឲ្យប្រជាជនដឹកគោ ចិញ្ចឹមជ្រូក ចិញ្ចឹមមាន់អី នៅជិតក្បែរគេដែរ អត់ទេ។ គឺដូចថានៅកណ្ដាលភូមិ

គេដែរ តែហាក់មាន -- ហាក់ថាស្ងាត់ គេមិនឲ្យៗប្រជាជនចេញចូលហ្នុង គេអត់ឲ្យដឹងរឿងគេចាស។ ដល់ក្រោយនេះ ក្រោយរំដោះហ្នឹង ប្រជាជនដែលមានភូមិចាស់នៅអាកន្លែង ១គីឡូប្អូនជ្រុងហ្នឹង ផ្ទះតាសៀង តាអីហ្នឹងគាត់មកហ្នឹងវិញអស់ហើយ ខ្ញុំទៅ។ ដល់ខ្ញុំព្រោកនិយាយជាមួយគាត់ គាត់ថាគាត់មកមុនដំបូង អ៊ុំរុន អើយ ស្ងាត់ណាស់ ឮតែសត្វទីទុយយំទេ។ ដល់អ៊ុំមួយទៀតគាត់ថា “ខ្ញុំអត់ហ៊ាននៅទេ ខ្ញុំមករុះផ្ទះទៅធ្វើនៅនោះ ប៉ុន្តែលងមួយយប់ៗ” ព្រោះអីផ្ទះគាត់ហ្នឹងចងអ្នកទោសសម្លាប់នៅហ្នឹងអត់មាន -- ដូចថាគគ្រឹកគគ្រេងវិញ មានប្រជាជនរស់ជុំវិញបាន ចាស។

[១៤:២៨:៥៦]

**ស៖** ឥឡូវខ្ញុំសូមចោទសំណួរឡើងវិញ ខ្ញុំគិតថាលោកស្រីប្រហែលជាមិនបានឆ្លើយនឹងសំណួរខ្ញុំទេអម្បាញ់មិញនេះ។ ខ្ញុំបានសួរលោកស្រីថា តើលោកស្រីអាចបែងចែកច្បាស់លាស់ដែរឬទេ អ្វីដែលលោកស្រីបានឃើញ នៅពេលដែលលោកស្រីទៅមន្ទីរក្រាំងតាចាន់ថ្មីៗនេះ និងខុសគ្នាយ៉ាងម៉េចដែរ ពីអ្វីដែលលោកស្រីបានឃើញពេលដែលលោកបានជាប់ឃុំឃាំងនៅទីនោះៗ? តើលោកស្រីអាចបង្ហាញភាពខុសគ្នាបានទេ នៅមន្ទីរក្រាំងតាចាន់ហ្នឹង ពីមុននោះកាលលោកស្រីជាប់ឃុំឃាំងខុសពីឥឡូវ -- ពីរបីឆ្នាំមុននេះយ៉ាងម៉េចដែរ?

**ឆ៖** ចាស កាលពីសម័យជាប់នៅកន្លែងក្រាំងតាចាន់ យើងទៅឃើញមានកន្លែង ទៅមានកន្លែងសួរចម្លើយ មានកន្លែងអ្នកទោសដេក មានកន្លែងបុគ្គលិក ដែលអ្នកមេគុកគេហ្នឹងដេក បែងចែកច្បាស់លាស់។ តែដល់ខ្ញុំមកឥឡូវនេះ ខ្ញុំឃើញគេធ្វើស្តូបសម្រាប់ដាក់ធាតុអ្នកទោស ហើយមានរោងគេសម្រាប់និមន្តលោកបង្សុកូលលនៅខែចូលឆ្នាំ និងមានសាលាមួយទៀត ថា ខ្ញុំសួរតានៅហ្នឹង គាត់ថាបរទេសជួយតម្កល់ភស្តុតាងដែលគុកក្រាំងតាចាន់បានទុកនៅ ដូចជាកង អាកងច្រវាក់ស៊កជើងហ្នឹងហើយនិង -- ខ្ញុំឃើញអាហ្នឹង ឃើញកងហ្នឹង ហើយនិងបញ្ជីៗអ្នកទោស ឃើញទុកដាក់បាន -- ខ្ញុំឃើញហ្នឹងនៅកន្លែងអង្គការធ្វើឲ្យហ្នឹង។ ខ្ញុំឃើញតែប៉ុណ្ណឹងទេ។

**ស៖** ខ្ញុំព្យាយាមសួរម្តងទៀត។ តើៗលោកស្រីបានឃើញឆ្អឹងទាំងអស់ហ្នឹង លោកស្រីបានឮគេនិយាយពីឆ្អឹងទាំងអស់ហ្នឹង ក៏ប៉ុន្តែតាមពិតនោះ នៅពេលដែលគេឃុំឃាំងរូបលោកស្រីនៅសម័យខ្មែរក្រហមនោះ លោកស្រីមិនដែលឃើញឆ្អឹងទាំងហ្នឹងទេ។ អ៊ីចឹងមែនទេ?

**ឆ៖** ចាស អង្គាល់គេឃុំឃាំងធ្វើម៉េចមានបានឃើញឆ្អឹង បើឆ្អឹងហ្នឹងគេយកវើចោលក្នុងរណ្តៅដល់ពេលឥឡូវនេះបានជាឃើញឆ្អឹង ព្រោះប្រជាជនមកវិញ ឃើញឆ្អឹងអ៊ីចឹង គាត់ប្រមូលដាក់គំនុំ ដល់

ប្រមូលដាក់ម្ដុំអ៊ីចឹង មានអង្គការគេមកជួយធ្វើអាកន្លែងស្តូបដាក់ដែលធាតុហ្នឹង ទើបបានគេរើសធាតុហ្នឹងទៅដាក់ក្នុងស្តូបតាមលលាដ៍ក្បាល តាមឆ្អឹងវែង ឆ្អឹងខ្លីដាក់តាមសណ្ឋាន។

[១៤:៣១:៥០]

**ស៖** បាទ សូមអរគុណ ឥឡូវខ្ញុំយល់រាងច្បាស់បន្តិចហើយ។ តើលោកស្រីមានចាំដែរឬទេថាមានអ្នកណាដែលនិយាយអំពីមីក្រូ ហើយចាក់ភ្លេងតាមមីក្រូនៅពេលដែលមានរឿងអីកើតឡើងនៅក្រាំងតាចាន់ តើមានបុគ្គលណាជាក់លាក់ម្នាក់និយាយប្រាប់លោកស្រីពីរឿងហ្នឹងដែរឬទេ?

**ឆ៖** ចាស ពេលដែលខ្ញុំឃើញជាក់ស្តែងគឺគេចាក់មេក្រូហ្នឹងហ្មង មីក្រូហ្នឹងគ្រាន់តែគេនិយាយដំបូង តែខ្ញុំអត់បានថា -- មិនចាំថាអ្នកណាជាអ្នកនិយាយទេ គ្រាន់តែគេនិយាយថា "អ្នកទោសឥឡូវនេះបានមកកសាងខ្លួន កែប្រែខ្លួនបានហើយ ឥឡូវអង្គការឲ្យវិលត្រឡប់ទៅផ្ទះវិញ" គេនិយាយប៉ុណ្ណឹងហើយមីក្រូ គេចាក់បទចម្រៀងគេទៅ ឮផ្ទាល់ពេញហ្នឹងទៅ ចាសតែប៉ុណ្ណឹង។ តែត្រង់ថា អ្នកនិយាយខ្ញុំមិនៗអាចដឹងគេច្បាស់ទេ ព្រោះអីយើងក៏អត់ដឹងថាមីក្រូហ្នឹង គេដាក់នៅណាដែរ ឮតែសំឡេង។

**ស៖** តើវាអាចដែរឬទេ គឺ ដែលថា សយ សែន ហ្នឹង គាត់ហ្នឹងហើយជាអ្នកបាននិយាយប្រាប់លោកស្រីអំពីការចាក់ភ្លេងនៅក្នុងមន្ទីរក្រាំងតាចាន់នេះ ចាក់មីក្រូនោះ? តើអ៊ីចឹងមែនទេ អាចអ៊ីចឹងទេ សយ សែន ជាអ្នកប្រាប់លោកស្រីទេ?

**ឆ៖** ចាស ករណីនេះ ខ្ញុំគេប្រាប់មិនមែនតែម្នាក់ទេ។ អ៊ីផុន ដែលខ្ញុំនិយាយថា អ៊ីផុនៗហ្នឹងគាត់ជាប់គុកមុនខ្ញុំយូរឆ្នាំណាស់ គាត់ដឹងពីរបៀបរបបក្នុងៗហ្នឹងទាំងអស់។ អ៊ីចឹងពួកយើងដែលជាជនរងគ្រោះស្គាល់គ្នាអ៊ីចឹង គេខ្សឹបប្រាប់ គេថា "នែ៎! តែចាក់មីក្រូ បន្តិចទៀតឲ្យទៅផ្ទះទៀតហើយ" អ៊ីចឹង។ ដូច្នេះ ខ្ញុំចេះតែតាមដានទៅ វាអ៊ីចឹងមែន ឲ្យតែចាក់មីក្រូ យើងឃើញគេបណ្ដើរអ្នកទោសចេញហើយតែអត់ចងទេ។ ទោះបីមិនចងក៏រត់មិនរួចដែរលោក ព្រោះអីអ្នកទោសមកជាប់គុក១០ថ្ងៃ កន្លះខែ មួយខែ ឬពីរខែ បបរមួយវែកប៉ុណ្ណោះហ្នឹង អង្គុរមើលអត់ឃើញផងហ្នឹង អ៊ីចឹងអាថាមពល អាកម្លាំងហ្នឹង គ្រាន់តែគេរុញក៏ដួលដែរ។ ហេតុនេះ ខ្ញុំឃើញគេហៅទៅ ខ្ញុំលួចមើលតាមជញ្ជាំងគុក អត់ដែលចងទេ តែចំពោះអ្នកដើរអត់រួច គេយករទេះរុញហ្នឹងហ្មង ហើយរទេះរុញហ្នឹង ជួនកាលពួកវា ជួនកាលតាដាំ ជួនកាល ពូសែន តាមតែគេប្រើគាត់ តាមពិតគាត់ជាអ្នកទោសទេ គេសម្លាប់ឱគាត់ដែរហ្នឹង តែដល់នៅយូរទៅ គេហៅ "បាតគុក" ស្រេចតែគេប្រើ ចាស។

[១៤:៣៥:៣០]

**ស៖** ខ្ញុំចោទសំណួរសាមញ្ញមួយទេ ខ្ញុំគ្រាន់ អម្បាញ់មិញខ្ញុំគ្រាន់តែចង់សួរថា តើ សយ សែន ហ្នឹងប្រាប់លោកថាមានមីក្រូ ឬក៏លោកស្រីខ្លួនឯងហ្នឹងបានឃើញខ្លួនឯង ហើយអ៊ីចឹងអាចជម្រាបជូនតុលាការបានទេថា មីក្រូនោះនៅកន្លែងណា ហើយគេចាក់បទភ្លេងអ្វីដែរ បើតាមលោកស្រីចាំនោះ?

**ឆ៖** មីក្រូ ខ្ញុំអត់ដឹងថាគេដាក់នៅកន្លែងណាទេ ប៉ុន្តែឮសំឡេងដូចចេញពីផ្ទះប្រធាន ប្រធានគេ ហើយគេចាក់បទ បទចម្រៀងប៉ុល ពត។ ឥឡូវហ្នឹង ខ្ញុំភ្លេចអស់ហើយ មិនដឹងគេថាគេច្រៀងថាម៉េច។

**ស៖** តើសំឡេងដែលលោកស្រីឮចេញពីមីក្រូហ្នឹង ឮខ្លាំងប៉ុនណាដែរ?

**ឆ៖** ចាស ខ្លាំង។ ខ្លាំងរហូតដល់ថាអ្នកទោសស្រែកហ្នឹង យើងសឹងតែថា សឹងតែមិនឮផង ប៉ុន្តែយើង ដូចថាយើងដឹង យើងចេះតែផ្ទៀងត្រចៀកទៅ អាចឮ តែបើថាអ្នកមិនចាប់អារម្មណ៍ អត់ឮសោះ ឮតែមីក្រូហ្នឹង សឹងបែកក្រដាសត្រចៀកហើយ។

**ស៖** លោកស្រីបាននិយាយថា នៅក្នុងមន្ទីររបស់ តាអាន់ អ៊ីចឹងត្រឹមត្រូវដែរឬទេ មីក្រូហ្នឹង?

**ឆ៖** ចាស គឺចេញពីក្នុងរោងហ្នឹង តែមិនដឹងថាគេដាក់កន្លែងណាទេ ព្រោះអីក្នុងរោងហ្នឹង វាមានផ្ទះបុគ្គលិកគេដែរ ដេកនៅក្នុងហ្នឹង បុគ្គលិកអ្នកទោសគេហ្នឹង អ្នកគុកហ្នឹង។

**ស៖** តើខ្ញុំពិតជាយល់ត្រឹមត្រូវដែរឬទេ គឺថាលោកស្រីមិនបានឃើញមីក្រូនោះទេ លោកស្រីគ្រាន់តែបានឮសំឡេងដែលចេញពីមកខាងមន្ទីរក្រាំងតាចាន់នោះទេ។ តើត្រឹមត្រូវដែរឬទេ?

**ឆ៖** ចាស ត្រឹមត្រូវ គឺយើងមិនបានឃើញរូបភាពមីក្រូទេ តែយើងចំណាស់នេះហើយ ក៏ដឹងថាគេចាក់ចេញពីមីក្រូដែរ ពិតមែនតែភ្នែកយើងអត់ឃើញ តែយើង -- ខ្ញុំចាស់ដែរហើយ ខ្ញុំមិនដឹង ខ្ញុំធ្លាប់ស្គាល់មីក្រូដែរ ហើយក៏ធ្លាប់ស្គាល់ ដែលឮគេចាក់មីក្រូអានៅកន្លែងការដ្ឋាន គេឲ្យយើងទៅរែកដីហ្នឹង ក៏គេចាក់មីក្រូដែរ។ អ៊ីចឹងខ្ញុំៗសន្និដ្ឋានក្នុងចិត្តខ្ញុំថា អាហ្នឹងមីក្រូហ្នុង ព្រោះអីយើងធ្លាប់ឮនៅកន្លែងការដ្ឋានគេចាក់។

**ស៖** ក៏ប៉ុន្តែលោកស្រីមិនបានឃើញមីក្រូទេ តើខ្ញុំនិយាយហ្នឹងត្រឹមត្រូវដែរឬទេ?

**ឆ៖** *(មីក្រូហ្នូនមិនទាន់ដំណើរការ)*

**ប្រធានអង្គជំនុំ៖**

ឆ្លើយៗតប! អំមិញអត់ទាន់ឆ្លើយតបទេព្រោះឆ្លើយពេលដែលក្បាលមេក្រូមិនទាន់ប្រតិបត្តិការ។

**លោកស្រី វង សារុន៖**

**ឆ៖** ចាស ត្រឹមត្រូវ។ គឺខ្ញុំអត់បានឃើញមែន មិនដឹងថាមីក្រូហ្នឹងគេដាក់នៅកន្លែងណា តែ

ត្រចៀកស្តាប់ឮ ភ្នែកយើងដែលធ្លាប់ឃើញ មីក្រូហ្នឹងរាងអាម៉េច គេចាក់នៅការដ្ឋានកន្លែងយើងរែកដីធ្វើទំនប់។ អ៊ីចឹងខ្ញុំសន្និដ្ឋានថា អាហ្នឹងមីក្រូ ព្រោះខ្ញុំដែលឃើញនៅការដ្ឋាន វាអ៊ីចឹង វាឮអ៊ីចឹង និយាយអ៊ីចឹងដូចគ្នា។

**លោក វ៉ិចទ័រ កូប៉េះ**

ឥឡូវ ខ្ញុំចូលប្រធានបទថ្មីមួយទៀត លោកប្រធាន ប្រហែលជាត្រូវសម្រាកមុន ឬក៏យ៉ាងណាលោកប្រធាន។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ ឥឡូវនេះដល់ពេលសម្រាកហើយ អង្គជំនុំជម្រះប្រកាសសម្រាកចាប់ពីពេលនេះតទៅរហូតដល់ម៉ោងបី សូមអញ្ជើញចូលវិញ ដើម្បីបន្តកិច្ចដំណើរការសវនាការ។

មន្ត្រីរដ្ឋបាលតុលាការសម្របសម្រួលផ្តល់កន្លែងសម្រាកនៅបន្ទប់រង់ចាំសម្រាប់សាក្សី និងអ្នកជំនាញ ដល់សាក្សីរូបនេះនៅក្នុងអំឡុងពេលឈប់សម្រាក និងឲ្យអញ្ជើញគាត់ ព្រមទាំងបុគ្គលិកអង្គការធី.ភី.អូ មកកាន់កន្លែងផ្តល់សក្ខីកម្មនៅក្នុងបន្ទប់សវនាការនេះនៅវេលាម៉ោងបី។

សម្រាកចុះ!

*(សវនាការសម្រាកពីម៉ោង ១៤:៤០ នាទី ដល់ម៉ោង ១៥:០២ នាទី)*

[១៥:០២:៣៥]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ និងផ្តល់វេទិកាជូនទៅក្រុមមេធាវីការពារក្តីលោក នួន ជា ដើម្បីមានឱកាសបន្តការតាំងសំណួរដេញដោលចំពោះសាក្សី។

**លោក វ៉ិចទ័រ កូប៉េះ**

សូមអរគុណលោកប្រធាន។

**សួរដោយលោក វ៉ិចទ័រ កូប៉េះ**

**ស៖** ជម្រាបសួរលោកស្រីសាក្សី! ពេលដែលលោកស្រីឆ្លើយព្រឹកមិញ ខ្ញុំមិនមានវត្តមាននៅនេះទេ ប៉ុន្តែតាមរយៈកំណត់ត្រា ខ្ញុំដឹងថាលោកស្រីមិនដែលបានឃើញគេសម្លាប់មនុស្សណាម្នាក់នៅឯក្រាំងតាចាន់នោះទេ។ តើបើខ្ញុំថាអ៊ីចឹងត្រឹមត្រូវដែរទេ?

**លោកស្រី វង សារុន៖**

**ឆ៖** ចាស ត្រឹមត្រូវ ព្រោះខ្ញុំឃើញតែគេអ្នកទៅធ្វើហ្នឹងមកវិញប្រលាក់ឈាម រឿងថាគេយកទៅកាប់ ធ្វើវ៉ៃ យើងអត់ឃើញផ្ទាល់ភ្នែក យើងឃើញផ្ទាល់ភ្នែកតែត្រង់ថា គេចុះមកទឹកត្រពាំងពីខាងជើងហ្នឹង គេលាងឈាមគេ ឈាមប្រលាក់ខ្លួន។

**ស៖** ហើយខ្ញុំក៏យល់ផងដែរថា លោកស្រីមិនដែលបានឃើញសាកសពរបស់អ្នកទោសទេ នៅពេលដែលលោកស្រីជាប់ឃុំឃាំងនៅមន្ទីរសន្តិសុខក្រាំងតាចាន់។ តើត្រឹមត្រូវដែរឬក៏អត់ទេ?

**ឆ៖** ចាស ត្រឹមត្រូវ។

**ស៖** ហើយគឺថាយើងបានស្តាប់សក្ខីកម្មអ្នកទោសដែលជាប់នៅជាមួយលោកស្រីដែរ ឈ្មោះ សយ សែន គាត់បានឆ្លើយថា គាត់គឺថាធ្លាប់ចូលរួមក្នុងការជីករណ្តៅសាកសពដើម្បីដោះយកសម្លៀកបំពាក់របស់អ្នកទោសក្រោយពីសម្លាប់ហើយ។ គាត់ធ្លាប់ចូលរួមរាប់ចំនួនអ្នកទោសមុនគេសម្លាប់។ បើ សយ សែន គាត់ឆ្លើយថាអ៊ីចឹង។ តើលោកស្រីមានប្រតិកម្មថាម៉េច? យល់ថាម៉េចដែរ?

**ឆ៖** ចាស ខ្ញុំមិនបានដឹងថាគាត់ចូលរួម ឬមិនចូលរួម តែគាត់ជាអ្នកទោស គេឲ្យសិទ្ធិរបស់គាត់នៅក្រៅផ្ទះ។ អ៊ីចឹង រឿងៗមួយចំនួនគាត់អាចដឹង ព្រោះអីគាត់នៅក្រៅកន្លែងឃុំឃាំង។

**ស៖** ខ្ញុំយល់ហើយលោកស្រី ប៉ុន្តែសាក្សី សយ សែន បានឆ្លើយប្រាប់អង្គជំនុំជម្រះរាល់សកម្មភាពទាំងអស់ដែលគាត់ចូលរួមពាក់ព័ន្ធ គឺគាត់បានឆ្លើយអំពីអ្នកទោសដែលគេសម្លាប់ថ្មីៗ។ ដូច្នេះ សំណួររបស់ខ្ញុំនេះ តើហេតុអ្វីបានជាលោកស្រីមិនអាចឃើញរាល់សកម្មភាពដូច សយ សែន នៅឯមន្ទីរសន្តិ-សុខក្រាំងតាចាន់នោះ?

[១៥:០៦:២២]

**ឆ៖** ចាស ព្រោះខ្ញុំមិនទាន់មានសិទ្ធិថាគេទុកចិត្តយើង ឲ្យយើងដើរហើរមើលអីតាមចិត្តទេ។ ពេលថ្ងៃ ពេលព្រឹកគេនាំយើងទៅធ្វើការរែកដីដំបូក ឬក៏ដកសំណាប ឬក៏ស្ទូង ឬក៏រែកជីដាំឪឡឹក ដាំបន្លែ គេជូនយើងទៅ គេបណ្តើរយើង។ ស្គាល់ពាក្យថា បណ្តើរអ្នកទោសទេ? អ៊ីចឹងយើងមិនអាចងាកមើលទៅនេះ ឈប់ទៅនោះអី មើលអត់បានទេ។ អ៊ីចឹង បានថា ខ្ញុំធ្វើម៉េចបានឃើញ បើគេអត់ គេរបៀបថាគេឃ្វាលយើងដូចគោអ៊ីចឹង ពេលទៅគេបណ្តើរយើងទៅ យើងគ្មានសិទ្ធិថា ហ៊ឺ! ចូលទៅនេះបន្តិច នោះបន្តិចអី អត់ទេ តែបណ្តើរ ទៅហើយ ត្រង់ភ្លឹង។ អ៊ីចឹងបានសេចក្តីថា ហេតុហ្នឹងហើយ ដែលមិនអាចឲ្យខ្ញុំឃើញសព្វបាន។

**ស៖** ឥឡូវនេះ ខ្ញុំសុំត្រឡប់ទៅពេលដែលគេឃុំលោកស្រីនៅគុកក្រាំងតាចាន់។ ជាពិសេស ពាក់ព័ន្ធទៅនឹងការសួរចម្លើយលោកស្រី។ ខ្ញុំដឹងថាការសួរចម្លើយនេះគឺថា អស់រយៈពេលច្រើនថ្ងៃដែរនៅពេលដែលគេសួរចម្លើយលោកស្រី ប៉ុន្តែលោកស្រីមិនត្រូវបានគេវាយដំទេ មិនត្រូវបានអ្នកសួរចម្លើយវាយដំលោកស្រីទេ។ តើត្រឹមត្រូវដែរទេ?

**ឆ៖** ចាស ត្រឹមត្រូវ។

**ស៖** ហើយព្រឹកមិញ លោកស្រីបានឆ្លើយពាក់ព័ន្ធទៅនឹងខ្លឹមសារនៃការសួរចម្លើយ។ សូមលោកស្រីរៀបរាប់លម្អិតបន្តិចមើលពាក់ព័ន្ធទៅនឹងការសួរចម្លើយលោកស្រីហ្នឹង។ តើលោកស្រីនៅចាំថាគេសួរចម្លើយអ្វីខ្លះដែរទេ? ហើយលោកស្រីឆ្លើយទៅនឹងសំណួររបស់គេថាដូចម្តេចដែរ?

[១៥:០៨:៣៨]

**ឆ៖** ចាស ខ្ញុំនៅចាំមិនភ្លេចកន្លែងថា គេសួរខ្ញុំថា "តើប្តីយើងហ្នឹង ដឹកនាំឲ្យយើងចូល អា.កា.បេ យួនហ្នឹងដោយរបៀបណា?" ខ្ញុំឆ្លើយថា កុំថាដល់ខ្ញុំឆ្លើយ ត្រង់តែពាក្យថា អា.កា.បេ. យួនហ្នឹង ខ្ញុំអត់ដឹងថាយ៉ាងម៉េចទេ។ រហូតដល់ថ្ងៃនេះ ក៏ខ្ញុំនៅតែអត់ដឹងថា អា.កា.បេ. យួនហ្នឹងវាជាអ្វីដែរ? ហើយគេសួរទៀត គេសួរសម្រាយថា៖ "យើងហ្នឹងរៀនដល់ថ្នាក់ណា? ម៉ែឪយើងហ្នឹងធ្វើស្អី? បងប្អូនយើងហ្នឹងធ្វើអី?" ចាស គេសួរអ៊ីចឹង។ ហើយគេហាក់ដូចជានិយាយលេង មិនមែនជាសំណួរ គេថា៖ "យើស! កាលនៅធ្វើពេទ្យ បែបគ្មានចាក់ថ្នាំគ្មានអីឲ្យគេល្អៗទេ បើតាមមើលតែមុខហ្នឹង"។ អាហ្នឹងដូចថា វាមិនមែនជាសំណួរ។ របៀបថាគេនិយាយដូចថាបញ្ឈឺឲ្យយើង។ អាហ្នឹង ខ្ញុំមិនចាត់ទុកថាជាសំណួរទេ ទើបបានខ្ញុំចាំច្បាស់ត្រង់គេថា ប្តីខ្ញុំហ្នឹងដឹកនាំឲ្យខ្ញុំចូល អា.កា.បេ. យួន។ តែខ្ញុំអត់ដឹង។

**ស៖** តើមានអ្នកសួរចម្លើយណាម្នាក់ដែលប្រាប់លោកស្រីថាគេមិនជឿចម្លើយលោកស្រីថាលោកស្រីមិនតាមប្តីលោកស្រីអ៊ីចឹង។ មានគេប្រាប់អ៊ីចឹងទេ?

**ឆ៖** ខ្ញុំរៀងដូចអត់មានអ្នកណានិយាយថាអ៊ីចឹង អត់មាន គេអត់មាននិយាយ។

**ស៖** លោកស្រីនៅចាំថ្ងៃសួរចម្លើយចុងក្រោយបំផុតសម្រាប់លោកស្រី តើគេ តើអ្នកសួរចម្លើយមាននិយាយអីមកកាន់លោកស្រីទេ ឧទាហរណ៍ថាគេនឹងដាក់ទណ្ឌកម្ម គេនឹងអប់រំកែប្រែ ឬក៏គ្រាន់តែសួរចម្លើយ ហើយចប់អ៊ីចឹងទៅ?

[១៥:១០:៥៨]

**ឆ៖** ចាស ពេលដែលសួរចម្លើយហើយ គេនិយាយថា "ឲ្យធ្វើការទៅ ឲ្យធ្វើការឲ្យធ្ងន់ទៅ វា

គង់តែស្លាប់ទេ"។ អ៊ីចឹង ខ្ញុំគិតឃើញថា ជីវិតខ្ញុំមិនអាចចេញពីគុកក្រាំងតាចាន់បានទេរហូតដល់ថ្ងៃខ្ញុំស្លាប់ តែជីវិតខ្ញុំថ្ងៃបានគេជួយរំដោះឲ្យខ្ញុំរួចហ្នឹង អាហ្នឹងឪម៉ែទី២របស់ខ្ញុំហើយ។ ខ្ញុំៗស្លាប់ទៅវិញក៏ខ្ញុំអត់ភ្លេចដែរ បើគ្មានគេជួយខ្ញុំ គឺខ្ញុំស្លាប់រហូត ព្រោះអីគេនិយាយអ៊ីចឹងហើយថាឲ្យធ្វើការធ្ងន់ទៅគង់តែស្លាប់។ រឿងអីមិនស្លាប់លោក បង្គឺប៉ុណ្ណឹងៗ ហើយយើងកូនតូច ខ្ញុំមានជំងឺស្រុតស្បូនរហូតដល់ថ្ងៃនេះខ្ញុំទៅមើលផ្លាយដល់វៀតណាមក៏នៅតែអត់ជាដែរ។ នេះហើយជំងឺប្រចាំជីវិតដែលគេធ្វើបាបយើង។ គេមិនវ៉ៃដំមែន តែគេឲ្យយើងធ្វើការងារធ្ងន់។

**ស៖** លោកស្រីមានដឹងការសួរចម្លើយអ្នកទោសដែលជាប់ជាមួយលោកស្រីដែរទេ គឺ ហាន។ លោកស្រីមានដឹងទេនៅពេលគេសួរចម្លើយ ហាន ហ្នឹងតើវាយ៉ាងដូចម្តេចដែរ?

**ឆ៖** ពេលដែលគេសួរ អ៊ីហាន ឲ្យត្រឡប់វិលវិញ។ គេមិនបានឲ្យយើងអង្គុយជិតគ្នាទេ ឬដេកជិតគ្នាទេ គេខ្លាចយើងសួរៗគ្នា ដោយគេអត់ទុកចិត្តយើង។ អ៊ីចឹងគេឲ្យយើងដេកឆ្ងាយពីគ្នាមិនឲ្យមានការទាក់ទង ឲ្យដឹងថាវាយ៉ាងម៉េចៗអាហ្នឹង គឺអត់ទេ។

**ស៖** ប៉ុន្តែក្រោយពេលសួរចម្លើយហើយ គេឃុំលោកស្រីបន្តនៅក្រាំងតាចាន់បន្តទៅទៀត។ តើលោកស្រីមានឱកាសនិយាយជាមួយ ហាន បានទេ?

**ឆ៖** ចាស ពេលដែលគេសួរចម្លើយយើងទាំងពីររួចហើយ គេដាក់គុកយើងនៅក្នុងហ្នឹងបួនដប់ថ្ងៃទៀត បានគេចេញឲ្យយើង -- គេឲ្យយើងចេញធ្វើការ ដូចៗអ្នកជាប់គុកមុន។ ដូច អ៊ីហាន ជាមួយខ្ញុំហ្នឹង គឺជាអ្នកក្រោយគេបង្អស់ដែលបានជាប់គុក។ អ៊ីចឹងដល់ពេលគេដាក់បួនដប់ថ្ងៃ គឺក្រោយពីសួរហ្នឹងគឺបានគេចេញឲ្យយើងទៅរែកដីដំបូក ទៅរែកជីអាចម៍ ទៅដាំបន្លែ ទៅដក ទៅស្ទូងតាមៗគេប្រើ គេចង់ប្រើអី គេប្រើយើង។

[១៥:១៤:០៥]

**ស៖** តើលោកស្រីធ្លាប់និយាយជាមួយ ហាន អំពីការសួរចម្លើយ ហាន ទេ? តើ ហាន នេះត្រូវបានគេវាយដំដែរ ឬក៏អត់ទេនៅពេលសួរចម្លើយ? វាខុសប្លែកពីលោកស្រី ឬក៏អត់ទេ?

**ឆ៖** ចាស ហាន អត់ត្រូវបានគេវាយដំដែរ តែដល់ពេលបានយូរ អើ! ខ្ទង់កន្លះឆ្នាំទៅ យើងធ្វើការជាមួយគ្នាជិតស្និទ្ធទៅ សួរថា "ហាន គេសួរអី ហាន ឯង? គេថា គេសួរតែខ្ញុំហ្នឹងរឿង តាសែតហ្នឹងដឹកនាំ ព្រោះអីគាត់អ្នកបច្ចេកទេសវះកាត់ ហើយយើងជាបុគ្គលិកពេទ្យ។ អ៊ីចឹងគេសួរថា តាសែតហ្នឹងណែនាំយ៉ាងម៉េចខ្លះ? ដល់ហើយខ្ញុំថា ខ្ញុំអត់ដឹង"។ ក្រោយមកគេក៏ផ្លាស់ អ៊ីហាន គេមានប្តីនៅ

ស្រុកត្រពាំងគល់ហ្នឹងទៅ គេមកតាមប្តីរបស់គេមក។ វាមិនត្រូវអូសទាញ ហាន ឲ្យចូលក្នុងរឿងនេះផងព្រោះអី ហាន បានបែកពីម២២ យូរឆ្នាំណាស់។ មិនសមថារឿងនេះទៅពាក់ព័ន្ធជាមួយ ហាន សោះ។

**ស៖** តើគេដោះលែង ហាន នៅថ្ងៃតែមួយដូចលោកស្រីដែរ ឬក៏ថាគាត់ត្រូវបានរត់គេចខ្លួននៅថ្ងៃជាមួយដូចលោកស្រីដែរ ឬក៏ម៉េច?

**ឆ៖** ចាស គេបានរួចខ្លួនមុនខ្ញុំ ពេលរត់។ ពេលដែលប្រជាជនរត់ឈូទៅឈូមក គេជួបនឹងប្តីគេអ៊ីចឹងគេ ប្តីហ្នឹង បើ ខ្ញុំមិនដឹងថាពង្សសាវតារគេ ក្រែងលោគេស្គាល់ជាមួយមេគុក មេអី ខ្ញុំមិនដឹងទេណា។ តែដល់ពេលជួប ហាន គេក៏ឲ្យ ហាន ហ្នឹងទៅនៅជាមួយ ទៅតាម រត់ទៅតាមប្តីគេទៅ។

**ស៖** តើលោកស្រីមានឱកាសបានរត់ជាមួយគ្នានឹង ហាន ដែរ ឬក៏អត់ទេ?

[១៥:១៦:៣៥]

**ឆ៖** ចាស អត់ទេ។ ព្រោះហេតុអីបានជាខ្ញុំគ្មានឱកាសរត់? ពេលដែលរត់ជួប ខ្ញុំមើលទៅអត់ឃើញមានថាញាតិណាខ្ញុំស្គាល់ ហើយអ្នករត់ហ្នឹងសុទ្ធតែអ្នកទោសមកពីស្រុកនេះ មកពីស្រុកនោះដែលយើងមិនអាចស្គាល់គេបាន។ គ្មានឱកាសរត់។ ដល់តែគេទាន់ កាំភ្លើងផ្គោងទូងទាំងហើយបានមានឱកាសរត់។

**ស៖** លោកស្រីនៅចាំបានទេ មានអ្នកទោសប៉ុន្មាននាក់រត់ទៅជាមួយ ហាន មុនលោកស្រី?

**ឆ៖** ចាស អ្នកទោសដែលគេឲ្យទៅផ្ទះមុនហ្នឹង គ្រួសារយាយញ៉ៅ។ បន្ទាប់មកអ៊ីផុន ហើយនិងមួយទៀតឈ្មោះ វឿន នៅនារីទេ អាយុ១៥-១៦ ហ្នឹងចាស។ ហើយនៅខ្ញុំ តាដាំ ពូសែន ហើយអ៊ីហាន ហ្នឹងនៅក្រោយគេ ព្រោះអី ពូសែន និង តាដាំ ប្រហែលជាគេគិតថាទុកវាប្រើ បានជាគេអត់ឲ្យទៅហ្នឹង។ អាហ្នឹងខ្ញុំស្មានក្នុងចិត្ត តែបើខ្ញុំហើយ អ៊ីហាន អត់មានពេលឲ្យទៅទេ ព្រោះអីយើងទើបតែមកជាប់ក្រោយគេ។

**ស៖** ខ្ញុំប្រហែលជាយល់លោកស្រីមិនបានច្បាស់ទេ។ សំណួរសួរថា តើអ្នកទោសៗចំនួនប៉ុន្មាននាក់ដែរដែលរត់ចេញពីគុកក្រាំងតាចាន់ហ្នឹង នៅពេលវៀតណាមចូលមក គឺគ្រាន់តែមុនពេលវៀតណាមចូលមក?

**ឆ៖** ចាស អ្នកទោស គ្រាន់តែ -- អ្នកគុកហ្នឹងវានឹកឃើញថា វាត្រូវផ្លាស់កន្លែង ពេលហ្នឹងគ្មានទុកអ្នកណាទេ គេយកទៅវ៉ៃចោលទាំងអស់ ទុកតែខ្ញុំ និង អ៊ីហាន។

[១៥:១៩:២៨]

**ស៖** ខ្ញុំកំពុងតែមានភាពច្របូកច្របល់បន្តិច។ លោកស្រីចង់និយាយថា នៅពេលគេបញ្ជូនអ្នកទោសចេញ គឺថាលោកស្រីអត់បានរត់ចេញនោះទេ។ ខ្ញុំគ្រាន់តែចង់សួរថាដូច្នេះទេ ថាក្នុងរយៈពេលមួយសប្ដាហ៍ ឬក៏ពីរសប្ដាហ៍មុនវៀតណាមចូលមក តើអ្នកទោសទាំងអស់ហ្នឹងគេរត់ដោយខ្លួនឯង ឬត្រូវបានគេនាំយកចេញពីគុកក្រាំងតាចាន់?

**ឆ៖** ចាស មុនដែលវៀតណាមចូលដល់ គេមិនបានបញ្ជូនអ្នកណាទៅទាំងអស់ គឺគេប្រជុំថាយើងផ្លាស់ទីកន្លែង ហើយអ្នកដែលត្រូវផ្លាស់ទីកន្លែង ដល់តែពេលយប់គេនាំទៅតែម្ដង។ ដេកកន្លែងខុសគ្នា ខ្ញុំដេករោងផ្ទះមួយ អ្នកដែលគេបញ្ជូនហ្នឹងទៅផ្ទះមួយ។ តែពេលដល់អ្នកដែលបញ្ជូនទៅ ខ្ញុំមិនទាន់ដឹងថា គេយកទៅវ៉ៃចោលឬយ៉ាងណា។ អាពេលយប់ហ្នឹងយើងអត់បានដេកទេ ព្រោះអីយើងគិតខ្លាំងណាស់។ តែដល់ពេលព្រឹកឡើង គេប្រើឱ្យយើងទៅដងទឹកដាំបាយ ពេលដែលទៅដងទឹកនៅមាត់ត្រពាំងឃើញអាកន្សែងស្លូត្រនោះ វាទាក់ជាប់នឹងបន្លា បានខ្ញុំសន្និដ្ឋានថាអ្នកដែលទៅយប់មិញហ្នឹងគឺគេវ៉ៃចោលទាំងអស់។ ព្រោះអីឃើញៗក្រមា កន្សែងស្លូត្ររបស់មិត្តខ្ញុំទាក់ជាប់បន្លាហើយ បានសេចក្ដីថាគេនាំទៅ វាក្រាញមិនទៅ វាប្រទាញប្រទង់គ្នា បានជាកន្សែងស្លូត្រហ្នឹងវាជាប់ជាមួយបន្លានៅជិតផ្លូវហ្នឹង។ ហើយខ្ញុំបន្តទៀត ដល់ពេលនាំខ្ញុំទៅមានជួបអ្នកអស់ហ្នឹងឯណា បើដូរកន្លែងខ្ញុំទៅត្រូវតែជួបតែវាអត់ អ៊ីចឹងខ្ញុំគិតថាយកអ្នកទាំងអស់ហ្នឹងទៅវ៉ៃចោល។ អាហ្នឹងខ្ញុំអំណះអំណាងអ៊ីចឹងតែម្ដង ព្រោះអីដល់ពេលនាំខ្ញុំរត់ទៅ អត់មានឃើញអ្នកណាទាំងអស់។ អាហ្នឹងមិនបានសេចក្ដីថាមិនដឹងទៅណាអ្នកទាំងអស់!

[១៥:២២:០៣]

**ស៖** ខ្ញុំខ្លាចក្រែងតែខ្ញុំយល់លោកស្រី មិនបានច្បាស់លាស់ទេ ប៉ុន្តែខ្ញុំចូលប្រធានបទមួយថ្មីទៀតទៅចុះ។ ឥឡូវនិយាយពីពេលលោកស្រីធ្វើការនៅមន្ទីរពេទ្យ ម-២២។ ព្រឹកមិញលោកបានឆ្លើយអំពីមន្ទីរពេទ្យ ម-២២។ សូមលោកស្រីរៀបរាប់អំពីកិច្ចការលម្អិតរបស់លោកស្រីបន្តិចមើល៍ នៅឯមន្ទីរពេទ្យ ម-២២?

**ឆ៖** ចាស ខ្ញុំជាបុគ្គលិកសាមញ្ញសម្រាប់ធ្វើតាមគេ។ មេដុកទ័រគេដើរពិនិត្យជំងឺទៅ គេថា នែ! គេសរសេរក្នុងសៀវភៅឱ្យថា ត្រូវចាក់ថ្នាំនេះៗ យើងមាននាទីចាក់ថ្នាំហ្នឹងឱ្យយុទ្ធជន តាមគេ។ អាហ្នឹងតាមវេនចាក់ថ្នាំ ហើយពីវេនចាក់ថ្នាំគេដូចទៅវេនលាងរបួស។ គេណែនាំថា “របួសនេះត្រូវចាក់

ថ្នាំនេះ ត្រូវលាងធ្វើអ៊ីចេះ រុំធ្វើអ៊ីចេះ” យើងបានត្រឹមតែធ្វើតាមគេណែនាំ។ អ៊ីចឹងភារកិច្ចរបស់ខ្ញុំនៅម-២២ ដូរវេនគ្នា មួយអាទិត្យដាំបាយ មួយអាទិត្យចាក់ថ្នាំ មួយអាទិត្យលាងរបួស មួយអាទិត្យដើររកបន្លែម្ហូប សម្រាប់ផ្គត់ផ្គង់កន្លែងពេទ្យ។ ការងារមានតែប៉ុណ្ណឹង។

**ស៖** បាទ ខ្ញុំសូមរៀបសំណួរឡើងវិញ។ តើមានភាពខុសគ្នាដែរឬទេ រវាងអ្នកជំងឺដែលចូលមកសម្រាកក្នុងមន្ទីរពេទ្យ? សំណួរគឺសួរថាតើអ្នកជំងឺហ្នឹងត្រូវបានគេព្យាបាលឲ្យដូចៗគ្នាដែរ ឬមួយក៏ខុសគ្នា?

**ឆ៖** ចាស គេព្យាបាល កន្លែងរោងព្យាបាល គេដាក់ផ្នែកកម្មាភិបាលដោយកម្មាភិបាល។ យុទ្ធជនដោយយុទ្ធជន ហើយគេសរសេរក្នុងសៀវភៅពិនិត្យជំងឺ គេឲ្យចាក់ថ្នាំអីយើងចាក់ថ្នាំតាមតែគេដាក់ក្នុងសៀវភៅឲ្យ។

[១៥:២៤:៣៥]

**ស៖** លោកស្រីនិយាយអំពីការព្យាបាលយុទ្ធជន។ ខ្ញុំនិយាយចំពោះការព្យាបាលទៅឲ្យប្រជាជនដែលរស់នៅតាមសហករណ៍ នៅពេលប្រជាជនទាំងនោះចូលមកសម្រាកនៅមន្ទីរពេទ្យ តើគេផ្តល់ការព្យាបាលឲ្យហ្នឹងដូចៗគ្នាដែរឬក៏អត់ទេ?

**ឆ៖** ចាស ខ្ញុំសូមឆ្លើយ។ ខ្ញុំជាពេទ្យកងទ័ព មិនមែនជាពេទ្យព្យាបាលប្រជាជននៅតាមភូមិ ឬតាមសហករណ៍ឡើយ។

**ស៖** ដូច្នេះ លោកស្រីមិនដែលព្យាបាលអ្នកភូមិធម្មតាទេ អ្នករស់តាមសហករណ៍ធម្មតាទេ។ អ៊ីចឹងមែនទេ?

**ឆ៖** មុន -- កាលក្នុងសង្គ្រាម គឺនៅតែតាមៗព្រៃនិយាយរួម ដល់ទៅបែកហ្នឹងបានមកចេញតាមស្រុកអ៊ីចឹងទៅ។ ពីដើមៗនៅក្នុងព្រៃ អត់ដែលបានជួបប្រជាជនថាអ្នកណាឈឺហើយយកទៅព្យាបាលនៅពេទ្យហ្នឹងទេ ព្រោះពេទ្យនេះ ជាពេទ្យកងទ័ព។

**ស៖** តើលោកស្រីដែលបានក្លាយខ្លួនទៅជាសមាជិកបក្សកុម្មុយនីស្តកម្ពុជាដែរទេ? តើលោកស្រីដែលបានក្លាយខ្លួនទៅជាសមាជិកខ្មែរក្រហមដែរទេ?

**ឆ៖** ចាស អត់ដែលទេ ព្រោះខ្ញុំជាប់និន្នាការ ឪពុកខ្ញុំគាត់ធ្វើជាទាហានកាលជំនាន់សង្គមរាស្ត្រនិយម។

**ស៖** សំណួរចុងក្រោយរបស់ខ្ញុំ។ ខ្ញុំឃើញថាលោកស្រីដែលអង្គុយជាប់នឹងលោកស្រីសាក្សីគឺជាបុគ្គលិកមកពីអង្គការ ធី.ភី.អូ។ តើលោកស្រីហ្នឹង គាត់មកអង្គុយក្បែរលោកស្រីហ្នឹង ដោយសារតែលោកស្រីស្នើសុំ ឬក៏អត់ទេ?

**ឆ៖** ចាស ខ្ញុំស្នើសុំឲ្យគាត់អង្គុយជិត ព្រោះខ្ញុំមានជំងឺលើសឈាម និងជំងឺខ្សោយបេះដូង ខ្ញុំខ្លាចថាពេលណា ខ្ញុំរន្ធត់ ខ្ញុំអាចឡើងឈាមស្លាប់ពេលហ្នឹងក៏ៗពិត ហេតុនេះបានជាខ្ញុំស្នើថាឲ្យមួយ -- ឲ្យមានម្នាក់ ប៉ុន្តែខ្ញុំដឹងថាអង្គការណា ខ្ញុំអត់ដឹងទេ ខ្ញុំគ្រាន់តែថាសុំឲ្យមកអង្គុយជិតខ្ញុំ ក្រែងលោ ខ្ញុំមានបញ្ហាផ្នែកសុខភាព។

[១៥:២៧:៣១]

**ស៖** នៅក្នុងរយៈប៉ុន្មានឆ្នាំថ្មីៗនេះ តើលោកស្រីមានដែលជួបបញ្ហាប្រព័ន្ធសរសៃប្រសាទដែរទេ ខ្លួនលោកស្រីផ្ទាល់នេះ មានបញ្ហាខាងផ្នែកចិត្តសាស្ត្រ ខាងផ្នែកសរសៃប្រសាទដែរទេ?

**ឆ៖** ចាស អត់មានទេ។ បើខ្ញុំមានផ្នែកហ្នឹង ខ្ញុំមិនអាចបង្រៀនសិស្សបានទេ។

**លោក វ៉ិចទ័រ កូប៉េ៖**

សូមអរគុណលោកប្រធាន ខ្ញុំអស់សំណួរហើយ។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ ហើយសវនាការថ្ងៃនេះដល់ពេលឈប់សម្រាកហើយ ដោយសារនៅសល់ម៉ោងមែន ប៉ុន្តែនៅសល់ពេលវេលាកន្លះម៉ោងទៀត ប៉ុន្តែថ្ងៃនេះយើងអត់មានសាក្សីបម្រុងទេ។

អង្គជំនុំជម្រះប្រកាសផ្អាកកិច្ចដំណើរការសវនាការសម្រាប់ថ្ងៃនេះត្រឹមនេះ សវនាការលើកទៅបន្តធ្វើនៅថ្ងៃស្អែកថ្ងៃអង្គារ ទី១៩ ខែឧសភា ឆ្នាំ២០១៥ ចាប់ផ្តើមពីម៉ោងប្រាំបួន ព្រឹកទៅ។ ហើយសវនាការនៅថ្ងៃស្អែកនេះ អង្គជំនុំជម្រះនឹងធ្វើសវនាការស្តាប់សក្ខីកម្មសាក្សីដែលមានរហស្សនាម 2-TCW-836។ សូមភាគីជ្រាប និងអញ្ជើញចូលរួមតាមពេលវេលាបានកំណត់នេះ។

អង្គជំនុំជម្រះសូមអរគុណចំពោះលោកស្រី វង សារុន ដែលបានចំណាយពេលវេលាដែលមានតម្លៃមកផ្តល់សក្ខីកម្មក្នុងរយៈពេល -- ក្នុងឋានៈជាសាក្សីក្នុងរយៈពេលមួយថ្ងៃកន្លងមកនេះ ហើយសក្ខីកម្មរបស់លោកស្រី នឹងអាចចូលរួមវិភាគទានក្នុងការស្វែងរកការពិតក្នុងរឿងក្តីនេះ ហើយការផ្តល់សក្ខីកម្មរបស់លោកស្រីបានដល់ទីបញ្ចប់ហើយ វត្តមានរបស់លោកស្រីនៅ អ.វ.ត.ក នេះ លែងមានភាពចាំបាច់ទៀតហើយ លោកស្រីអាចវិលត្រឡប់ទៅកាន់លំនៅដ្ឋាន ឬក៏គោលដៅណាដែលលោកស្រី

មានបំណងចង់ទៅបានហើយ សូមលោកស្រីធ្វើដំណើរប្រកបដោយសុវត្ថិភាព។ ហើយអង្គជំនុំជម្រះក៏សូមអរគុណផងដែរចំពោះបុគ្គលិកអង្គការ ធី.ភី.អូ គឺលោកស្រី ឆាយ ម៉ារីដែន។

មន្ត្រីរដ្ឋបាលតុលាការសម្របសម្រួលជាមួយនឹងបុគ្គលិកនៃអង្គភាពគាំពារសាក្សី និងអ្នកជំនាញនៅក្នុងការជូនសាក្សី វង សារុន វិលត្រឡប់ទៅកាន់ទីលំនៅរបស់គាត់ ឬក៏គោលដៅណាដែលគាត់ចង់ទៅបានហើយ។ ហើយបង្គាប់ឲ្យអនុរក្សមន្ទីរឃុំឃាំងនាំខ្លួនជនជាប់ចោទទាំងពីររូបត្រឡប់ទៅកាន់មន្ទីរឃុំឃាំងនៃអ.វ.ត.ក វិញចុះ និងបង្គាប់ឲ្យនាំខ្លួនពួកគាត់ត្រឡប់មកចូលរួមសវនាការនៅព្រឹកថ្ងៃស្អែកឲ្យបានមុនម៉ោងប្រាំបួន។

សម្រាកចុះ៕

*(សវនាការផ្អាកនៅម៉ោង ១៥:៣០ នាទី)*